# ទស្សនវិជ្ជា
# នៃ
# អភិសមាចារ

ពាក្យកាព្យ

មាន ÷

- ច្បាប់ពាក្យស្លោក
- ច្បាប់ព្រះធម្មៈ
- ច្បាប់ព្រះវិទូរ
- ច្បាប់ព្រះក្រឹស្នា
- ច្បាប់ព្រះភីស្មៈ
- ច្បាប់ព្រះរាជាខ្មែរ
- យុគ
- អម្រឹត

រៀបរៀងដោយ

**ធន់ ហ៊ិន**

អតីតសាស្ត្រាចារ្យភាសាបារាំង

ព.ស.២៥៥០ គ.ស.២០០៦

Library of Cambodia

# ទស្សនវិជ្ជា

## នៃ

# អភិសមាចារ

(ពាក្យកាព្យ)

រៀបរៀង

ដោយ

**ធន់ ហ៊ិន**

អតីតសាស្ត្រាចារ្យភាសាបារាំង

ព. ស. ២៥៥០ រក្សាសិទ្ធិ គ.ស. ២០០៦

# សេចក្តីថ្លែងអំណរព្រះគុណ

សៀវភៅ **ទស្សនវិជ្ជានៃអភិសមាចារ** នេះត្រូវបានបោះពុម្ពឡើង ដោយព្រះរាជូបត្ថម្ភរបស់សម្តេច **នរោត្តម សិរីវុឌ្ឍ** ឧត្តមទីប្រឹក្សាព្រះមហាវីរក្សត្រ **ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ក្នុងគោលបំណងទុកចែកជាព្រះអំណោយ និងតម្កល់ទុកជាឯកសារ ដើម្បីបម្រើប្រយោជន៍សាធារណៈសម្រាប់កុលបុត្រខ្មែរទាំងឡាយ ដែលស្រឡាញ់ការអប់រំ និង ទស្សនវិជ្ជាស្តីពីសីលធម៌ដ៏ឧត្តុង្គឧត្តមនេះ ។

ទូលព្រះបង្គំ ខ្ញុំបាទ សូមថ្លែងអំណរព្រះគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះព្រះអង្គដែលតែងមិនគិតពីចំណាយព្រះរាជទ្រព្យផ្ទាល់ ដើម្បីជាជំនួយដល់ការអភិវឌ្ឍន៍នៃវិស័យអប់រំ និង ការរស់ឡើងវិញនៃវប្បធម៌ជាតិ ។

សូមព្រះអង្គទ្រង់បរិបូណ៌ដោយពរទាំងឡាយប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ភ្នំពេញ ថ្ងៃទី ៥ ខែធ្នូ ព.ស. ២៥៥១

ធន់ ហ៊ិន

# មាតិការឿង

| លរ | ចំណងជើង | ទំព័រ |
|---|---|---|
| ១. | បុព្វកថា | ក |
| ២. | ច្បាប់ពាក្យស្លោក (បទកាកគតិ) | ១ |
| ៣. | ច្បាប់ព្រះធម្មៈ (បទបន្ទោលកាក) | ១៦ |
| ៤. | ច្បាប់ព្រះធម្មៈ (តនិងចប់), (បទពាក្យ ៩) | ២១ |
| ៥. | ច្បាប់ព្រះវិទូរ (បទកាកគតិ) | ២៧ |
| ៦. | ច្បាប់ព្រះវិទូរ (តចប់), (បទព្រហ្មគីតិ) | ៣៩ |
| ៧. | ច្បាប់ព្រះក្រឹស្នា (បទពាក្យ៧) | ៥៩ |
| ៨. | ច្បាប់ព្រះក្រឹស្នា (ត), (បទកាកគតិ) | ៧២ |
| ៩. | ច្បាប់ព្រះក្រឹស្នា (តនិងចប់), (បទព្រហ្មគីតិ) | ៨០ |
| ១០. | ច្បាប់ព្រះភីស្មៈ (បទពាក្យ៧) | ៨៧ |
| ១១. | ច្បាប់ព្រះភីស្មៈ (ត), (បទកាកគតិ) | ១០១ |
| ១២. | ច្បាប់ព្រះភីស្មៈ (ត), (បទពាក្យ៨) | ១១១ |
| ១៣. | ច្បាប់ព្រះភីស្មៈ (តនិងចប់), (បទភុជង្គលីលា) | ១១៧ |
| ១៤. | ច្បាប់ព្រះរាជាខ្មែរ (បទពាក្យ៧) | ១២២ |
| ១៥. | យុគ (បទកាកគតិ) | ១២៨ |
| ១៦. | កលិយុគ (បទពាក្យ៧) | ១៣៤ |
| ១៧. | អប្រ៊ិត (បទពាក្យ៧) | ១៣៨ |
| ១៨. | សទ្ទានុក្រម (ខ្មែរ-អង់គ្លេស) | ១៤៤ |

# បុព្វកថា

## បទកាកគតិ

សូមលើកករផ្គង់ លំអុតឱនអង្គ ក្រាបថ្វាយបង្គំ
ព្រះរតនត្រៃ ផ្កាផ្លែឧត្តម ជាម្លប់ដ៏ធំ
ដែលប្រក់ព្រំលោក ។

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃបវរ ទ្រង់មានជ័យជោគ
តែងបង្ហាញផ្លូវ ដល់សព្វសត្វលោក ឱ្យរួចផុតរោគ
នរកលោកិយ ។

សូមថ្វាយបង្គំ ព្រះព្រហ្មជាធំ ព្រះឥន្ទកោសិយ
ហរិ-ហរៈ សិវៈ លក្ស្មី ព្រះទេវីស្រី
ជាទីសក្ការ ។

ខ្ញុំសូមក្រាបថ្វាយ- បង្គំដោយកាយ ទាំងចិត្តវាចា
ដ៏ស្មោះចំពោះ ព្រះអង្គក្រីស្នា ជាព្រះបិតា
លោកសន្និវាស ។

ជាលោកចក្ខុ ហាក់ដូចវត្ថុ ជ្រួតជ្រាបពេញពាស
សព្វរស់មិនរើ ពេកបរិនាស ទ្រង់បានយាងយោស
ចុះជាអវតារ ។

ទ្រង់បានកសាង ជាព្រះតំណាង ព្រះបិតាមហា
ផ្លូវរស់ពុទ្ធិ អភិសមាចារ ទុកឱ្យមនុស្សា
រកឃើញផាសុ ។

ខ្ញុំរំឭកគុណ សែនធ្ងន់លើសលន់ នៃព្រះវិស្ណុ
នារាយណ៍ គណេស ព្រះឥន្ទ្រាកុ និងព្រះប្រ៊ហ្មុ
មហាក្សត្រលោកា ។

សូមទេពនិករ ទាំងទេពអប្សរ លើអាកាសា
យមៈ វេស្សវ័ណ ព្រះរាម សីតា និងព្រះសង្ការ
ប្រទានបារមី ។

អញ្ជលីប្រណម្យ ក្រាបថ្វាយបង្គំ ព្រះនរបតី
ជាព្រះបិតា រាស្ត្រនិងមន្ត្រី សូមទ្រង់ប្រណី
ប្រោសប្រាណកូនចៅ ។

សូមរំឭកគុណ ដ៏ធ្ងន់លើសលន់ ពីគុណម៉ែឪ
មិត្តាជិដូន បងប្អូនញាតិផៅ ដែលតែងប្រដៅ
និងបីបាច់ខ្ញុំ ។

រំឭកគុណគ្រូ លោកជាវិញ្ញូ- ជនដែលខិតខំ
ផ្តល់នូវចំណេះ វិជ្ជាស្អាតស្អំ ដោយអប់រំខ្ញុំ
ឱ្យផុតល្ងង់ខ្លៅ ។

សូមគោរពចារចែង សារស័ព្ទសម្តែង សប្តីសំដៅ
ផងកាព្យជាច្បាប់ សម្រាប់កូនចៅ តពូជពង្សផៅ
នៅគ្រប់ជំនាន់ ។

ខ្ញុំផ្តើមចងកាព្យ ក្នុងដើមខែស្រាពណ៍ ព.ស. ពីរពាន់
ប្រាំរយហាសិប ទុកជាគ្រប់គ្រាន់ គ.ស. ពីរពាន់
ប្រាំមួយនោះឯង ។

ក្នុងសង្គមខ្មែរ យើងមានហូរហែ នូវច្បាប់គាក់តែង
ឱ្យបុត្រធីតា សិក្សាស្តាប់ស្តែង បានភ្លឺចិត្តវែង
ដូចសែងសុរិយា ។

ជាអាទិ៍ដូចជា ព្រះរាជសម្ភារ បណ្តាំបិតា
កេរកាលច្បាប់ប្រុស ច្បាប់ស្រីហែមហា[1] ភិរម្យភាសា
សព្វសែនពីរោះ ។

ច្បាប់ប្រពន្ធប្តី[2] ក្បួនលក្ខណៈស្រ្តី[3] ជាស្នាព្រះហស្ត
ព្រះបរិវក្ស ឥស្សរា[4] ទ្រង់យស មេកាព្យ[5] ច្បាប់ឈ្មោះ
វិចូរបណ្ឌិត ។

ជាគតិរឿងព្រេង ចារជាប់ទន្ទេង នៅលើស្លឹករឹត
ពាក្យរាយពាក្យកាព្យ ពេញដោយគំនិត គតិបណ្ឌិត
ពិតពេញនិយម ។

ពាក្យកាព្យទូន្មាន ដូចបានប្រិតប្រៀន សម្រាប់អប់រំ
ក្នុងសៀវភៅនេះ ជាការប្រមូល ក្បួនសែនអភិរម
តាមព្រេងនិទាន ។

ផ្ដុំនឹងការចាំ ចេះច្បាប់បណ្ដាំ និងតាមការរៀន
ទស្សនវិជ្ជា ក្នុងក្តីស្រុកឃ្លាន បំពេញអភិញ្ញាណ
ដោយន័យខ្លឹមសារ ។

---

១ ច្បាប់ហែមហាជន ។ ២. មើលវចនានុក្រមខ្មែរ ទំព័រ ៦៣៦ និង ៦៥៥ ។ ៣. មើលសៀវភៅ "កម្រងកំណាព្យបុរាណ" ។ ៤. ព្រះបរិវក្ស ឥស្សរាធិបតី ឬ ព្រះបាទអង្គឌួង (១៨៤១-១៨៥៩) ។ ៥. សៀវភៅ "មេកាព្យ" ចងក្រងដោយលោក រៀង សាយ ។

អានអក្សរសាស្ត្រ រឿងព្រេងខ្លះៗ ពិសមាចារ
រួចទើបសម្រេច ចិត្តចងអក្ខរា តាមក្បួនវោហារ-
សព្ទនៃពាក្យកាព្យ ។

ពាក្យទូន្មានខ្លះ ជាស្លោកចាស់ៗ មិនចេះសូន្យសាប
ន័យនៅល្អល្អះ ច្បាស់រៀងដរាប សម្រាប់បង្ក្រាប
អារម្មណ៍ហិង្សា ។

រឿងល្អគ្រកាល ដែលបានបណ្ដាល ឱ្យខ្ញុំប្ដេជ្ញា
ស្វែងយល់អត្ថរស ក្នុងវីរកថា មានឈ្មោះថាមហា-
ភារតៈហោង ។

ដែលបានផ្ដួចផ្ដល់ ផ្ដើមជាយោបល់ ឱ្យខ្ញុំតែងក្រង
ច្បាប់ព្រះធម្មៈ ព្រះពិទូរផង ន័យល្អកន្លង
ច្បាប់ព្រះក្រិស្ណា ។

ច្បាប់ព្រះភីស្មៈ ប្រសើរប្រពន្ធក្ស រាជធម៌ខេមរា
សម្រាប់មហាក្សត្រិយ៍ ក៏ចាត់ចែងចារ សង្ខេបវោហារ
ឱ្យនៅថេរឋិត ។

ដោយឡែកពីនេះ ខ្ញុំបានត្រិះរិះ តាមការពេញចិត្ត
ចងក្រងពីយុគ តាមន័យលម្អិត និងរឿងអប្រិយ
សមុទ្រទឹកដោះ ។

ច្បាប់កាព្យទាំងឡាយ ដូចមានបរិយាយ តទៅទាំងអស់
ហាក់ដូចរុក្ខា លូតលាស់យ៉ាងស្រស់ ឬជាកេរកោះ
សម្រាប់សង្គម ។

មិនអាចចាត់ថា ជាច្បាប់សាសនា ព្រះពុទ្ធព្រះព្រហ្ម
ឬថាជាការ បម្រើមនោគម- វិជ្ជានិយម
នាំឱ្យធុញថប់ ។

សុទ្ធតែទាក់ទង នឹងកិច្ចគ្រប់គ្រង ការភពប្រសព្វ-
គ្នាក្នុងសង្គម គ្មានទីបញ្ចប់ ព្រោះមានបង្កប់
ន័យល្អលើសលន់ ។

ច្បាប់នេះក្រក្រៃ គតបីឧបមេយ្យ គួរទុកជាគុណ
បើមិនចេះសោះ ជាកំហុសធ្ងន់ ដូចអនក្ខរជន
ក្នុងសង្គមមនុស្ស ។

លោកយល់ច្បាស់ថា អភិសមាចារ ជាទ្រព្យខ្ពង់ខ្ពស់
អាចជួយនរជន ឱ្យថ្កើងកិត្តិយស នៅសព្វទិសទស
ជាមនុស្សទេវា ។

រីគោលបំណង ដ៏ធំចម្បង នៃអស់កាព្យា
គឺក្រមសីលធម៌ នៃជនគ្រប់គ្នា សម្រាប់ឱ្យវៀរ
ចាកក្ដីខ្លោចផ្សា ។

បញ្ហាសង្គម ទោះបីតូចធំ តែងកើតហេតុការណ៍
ពី **អយុត្តិធម៌** ជាធម៌ឥតសារ នាំភាពអន្ធការ
ឱ្យមកគ្រប់ព្រង ។

ដូច្នេះគួរជ្រាប ថាធម៌ថោកទាប នាំឱ្យខុសឆ្គង
ត្រូវតែកម្ទេច កៀសគេចរំលង រំលើងដើមទង
នៃទិសអវិជ្ជា ។

ខ្ញុំបានចំណាយ កម្លាំងចិត្តកាយ ប្រាជ្ញាវេលា
ប្រឹងចងពាក្យពេចន៍ ឱ្យកើតឃ្លោងឃ្លា ជូនវណ្ណគ្គា
មិនមានឱ្យខ្ចោះ ។

បើមានឆ្គាំឆ្គង លើសលស់រំលង ឬមានចន្លោះ
ប្រការណាមួយ សូមជួយដោយស្មោះ សម្រួលឱ្យអស់
កុំមើលបំណាំ ។

កាព្យទាំងនេះណា កូនគួរសិក្សា ទុកជាបណ្តាំ
ជាមិត្តស្នេហា ជាចម្ការផ្សាំ ឬដូចជាថ្នាំ
សម្រាប់ព្យាបាល ។

កុលបុត្រខេមរា រៀងរាល់អាត្មា ជួរជាំឱ្យដាល-
ដុះសព្វចំណេះ ពិសេសពិសាល សម្រាប់ជាថ្នាល
សាបព្រោះពូជធារ ។

អាយុ វណ្ណៈ សុខៈ ពលៈ ពុទ្ធពរជយា
ទាំងបួនល្អមច- ម្រើនដល់ប្រជា- រាស្ត្រខ្មែរគ្រប់គ្នា
ជារៀងដរាប ។

ក្រុងប៉ារីស្ស ថ្ងៃអាទិត្យ ទី ២៩ ខែតុលា ព.ស. ២៥៥០. គ.ស. ២០០៦
(ក្នុងពេលបំពេញបេសកកម្មការទូត : តុលា ២០០៤-កញ្ញា ២០០៧)

**ធន់ ហ៊ិន**

អតីតសាស្ត្រាចារ្យ ម.ស.ប.ភ. ភាសាបារាំង

# ច្បាប់ពាក្យស្លោក

បទកាកគតិ

បពិត្រព្រះអង្គ សូមទ្រង់ផ្ចិតផ្ចង់ ព្រះកាណ៌សណ្តាប់
ន័យនៃពាក្យស្លោក លោកចងជាច្បាប់ តាមវោហារសព្ទ
ទុកយ៉ាងនេះថា ។

ជំហរដូចសិង្ហ បើនឹងសម្លឹង បីដូចសត្វខ្លា
សំឡេងបន្លឺ លាន់ឮឡើងស្នា សោតងនេត្រា
ដូចភ្នែកមាន់ព្រៃ ។

បុរាណោបានចាត់ លក្ខណសម្បត្តិ នេះថាប្រពៃ
ជាឧត្តមជន មានបុណ្យបារមី គបដោយសិរី -
សួស្តីគ្រប់យ៉ាង ។

នេះជាលក្ខណៈ ប្រសើរប្រត្យក្ស និងជាតិកតាង
នៃអ្នកខ្ពង់ខ្ពស់ ដោយយសសំណាង ដូចបានកសាង
បុណ្យទុកពីនាយ ។

លុះដល់ជាតិនេះ គេក៏អាចបេះ យកផលដោយងាយ
ប្រយោជន៍តូចធំ កុសលសម្លាយ ទាំងក្តីរីករាយ
ហូរចូលគរគោក ។

ពាមពុទ្ធឱវាទ ថែងជាក្បួនខ្នាត ថាមនុស្សក្នុងលោក
មានបួនសណ្ឋាន ខ្លះមានជ័យជោគ ខ្លះចិត្តស្មោគគ្រោក
ទៅតាមកម្មផល ។

មនុស្សមនុស្សោ មនុស្សទេវោ ដាបដោយកុសល
ស្មេហ៍យុត្តិធម៌ សុចរិតជិតដល់ អំពើអំពល់
អំពីសច្ចភាព ។

កិរិយាឧត្តម សម្តីគួរសម រម្យទមរាបទាប
ចិន្តាសប្បុរស ស្ម័គ្រស្មោះសុភាព រស់មានរបៀប
ស្គាល់ខុសនិងត្រូវ ។

មនុស្សបេតោ មនុស្សតិរច្ឆានោ តែងនាំអាស្រូវ
សម្តីអសុរោះ យកខុសជាត្រូវ អាក្រក់ពេកកូវ
សែនថោកអាត្មា ។

យល់ខ្មៅថា ស អាក្រក់ថា ល្អ លាមកថាផ្កា
ចិត្តជាអន្ធពាល យល់ថាជ្រះថ្លា ខ្លួនខ្មៅពេកសោរ
យល់ថាចំណាប់ ។

ខ្មៅងឹតអវិជ្ជា ទោះរស់នៅនា ក៏ដូចមនុស្សស្លាប់
ឥតយសសក្តា ឥតសារឥតសព្ទ បណ្ឌិតលោកប្រាប់
ឱ្យឆាប់ស្មារលា ។

ជើងទេញធ្មេញល្អិត ត្រចៀកកំប៉ិត ក្បាលកំពែងខ្សៀ
ឬក្បាលផ្លូវខ្មោច អសោចដូចគ្នា ចិត្តមិនដែលជា
ក្រាស់ដោយកម្រោល ។

ជើងទេញធ្មេញល្អិត ត្រចៀកកំប៉ិត ដំណើរប៉ែលប៉ោល
ជាជនអប្រិយ ច្រើនស្តីដេញដោល ឃើញត្រឹមស្រមោល
ពោលចោលគ្នីគ្នា ។

វីជនទាំងបី នេះមិនមានអ្វី សមសួនសោភា
ចិត្តមិនសុចរិត ប្រព្រឹត្តពាលា បំពានបំពារ
មិនថាតែឯង ។

មនុស្សមាត់ដូចសេះ ច្រើនអន់ចំណេះ មិនចេះចាត់ចែង
អាក្រក់ជូជាតិ ឥតគិតកោតក្រែង មារយាទនោះឯង
សែនថោកពេកក្រៃ ។

បណ្ឌិតពោលថា មនុស្សបែបនេះណា មិនអាចកែច្នៃ
ត្រូវវៀរចាកចេញ ដូចដេញចង្រៃ ឱ្យស្រឡះដៃ
កុំបីធ្វេសទេ ។

លោកថាចេះឯង ឱ្យគិតកោតក្រែង រអែងចេះគេ
មិនមានតែខ្លួន មាំមួននុះទេ ទាំងយើងទាំងគេ
តោងទៅទាំងសង ។

មួយសោតចេះឯង នឹងដាច់សង្វែង ពីច្បាប់ច្បាស់ច្បង
ចេះឯងជូនឱ្យ ខុសឆ្ងាយកន្លង ពីក្រឹត្យក្រមផង
ដូចភ្នែកខ្វាក់ម្ខាង ។

តោងរៀនមានគ្រូ ជាជនវិញ្ញូ ជួយជាតួយ៉ាង
អនុវត្តខ្ជាប់ខ្ជួន យកក្បួនជាតាង ទើបភព្វសំណាង
ជួយសាងកិត្តិយស ។

លោកថាទោះបី ទៅទីណាក្តី ក៏គង់ខ្ពង់ខ្ពស់
ពេបីសាបសូន្យ ឈ្មោះនៅតែរស់ រស់នៅចំពោះ
មុខមនុស្សគ្រប់គ្នា ។

ជនមួយអន្ធពាល ចិត្តក្តៅរោលរាល រៀងរាល់វេលា
លោកឱ្យវៀរចាក កុំយកជាគ្នា នាំខូចសាមគ្គា
វេទនាសោកសៅ ។

គឺជនអសោច ដែលរុញឱ្យខ្លោច ឬរោចឱ្យឆៅ
ចិត្តអន្យតិរ្ថិយ ឈាមខ្មៅថ្លើមខ្មៅ សម្តីសំដៅ
ច្រើនច្រឡោងខាម ។

ជាមនុស្សចង្រៃ មិនមានតម្លៃ បុរាណតែងហាម
មិនឱ្យសេពគប់ ឱ្យឈប់ដើរតាម ឱ្យជួយប្រាប់ប្រាម
ថាត្រូវខ្លាចក្រែង ។

អវិជ្ជាតែងអួត ហាក់ដូចមនុស្សឆ្កួត មិនរវីរួសរង
ពានពេកព្យាការ រឹងរឹតខែងរឹង ឫកពានោះតែង
ទើរទើសភាកាគ ។

ខ្លៅនិងអវិជ្ជា ចិត្តស្រាលដូចគ្នា គឺរើងរឹងក្រាស់
ស្តីមិនពីរោះ មោះមិនរៀនខ្ពាស និយាយផ្តេសផ្តាស
គិតថាគ្រាន់បើ ។

ពាលពេញមោហា តែងធ្វើសក្ការ ពាក្យពោលសរសើរ
ពាក្យពោលទិតៀន ក្នុងន័យស្មោះស្មើ យល់ជាដំណើរ
នៃភាពឱនអាប់ ។

ព្រះពុទ្ធថាបើ គេពោលសរសើរ ដូចគេសម្លាប់
បើគេទិតៀន បន្ទុះបង្គាប់ ព្រះអង្គប្រញ្ញប្តិ៍
ថាគេឱ្យពរ ។

ចំពោះបណ្ឌិត លោកតែងគួរគិត ថាជាគុណធម៌
ដែលត្រូវទទួល យកទាំងសាទរ ក្នុងក្ដីស្មោះសរ
ព្ធានចិត្តរឹង ។

ប្រាជ្ញប្រាយប្រាប់ថា កុំឱ្យអ្នកណា មិនចេះថ្លែងថ្លឹង
យកចានពែងកែវ ទៅលាងទាំងខឹង របស់នោះនឹង
ឆែបស្លូងបែកបាក់ ។

កុំឱ្យអ្នកណា ដែលឃ្លានអាហារ វាល់អង្ករដាក់
ដណ្ដាំបាយឆី ព្រោះឃ្លានដូចខ្លាក់ ឱ្យវាវាល់ដាក់
នឹងឫសទម្លាប់ ។

លោកហាមប្រាមថា កុំឱ្យមនុស្សណា ជាអ្នកក្រទ្រព្យ
យៀងធ្វើអ្នកធំ ព្រោះនាំរភ័ព្វ មិនគួរមិនគាប់
វាលួចមិនលែង ។

ពុលនឹងលុយកាក់ ពុលនឹងបុណ្យសក្តិ លើសពុលនឹងល្បែង
ពុលនឹងស្រីញី ពុលនេះវាតែង ឱ្យហិនឯង១
ហៅសែនចង្រៃ ។

ពុលនេះហៅមហា សែនអមនុស្សា ឈានទៅព្រៃផ្សៃ
កើតចិត្តជាចោរ មោហោពេកក្រៃ រកពាក្យឧបមេយ្យ
ឧបមាមិនបាន ។

វៀរលោភលន់ តែងមិនគិតគន់ គេឯងជាថ្នាន
ព្រោះជាពូជពង្ស ត្រកូលសាមាន្យ ចិត្តចោរតិរច្ឆាន
គិតតែខ្លួនឯង ។

លោភលន់ដូចខ្លាក់ ពាក់ព័ន្ធលុយកាក់ កុំឱ្យចាត់ចែង
ដ្បិតចិត្តលោភលន់ វាលួចមិនលែង ផ្កាប់តែចិត្តឯង
ឱ្យបានរីករាយ ។

ទ្រព្យលួចប្លន់ បើយកធ្វើបុណ្យ ធ្វើគុណហោសម្ពាយ
តាមក្បួនតម្រា ចារទុកពីនាយ មិនអាចរំលាយ
បាបកម្មបានឡើយ ។

សម្បត្តិធនទ្រព្យ ដែលប្រសើរតាប់ គួរជាត្រាណត្រើយ
គឺទ្រព្យបានដោយ សុចរិតនោះហើយ ទើបល្អឥតស្បើយ
បុណ្យចូលហូរហែ ។

បុរាណពោលថា លុយអលង្ការ អាចទិញស្រីស្នេហ៍
តែស្នេហាពិត មិត្តឥតប្រួលប្រែ មិនអាចឱ្យគេ
យកលុយទិញបាន ។

អាចទិញបុណ្យសក្តិ សញ្ញាបត្រថ្នាក់ ខ្ពស់បួសប្រមាណ
តែក្តីគោរព វិជ្ជាជាត្រាណ កិត្តិយសថ្កើងថ្កាន
ទិញមិនបានទេ ។

លុយកាក់ប្រាក់មាស វាជាក់ជាទាស- ករល្អលើសគេ
តែអាចជាគ្រូ ម្នាក់អាក្រក់ទ្វេ ព្រោះអាចជាមេ
នៃអភិជ្ឈា ។

គឺអាចបណ្តោយ ខ្លៅអវិជ្ជាឱ្យ លោភលន់ពាលា
ទាំងកើតទោសៈ បែកបាក់សាមគ្គា ហ៊ានសម្លាប់គ្នា
មិនក្រែងបាបកម្ម ។

បើឃើញគ្នាខ្សោយ មិនត្រូវបណ្ដោយ ទុកមើលបំណាំ
បំណោចគ្នាខ្សោយ ចូរជួយផ្សំផ្សាំ នេះជាបណ្ដាំ
នៃសាមគ្គីភាព ។

កុំកាន់ឫកឆ្មើង តាមចិត្តរើសអើង ថាគ្មានគូប្រៀប
ឃើញខ្លួនឯងខ្ពស់ គេនោះថោកទាប ឃើញខុសរបៀប
នៃធម៌បុរាណ ។

អ្នកខ្លាំងជាងត្រូវ ធ្វើដូចសំពៅ ពឹងពាក់សំប៉ាន
មានត្រូវជួយក្រ ទៅតាមលម្អាន បីដូចខ្លួនប្រាណ
ព័ទ្ធដោយសំពត់ ។

ប្តូតាអ្នកប្រាជ្ញ មិនដែលកោងកាច តែចិត្តមុះមុត
ជួយអ្នកល្ងង់ ឱ្យចេះប្រយុទ្ធ ផុតភាពទុគ៌ត
នៃការចេះដឹង ។

បើឃើញតែទោសគេ តែទោសឯងទេ មិនគិតគួរប្រឹង
បើលេឱ្យឃើញសិន គិតតែសម្លឹង ផ្សំដោយកំហឹង
គ្មានចិត្តត្រង់ស្មោះ ។

ព្រោះជាស្ពាន ជាទ្រព្យធនធាន ល្អសព្វលើសអស់
សម្បត្តិសម្បើម សម្បូរណ៍កេរកោះ នៅក្នុងអម្រស់
ប្រចាំជីវិត ។

បើធ្វើជាមេ ហើយល្ងង់ជាងគេ នឹងលង់គំនិត
ព្រោះមិនអាចវាស់ វែងនូវការពិត ទាំងអាចកើតចិត្ត
ស្អប់អ្នកចេះជាង ។

ត្រូវប្រព្រឹត្តល្អ   តាមវិធីកុលធម៌   ឈ្មោះសរសើរល្បើង
ទើបបានជាមនុស្ស   ខ្ពង់ខ្ពស់ទាត់ទៀង   កេរ្តិ៍ឈ្មោះរស់រៀង
រាប់ជាអរិយៈ ។

ត្រូវសាងសាមគ្គី   ឱ្យមិត្តមូលមីរ   យកចិត្តទុកដាក់
ទោះជិតឬឆ្ងាយ   រួសរាយរាក់ទាក់   កោកាចមិនពាក់
ដូចចង្កឹះមួយបាច់ ។

ចង់ឱ្យគេគោរព   មិនត្រូវច្រឡោត   ពោលពាក្យដាច់សាច់
សម្ដីផ្អែមល្ហែម   ជាពោលចាំបាច់   កុំប្រើរង្គាក់
តាមចិត្តគុំស្អប់ ។

សត្វលោកៈនៃមេ   គឺកិរិយាស្ដីជេរ   ឱ្យគេធុញថប់
ម្ដេចតាធ្វើបែ   ត្រូវធ្វើក្បាន់សព្វ   ការខុសមិនគាប់
ត្រូវឆាប់ណែនាំ ។

បក្សីទាបតូច   តែងតែធ្វើខូច   ធ្វើខុសជាចម្ប-
តា ល្ងៀតមិនផុត   ត្រូវពត់ពេលដំ   បើមិនទាន់ស៊ាំ
ត្រូវណែនាំគ្នា ។

ទោះហៅថាមេ   ដូចម៉ែឪគេ   ត្រូវពិតឱ្យជា
កុំឱ្យដូចមនុស្ស   ទុឃិសពាលា   ចង់តែបំពារ
បំពានគេឯង ។

កុំធ្វើឱ្យល្អក់   តាមពុតអាក្រក់   តែត្រូវគិតក្រែង
ថាការអប់រំ   អាចឱ្យចិញ្ញែង   ចិញ្ចាចជាត់ស្ដែង
កបកាយកិរិយា ។

ឬតាសព្វផ្លែ ដែលម្ចាស់ឱ្យថែ បន្លែក្នុងច្បារ
ទោះស៊ីមិនកើត ក៏វាបង្ការ មិនឱ្យអ្នកណា
ផ្សេងចូលបោចបេះ ។

បន្លែនេះណា អ្នកប្រាជ្ញចង់ថា មនុស្សខ្លះមិនខ្មេះ
តែប្រឹងខាឃាំង ដ្បិតចិត្តឈ្នានីស ខ្លាចក្រែងអ្នកចេះ
មានកិត្តិយសជាង ។

ផ្លែព្រះមិនខាំ ផ្ដូរតពាក់តតាំ មិនដែលមានភ្លៀង
បន្លែមួយនេះ ត្រូវរិះដោយទៀង តាមន័យមិនល្មៀង
ពីលោកចង់ថា ។

កំណោច់ធ្វើមនុស្ស ត្រូវលើកកម្ពស់ កិត្តិយសអាត្មា
តាមការអនុវត្ត នូវពាក្យសន្យា បើក្បត់វាចា
នឹងបាត់សូស្ដី ។

តាមន័យឧបមា ផ្សេងពីចង់ថា មានជនអប្រិយ
ខ្លះតែងស្រែករូត ប្រកួតសម្ដី គ្រាន់តែដើម្បី
ពោកប្រាស់តែឯង ។

អ្នកខ្លះទៀតសោត ចង់ឱ្យគេកោត ក៏ខំខ្លះខ្នែង
ផ្ទុះឆ្មៀលដូចឆ្កួត ស្រែករូតក្ដែងៗ ដើម្បីជាល្បែង
ពោកប្រាស់មួយក្ដារ ។

កើតជាមនុស្សលោក មិនអាចមានជោគ- ជ័យលើវាចា
ណោមិនសុចរិត អាប់ឥតខ្លឹមសារ សែនថោកកិរិយា
ការក្បត់សម្ដី ។

ក្នុងចឹងហើបហោ មាត់ពោលស្ដីថា គួរគិតវែងខ្លី
តាមការថ្លឹងថ្លែង ឱ្យច្បាស់ដោយន័យ រួចសឹមចេញស្ដី
ទើបប្រសើរគាប់ ។

ដូចពាក្យស្លោកមួយ គួរទុកជាត្រួយ ជាពន្លកទ្រព្យ
ឱ្យទៅស្ថិតស្ថេរ ជាកេរគួរគាប់ ព្រោះជាញឹកញាប់
យើងតែងត្រូវការ ។

ជាការល្អក្ដាត់ សម្ដីមួយម៉ាត់ បណ្ឌិតចែងថា
ឱ្យពិតមួយម៉ោង សឹមឱ្យជិវ្ហា បញ្ចេញស័ព្ទសារ
ឱ្យគេឯងស្ដាប់ ។

នេះបានន័យថា ការពិចារណា ប្រាជ្ញាជាច្បាប់
ជាគោលត្រូវ ដើរតាមលំដាប់ និងត្រូវត្រង់គ្រាប់
ឱ្យត្រង់កន្លង ។

ស្លោកមួយទៀតថា ត្រូវឱ្យជិវ្ហា របស់យើងផង
គន្លាស់គ្រលៀស គ្រប់ប្រាំពីរដង រួចហើយសឹមសាសង
ស្ដីឱ្យគេស្ដាប់ ។[1]

បន្ទូលនេះណា ក៏មានន័យថា តាមការរាយរ៉ាប់
ដូចគ្មានឹងន័យ ខាងលើនេះស្រាប់ ចូរចាំជាច្បាប់
គ្រាប់ជាប្រក្រតី ។

ពោលថាកុំខំ ស្រវាឱបក្អំ បើខ្លួនដៃខ្លី
បើខ្លួនតូចទាប កុំឈោងចាប់អ្វី ខ្ពស់ឆ្ងាយបួសដី
ឈរឈោងមិនដល់ ។

---

១. សុភាសិតបារាំង ។

ខ្លួនឯងជាមនុស្ស ឃើញដំរីជុះ តាំងគិតខ្វាយខ្វល់
ចង់ជុះឱ្យដូច ទើបចិត្តស្អប់ស្អល់ មិនគិតគួរដល់
ធម្មជាតិខ្លួនឯង ។

បើយោងតាមន័យ ជាការឧបមេយ្យ លោកចង់សម្តែង
ថាទុជ៌នខ្លះ ហេតុចង់សម្ញែង ឱ្យខ្ពស់ខ្លួនឯង
ទើបចិត្តក្រៀមក្សាន្ត ។

ទៅចងការប្រាក់ លក់ស្រែបណ្តាក់ ទិញរឺឡាឡាន
ព្រោះដៀតចិត្តព្រើល មិនប្រយោគប្រាណ មិនយូរប៉ុន្មាន
បានទុក្ខផតស្បើយ ។

ចំណេះវិជ្ជា ជាមិត្តផងគ្នា ជាគូគៀកកើយ
ជួយយើងទាំងសព្វ ចាំតបឆ្លាស់ឆ្លើយ ចំណេះជាត្រើយ
ជាទ្រព្យពិសេស ។

ប្រើច្រើនចេះច្រើន កាក់កបកើតកើន កាន់តែភ្លឺថែស
ព្យាយាមសន្សំ កុំបីប្រហែស តក់១ប៉េះ១
ទឹងពេញបំពង់ ។

អ្នកចេះដឹងពិត តែងមានគំនិត យោងយីតអ្នកល្ងង់
ពោមចិត្តអាណិត អាសូរពូជពង្ស ឱ្យផុតក្តីល្ងង់
ខ្លៅអស់ពីខ្លួន ។

អ្នកខ្លះល្ងង់ខ្លៅ គ្មានគ្រូប្រដៅ បែរជាគុំកួន
សេព្វាប់អ្នកប្រាជ្ញ ដើម្បីលើកខ្លួន ឱ្យខ្ពស់បំហួន
លើសលើមាត្រា ។

ព្រះចន្ទពេញវង់ រស្មីរឿងរុង ក្នុងហ្វូងតារា
ជាលម្អមេឃ អាកាសវេហាស៍ បីដូចវិជ្ជា
ឱ្យឫកពាល្អ ។

នៅក្នុងសង្គម ដែលត្រូវប្រក់ព្រាំ ដោយអយុត្តិធមិ
វិបត្តិតែងកើត ឡើងជាបន្ត ឱ្យចិត្តញាប់ញ័រ
ជឿព្រេងសំណាង ។

ហេតុដ្បិតខ្លៅល្ងង់ គំនិតច្រូវល់ គ្មានអ្វីជួយអាង
មើលមិនឃើញការ- ពិតជាភស្តុតាង ជឿជាក់តែខាង
ពាក្យពោលទូលពិត ។

ប្រាជ្ញមិនឈ្លះប្រប ឡេមឡឹមឡេបឡប ឯបររបយប់បិត
ត្រូវនាយអវិជ្ជា លើកជាជំនិត ទាំងឱ្យប្រព្រឹត្ត
ពាលពេតពិតក្រែង ។

ជនជាបណ្ឌិត ប្រសើរពិតៗ មិនដែលសម្តែង
កិរិយាឆ្លើយតប អបអ្នកប្រើល្បែង ប្រចុបប្រចែង
ព្រោះស្វែងរកលាភ ។

ត្រូវចាំឱ្យខ្ជាប់ ថារឿងសាច់គាប់ ជាធមិថោកទាប
ជាកលល្បិចក្បត់ ជាខ្នោះឃ្នាងឃ្នាប ប្រាជ្ញតែងប្រុងប្រៀប
រៀបខ្លួនចេញឆ្ងាយ ។

ត្រូវលើកសាច់ការ ឱ្យខ្ពស់ថ្លៃថ្លា ទើបនាយកបកាយ
កបចិត្តអារម្មណ៍ ចៀសផុតអន្តរាយ កើតក្តីសប្បាយ
តត្រឹកតត្រេង ។

ចំណេះវិជ្ជា នាំមនុស្សផងគ្នា ឱ្យបាត់វង្វេង
ឱ្យយល់ភាក់ជ្រៅ អារម្មណ៍ទន្ទេង ដូចទឹកថ្លាឈ្វេង
ឥតបីប្រួលប្រែ ។

កុំរៀនរើសអើង កុំកាន់ឫកឆ្មើង ពូជយើងជាខ្មែរ
កុំភ្លេចកំណើត ដូនតាឪម៉ែ ទោះក្រុងឬស្រែ
ត្រូវថែវង្សា ។

អ្នកភ្លេចកំណើត យល់ខ្លួនល្អឆើត វាយឫកសង្ហា
អាងមានធនទ្រព្យ ច្រើនពាប់ចិន្ដា រូចក្បត់វាចា
កាលគ្រាសោកសៅ ។

នេះប្រាជ្ញលោកប្រាប់ ថាមិនត្រូវគ្រាប់ ពូជមេអំបៅ
ដូចមាននិទាន ទុកប្រៀនប្រដៅ អស់ទាំងកូនចៅ
ឱ្យល្អសោភា ។

ការមេអំបៅ មួយហើរ១ទៅ ក៏លោជួបជា
ទំលំពដង្កូវ មួយកំពុងវារ ទប់ខ្លួនវេរា
វាវកចំណី ។

មេអំបៅថា រូបឯងនេះមហា អាក្រក់ឥតបី
គួរឱ្យខ្ពើមពេក ដូចជន្លេនដី ឥតមានឃើញអ្វី
ល្អដូចខ្លួនអញ ។

ស្លាបអញត្រដាង ពណ៌ស្មើសងខាង ល្អស្រស់សស្រាញ់
បុប្ផាលើកត្បូង ក៏អញមិនចាញ់ គេតែងស្រឡាញ់
ចាប់ចិត្តចង់បាន ។

មើលទៅរូបឯង   គ្មានអ្វីឱ្យស្វែង   នាមជាតិរច្ឆាន
បើឃើញឯង គេ   ចៀសឆ្ងាយពីឋាន   តែគេចង់បាន
រូបអញល្អឆើត ។

ដង្កូវឆ្លើយថា   សូមលោកមេត្តា   កុំភ្លេចកំណើត
កាលល្អប៉ុណ្ណឹង   កុំប្រឹងចំអើត   ភ្លេចថាខ្លួនកើត
ចេញពីដង្កូវ ។

ឬរឿងនិទាន   មួយទៀតដូចមាន   មកដល់ឥឡូវ
ពីក្សត្រិយ៍មួយអង្គ   គ្រងរាជ្យត្រឹមត្រូវ   ល្អល្អះពេកគួរ
ជាសេចក្ដីថា ។

ថ្ងៃមួយមហាក្សត្រិយ៍   ទ្រង់ត្រាស់ឱ្យចាត់-   ចែងតៀងព្រះយោ
ដើម្បីអញ្ជើញ   អគ្គសេនា   ចូលរួមពិសា
ជាមួយព្រះអង្គ ។

ព្រះស្ងោយឆ្ងាញ់ៗ   រើសតាមស្រឡាញ់   ក្នុងចានបញ្ចរង្គ
តែសេនាឆ្ងល់   ក៏សួរព្រះអង្គ   ពីហេតុដែលទ្រង់
មិនមាននំប៉័ង ។

ព្រះអង្គត្រាស់ថា   នែ! លោកសេនា   ខ្ញុំមិនលាក់បាំង
ដែលខ្ញុំមិនឱ្យ   បម្រើនំប៉័ង   ព្រោះខ្ញុំប្រឆាំង
នឹងកិរិយាលោក ។

នំប៉័ងសំណព្វ   ចិត្តយើងទាំងសព្វ   នំនែកគរគោក
សុទ្ធតែកើតពី   ស្រូវអង្ករមក   ដែលជាជម្រក
នៃជីវិតយើង ។

អើ! លោកសេនា រឿងស្រេចម្ការ លោកត្រូវតម្កើង
ស្នេហាអ្នកស្រែ អ្នកចម្ការឡើង ចូរលែងរើសអើង
ស្អប់កសិករ ។

នេះឯងមូលហេតុ មួយច្បាស់ក្រឡែត សូមលោកអបអរ
ឯងជូនតាលោក ក៏ជាកសិករ ពោលតីសសរ
ទ្រូងទ្រសេដ្ឋកិច្ច ។

សូមលោកសេនា កាន់ចិត្តជ្រះថ្លា កុំក្បិលកុំក្តិច
មេត្តាករុណា ជាករណីយកិច្ច កុំបីភ្លាំងភ្លេច
ភ្លាត់មួយវេលា ។[១]

ដូច្នេះត្រូវយល់ អ្វីជាឫសគល់ នៃពៀរវេរា
ដែលជាសត្រូវ គឺខ្មៅអវិជ្ជា ព្រោះជាមាតា
នាំទៅអន្តរាយ ។

អ្វីជាអកុសល ត្រូវយល់ឱ្យដល់ វាងវៀរឱ្យឆ្ងាយ
កាន់ធម៌សប្បុរស កុំបីនឿយណាយ ល្អទាំងចិត្តកាយ
ទាំងសព្វវាចា ។

ជម្រះចិត្តពាល ចិត្តខ្មៅរោលរាល នាំឱ្យខ្លោចផ្សា
បែកបាក់សាមគ្គី ដូចបង់គ្រួសារ បីដូចមាត់ហា
ហៅបរាជ័យ ។

៚

---

១. រឿងនេះមានតំណាលក្នុងអក្សរសាស្ត្របារាំង ។

# ច្បាប់ព្រះធម្មៈ

## បទពំនោល

ពេលសម្រាកក្រោមម្លប់ជ្រៃ យុធិស្ឋិរស្ដី ទៅកាន់សហទេពថា ។
ចូរប្អូនទៅរកទឹកថ្លា នៅទីណា១ សោយហើយខ្ចប់មកផងណា ។
អ្នកពេញជាស្រេកតង្ហា តែចង់នៅនា សម្រាកយកម្លាំងកាយ ។
សហទេពយាងរៀងរាយ ទៅទៅមិនឆ្ងាយ ឃើញទីមួយគួរសប្បាយ ។
ថាអាចមានទឹកថ្លាក្រៃ ទ្រង់យាងត្រៀវត្រៃ ទៅតាមព្រះរាជបញ្ជា ។
ដល់ហើយក៏ទ្រង់ស្ទុះភ្លា ទៅសោយតង្ហា និងស្រង់រួចសឹមខ្ចប់យក ។
តែទ្រង់ឮពាក្យសង្ស្រុក សង្កេតអករក ឃាត់ហាំងមិនឱ្យប៉ះពាល់ ។
ពីយក្សប្រាប់ក្រក់សល់ ពោលប្រាប់បកផ្កាល់ ថាជាកម្មសិទ្ធិផងខ្លួន ។
យក្សបោះសម្ដីជូន១ ម៉ឺងម៉ាត់ម៉ាំមួន ដាក់ជាលក្ខខណ្ឌមួយថា ។
សូមឱ្យទ្រង់ឆ្លើយប្រស្នា រួចរស់សិនណា ទើបអាចចុះទឹកនោះបាន ។
ឮពាក្យយក្សដូចតិរច្ឆាន ព្រះអង្គមិនស្មាន ថានោះជាការពិតសោះ ។
រួចក៏មានះយាងចុះ យក្សឃើញដូច្នោះ ក៏វាយទ្រង់សុគតទៅ ។
យុធិស្ឋិរចាំមើលផ្លូវ អនុជពាលពៅ មិនឃើញទ្រង់ត្រឡប់មក ។
ទ្រង់ព្រះតម្រាស់ហៅរក នកុលពន្លក មានរូបល្អស្រស់ជាងគេ ។
ថានកុលប្អូនមាសមេ បាកុំធ្វេសទ្វេ ចូរឆាប់ចាកចេញទៅតាម ។
នកុលក៏យាងតាមស្នាម-ដើងនៅជិតដាម ឃើញអនុជក្ស័យស្លុកស្លឹង ។

ភ្លាមនោះទ្រង់ហើបសម្លឹង ទតទឹកក្នុងបឹង សមនឹងមានរសពិសា ។
ទ្រង់ត្រាច់សំដៅយាត្រា ក៏ជួបវាសនា ដូចសហទេពតែម្តង ។
លុះបាត់យូរពេកកន្លង មិនដូចបំណង ទ្រង់ឱ្យអរជូនតាមភ្លាម ។
តាមព្រះបញ្ជាព្រះរៀម មិនមានទីមទាម អរជូនយាងទាំងមួហ្មង ។
រួចហើបពិរោធកន្លង ទៅបួយអង្គម្តង យក្សវាយសុតតតតសល់ ។
ក្នុងព្រះទ័យសែនខ្វាយខ្វល់ យុធិស្ឋិរស្គាល់ ថាជារឿងចម្លែកក្រៃ ។
ទ្រង់ព្រះវិការណ៍ផាផៃ អនុជស្ងើចផ្ទៃ ហេតុអ្វីបាបាត់ទាំងអស់ ។
ទើបទ្រង់ឈានព្រះបាទឆ្ពោះ ទៅទាំងមានមោះ- មៃខ្លាំងក្នុងព្រះឱរា ។
លុះប្រទះព្រឹត្តការណ៍ ទ្រង់ឆ្ងល់ណាស់ថា ហេតុអ្វីក៏អាចដូច្នោះ ។
គ្មានស្លាប់ប្រយុទ្ធណាតោះ ម្តេចក៏ប្អូនប្រុស អញ្ចក្ស័យដោយងាយអ្វីម្ល៉េះ ។
យក្សយល់សព្ទសេចក្តីនេះ វាក៏រេរ៉ះ មកទូលយុធិស្ឋិរថា ។
អរជូនហៅពេញហានក្លា ចិត្តចង់ប្រហារ យើងចោលនឹងព្រួញមុត១ ។
យើងមិនខ្លាចសព្វាវុធ មិនចង់ប្រយុទ្ធ តែយើងឱ្យដោះប្រស្នា ។
ពួកនេះមានះណាស់សា យើងក៏ប្រហារ វាចោលទាំងអស់តែម្តង ។
ពេលនេះយើងអរកន្លង ព្រោះឯងជាបង កាន់ប្ញករាបសាជាងគេ ។
ឥឡូវឯងកុំធ្វេសទេ ព្រមស្រាយឬទេ នូវរាល់ប្រស្នាយើងចោទ ។
បើឆ្លើយរួចយើងលែងក្រោធ ឯខ្លួនឯងសោត អាចធ្វើអ្វីតាមចិត្តចង់ ។
គ្មានផ្លូវអាចឱ្យអែអង់ យុធិស្ឋិរផ្ចង់ ស្មារតីចាំឆ្លើយឥតសល់ ។
ព្រមជាមួយនឹងកិច្ចកល យក្សសែនរចល់ លើកប្រស្នាឡើងបន្ត ។

វាំងទឹកព្រះទ័យអបអរ យុធិស្ឋិរក៏ ស្រាយប្រស្នាទាំងនោះថា ។
លើសលោកលោកនេះពា រស្មីសុរិយា ចាំងចែងក្នុងសច្ចធម៌ ។
ចំណេះវិជ្ជាបវរ គឺការរៀនធម៌ ក្នុងសព្វគម្ពីរនានា ។
បុគ្គលឧត្តមមហិមា គឺអ្នកភាវនា ដូចជាធុតង្គឫសី ។
ប្រាជ្ញាមុតសែនគប្បី ជាមិត្តភក្តិ ដ៏ល្អនៅជាប់ជាមួយ ។
ព្រោះវាជាជនចាំជួយ និងជាទ្រព្យព្រួយ មិនចេះរីងស្ងួតឡើយហោង ។
ប្រព្រឹត្តព្រហ្មចារ្យផង ឱ្យដូចបំណង នឹងកើនគតិបណ្ឌិត ។
អ្នកយកគម្ពីរជាមិត្ត អនុវត្តធម៌ពិត នឹងបានដូចជាទេព្ដា ។
ក្រុមគ្រួត្រូវរៀបគ្រឿងសក្ការ បូជាទេព្ដា ឱ្យទៀងជាប្រក្រតី ។
ប្រាជ្ញណាប្រាថ្នាអ្វី១ ដែលជាលោកិយ ទោះបីរស់ក៏ដូចស្លាប់ ។
ជាក់មារយាទកាយទឹកជាស- ប្បុរសធម៌ពិតាប់ ជាទម្លាប់អភិជន ។
មាតាជាអ្នកមានគុណ ប្រសើរពេកពន់ សែនធ្ងន់លើសទាំងផែនដី ។
ឯអ្នកខ្ពង់ខ្ពស់ពិសី បួសសួគ៌ាល័យ គឺបិតាយើងនោះហោង ។
អារម្មណ៍របស់យើងផង រសាត់ហើរឆ្លង លឿនជាងវាយោបក់ផាត់ ។
ការគិតមមៃមិនបាត់ តែងផុសច្រើនក្តាត់ ក្នុងចំនួនច្រើនជាងស្មៅ ។
ទោះរីករាយឬហ្មងសៅ ការគិតនោះនៅ តែច្រើនឥតមានចន្លោះ ។
ជម្រកដ៏ខ្ពស់បង្អស់ នៃធម៌សប្បុរស គឺសទ្ធាទានតាមបទ ។
កេរ្តិ៍ឈ្មោះពីរោះប្រាកដ តាមប្រាជ្ញសន្មត គឺដាក់ទានតាមការគួរ ។
ជម្រកខ្ពស់នៃឋានសួគ៌ តាមក្រមជាតួ- យ៉ាង គឺស្នេហ៍សច្ចធម៌ ។

រាកប្បកិរិយាដ៏ល្អ ដូចទ្រព្យបវរ ជាជម្រកសុភមង្គល ។
បុត្រាបុត្រីនិម្មល ដូចចន្ទមណ្ឌល គឺជាព្រលឹងឪម៉ែ ។
ព្រះប្រទានតួគូរស្នេហ៍ ឱ្យមកជូនថៃ ស្វាមីដូចមិត្តនឹងគ្នា ។
ភាពជំនាញជាមុខងារ ប្រសើរមហិមា គួរឱ្យសរសើរម្ល៉េះទេ ។
ចំណេះវិជ្ជាជាមេ ថ្លៃថ្លាជាងគេ ជាយសខ្ពស់ឥតអ្វីស្មើ ។
សុខភាពដូចទ្រព្យត្រូវប្រើ បើល្អប្រសើរ នឹងនាំឱ្យរីករាយក្រៃ ។
ករណីយកិច្ចថ្លាថ្លៃ ជាអចិន្ត្រៃយ៍ គឺតបកុំធ្វើទុក្ខម្តេញ ។
រីឯអារម្មណ៍នោះវិញ បើអាចត្រួតពេញ មិនកើតវិប្បដិសារៈ ។
ហេរិច្ចតានាំឱ្យរស់សេក្តីណា បើលះបង់ជាក់ នឹងនាំឱ្យគេពេញចិត្ត ។
តណ្ហាជាហេតុទុច្ចរិត បើលែងផ្តេកផ្តិត ពិតដូចបរិបូណ៌ដោយទ្រព្យ ។
កំហឹងជាទ្រព្យមិនគាប់ បើបានរម្ងាប់ មិននាំឱ្យសោកស្តាយឡើយ ។
កំណាញ់ទ្រីស្តិស្នូរឥតស្បើយ បើលះបង់ហើយ គេនឹងស្គាល់ក្តីសប្បាយ ។
ការឈ្នះឥន្ទ្រិយទាំងឡាយ ដោយមិនមានស្តាយ ជាការត្រួតត្រាពិតៗ ។
ឯការបញ្ចប់អមិត្ត- ភាពជាធាតុពិត នៃគុណធម៌សន្តោស ។
ការតមអ្វីៗជាទោស ជាគ្រឿងរឱស នឹងឱ្យអស់ការខ្មាសអៀន ។
ទ្រព្យធនពិតៗនោះមាន វិជ្ជាដែលរៀន ចេះពីព្រះព្រហ្ម ព្រះពុទ្ធ ។
ក្តីសុខដូចសារពើយុត្ត ឱ្យផុតទុគ៌ត គឺសុខខាងផ្លូវចិន្តា ។
រីឯមេត្តាករុណា នោះមានន័យថា ប្រាថ្នាឱ្យគេបានសុខ ។
បើអង្គរឿងបែនបុក ឱ្យឈឺចាប់ចុក ខ្លួនឯងក៏លែងសប្បាយ ។

អភិជ្ឈាជាហេតុអន្តរាយ ដូចដំពៅក្លាយ មិនអាចឱ្យព្យាបាលបាន ។
ក្តីទៀងត្រង់ជាកល្យាណ គឺចង់ឱ្យបាន ក្តីល្អដល់សព្វសត្វលោក ។
រីឯកិរិយាស្មោកគ្រោក តែងទទួលយក ទឹកចិត្តអាក្រក់គ្រប់យ៉ាង ។
អវិជ្ជាតាមន័យជាតាង គឺមិនស្គាល់ខាង ករណីយកិច្ចផងខ្លួន ។
មោទនភាពមិនសមសួន គឺយល់ថាខ្លួន ជាតួសំខាន់ក្តាត់ណា ។
ទាំងក្នុងវីរកថា ទាំងរឿងសោកា ថាខ្លួនដើរតួទាំងគ្រប់ ។
ខ្លៅនិងអវិជ្ជាដូចយប់ ឱ្យងងឹតឈ្លប់ ជាប្រភពព្រួយបារម្ភ ។
ការកាន់ខន្តីជាធំ គឺជាការជ- ម្នះវិញ្ញាណប្រាំប្រការ ។
មូលហេតុនៃមហិច្ឆតា គឺការយល់ថា យោបល់ខ្លួនត្រូវទាំងអស់ ។
រីឯសេចក្តីសប្បុរស គឺមានចិត្តស្មោះ ក្នុងការរក្សាសត្វលោក ។
ព្រៃផ្សៃឱ្យបាត់ជ័យជោគ គឺការស្វែងរក ចងអាឃាតនឹងគ្នាឯង ។
មិត្តភាពប្រាកដជាក់ស្តែង ជាមិត្តមិនក្លែង គឺចិត្តស្មោះត្រង់នឹងគ្នា ។
បើហៅបទល្អល្អះជា សញ្ញាសទ្ធា នៃអ្នកកាន់សីលស្មោះសរ ។
ការបង្ហាញក្តីអបអរ ជារង្វាន់ប្រ- សើរដល់ពាក្យពោលពីរោះ ។
ធ្វើអ្វីដោយស្មោះចំពោះ ដើម្បីវៀរគ្រោះ គឺធ្វើដោយចេះរិះគិត ។
អ្នកបរិបូណ៌ដោយមិត្ត អាចស្គាល់ជីវិត រីករាយក្នុងពេលរស់នៅ ។
ការឧទ្ទិសខ្លួនស្មោះទៅ គុណធម៌ជាផ្លូវ ទៅបរលោកសែនថ្លៃថ្លា ។

# ច្បាប់ព្រះធម្មៈ (តនិងចប់)

## បទពាក្យ ៩

ការត្រួតត្រាបានលើអារម្មណ៍ឬចិត្ត   នេះទើបពិតជាហៅថាការត្រួតត្រា
សេចក្ដីខ្មាសអៀនក្រៃក្រាស់ជាផលា   កើតពីការប្រព្រឹត្តិអំពើមិនល្អ ។
វិជ្ជាពិតគឺការស្គាល់ពួកទេព្ដា   ទាំងសិក្សានិងកាន់ខ្ជាប់គុណធមិ
ភាពស្ងប់ស្ងៀមគឺតាំងចិត្តនៅនឹងន   មិនបន្ទរឬរញ្ជួយខុសក្រមក្រឹត្យ ។
ត្រូវកោះហៅរឿងនាំឲ្យមានពាក្យ "រញ"   ភាពសាមញ្ញជាឧបេក្ខានៃចិត្ត
កំហឹងជាសត្រូវប្រចាំក្បែរកិត   ក្លាខៗម្រិតថានឹងអាចឈ្នះវាបាន ។
ចិត្តវៀចវេរជាកិរិយាបង្ហាញថា   គ្មានមេត្តានិងករុណាសព្វសន្ដាន
ការណ៍ឃើញកិច្ចត្រូវបំពេញតាមលក្ខាន   បើខកខានគេហៅថាចោលលេបស្បៀត ។
ល្អកិរិយាជាសញ្ញាថាកាន់សីល   គ្មានបន្ទិលជាសៅហ្មងបកបៀនបៀត
កិរិយាអាក្រក់នឹងនាំឲ្យមនុស្សជាតិ   បែរជាឆ្ងៀតគេអន្តរាយចៀសមិនផុត ។
អ្នកសិក្សាគម្ពីរសាសនាបានចប់   មិនទាន់សព្វគ្រប់ថាជាជនបរិសុទ្ធ
បើកិរិយាបថមិនសមជាកុលបុត្រ   មិនប្រាកដថាជាមនុស្សមានចិត្តស្អាត ។
ដើរមួយថ្ងៃទៅមួយថ្ងៃដោយធម្មតា   ជាន័យថាការឈានចូលក្នុងប្រាសាទ
អត្តភាពនៃជីវិតជនប្រពាទ   ទុកជាខ្នាតនៃការសម្ដែងឆាកមួយ ។
អ្នកនៅរស់នៅឡើយតែងគិតថា   មិនមានការអ្វីនាំឲ្យគេទុក្ខព្រួយ
ព្រោះជីវិតត្រូវខ្លួនតែបានលើកស្ទួយ   ដាក់ជាមួយនឹងធម៌នៃអចិន្ត្រៃយ៍ ។

រួចគេយល់ឃើញថាគ្មានអ្វីអស្ចារ្យ ហើយក៏ក្លាយរីករាយចិត្តរៀងរាល់ថ្ងៃ
ព្រោះយល់ថាវត្ថុរាល់គ្នាអចិន្ត្រៃយ៍ តើមានអ្វីឱ្យអស្ចារ្យជាងនេះណា ។
រួចគេនាំគ្នាប្រឹងប្រមូលធនទ្រព្យ ដើម្បីផ្គាប់ចិត្តពាលយល់ថាថ្កើងថ្កាន
មិនអោនមើលគេឯងជាញាតិសន្តាន ឱ្យតែបានសាងខ្លួនខ្ពស់ប្លូសជាធំគេ ។
ខិតខំកេងកិបប្រាក់មាសគរជាភ្នំ តាមការផ្តុំផ្គុំលួចលាក់ឥតពិតត្រង់
លួចពន្ធដារព្រោះចិត្តចង់បានទទេ ទាំងវិះរកប្រើកលល្បិចខូចគ្រប់យ៉ាង ។
ព្រមគ្នានោះក៏កើតមានចិត្តនិន្ទា ឈ្លានីសគ្នាជាមួយអ្នកនៅជិតខាង
ប្រកាន់វាយអ្នកក្រជាងតាមការរាង ជាតឹកតាងនៃទឹកចិត្តអន្យត្ថិយ ។
ក៏កើតឡើងជាជម្លោះទាស់ទែងគ្នា បែកសាមគ្គីជាអាសន្នដល់ដែនដី
រាស្ត្រប្រជាមិនថាក្មេងចាស់ប្រុសស្រី ត្រូវរងក្តីទុក្ខវេទនាដោយឯងៗ ។
ក្មេងឥតបានទោសកំហុសត្រូវកើតមក រួចក៏ជ្រកជ្រៀតនៅក្នុងទឹកភ្នែង
អ្នកផ្លូវពុំមានការគាំពារក៏ហែង នេះជាល្បែងនិងផលនៃចិត្តលោភលន់ ។
ឱ! យក្សអើយ! នេះហើយផលអភិជ្ឈា អវិជ្ជាដែលកើតចំពោះទុរជន
ចិត្តជាចោរចាំតែស្រេកប្លន់ទ្រព្យធន មិនគិតគន់ដល់នរជនជាតិដូចគ្នា ។
មិនគិតពីសច្ចៈ ព្រហ្មវិហារធម៌ មិនញាប់ញ័រនឹងក្តីល្អជាមាគ៌ា
ឆ្ពោះទៅរកព្រះនិព្វានឬថាជា ព្រះព្រហ្មានៅក្នុងឥន្ទ្រិយារម្មណ៍ ។
សូមប្រឹងប្រែងចាប់ន័យនេះឱ្យបានជាក់ និងត្រូវអនុវត្តតាមទុកជាក្រប
ទើបមនុស្សម្នាទៅជាបុគ្គលឧត្តម ស្គាល់ក្តីចម្រើនរុងរឿងចិត្តក្សេមក្សាន្ត ។
ឧបករណ៍ជាមាគ៌ានាំសំដៅ ឱ្យឆ្ពោះទៅរកសេចក្តីសន្និដ្ឋាន
គ្មានភស្តុតាងគ្មានអ្វីអាងជាប្រមាណ គ្មានដើមដានអាចឱ្យបានដឹងការពិត ។

កម្ពើរស្រុតិបាកខុសគ្នាទាំងអស់ ឱ្យតាមសប្បុរសជាអ្នករិះគិត
បញ្ចេញយោបល់ផ្សេងគ្នាតាមគំនិត ម្នាក់ៗគិតថាខ្លួនគេមិនខុសឡើយ ។
ច្នេះការពិតនៃសាសនានិងករណីយ- កិច្ចអ្វីៗត្រូវបំពេញទុកជាត្រើយ
នៅតែកប់បាត់ក្នុងរូងជ្រៅនៅឡើយ ដែលត្រូវឆ្លើយឆ្លងជាមួយជាប្រក្រតី ។
ជាមាគ៌ាដែលមហាបុគ្គលត្រូវដើរ ឬបម្រើតម្រូវតាមកាលលោកិយ
សម្រាប់ឱ្យរកឃើញធម៌អចិន្ត្រៃយ៍ គឺដើម្បីឆ្លងឱ្យផុតក្តីទុក្ខព្រួយ ។
សកលលោកពោរពេញដោយអវិជ្ជា អាចប្រៀបគ្នាទៅនឹងខ្ទះដ៏ធំមួយ
ព្រះអាទិត្យជាភ្លើងឱ្យក្តៅរលួយ មួយថ្ងៃមួយយប់ឆ្លងផុតប្រៀបដូចប្រេង ។
ខែរដូវជាដងវែកធ្វើពីឈើ សម្រាប់ប្រើដួសឬកូរប្តូរស្តាំឆ្វេង
ពេលវេលាជាក្រុងភ្លៅនៅចាំសេង ដាក់ក្នុងប្រេងរួចចម្អិនតាមកំណត់ ។
ឱ! យក្សអើយ! នេះឯងហើយ **ពត៌មាន** សូមឧទានជូនលោកស្តាប់ជាបែបបទ
ប្រស្នាថាមនុស្សបែបណាទើបព្រាកដ យើងសន្មតជាសេចក្តីដូច្នេះថា ។
នៅលើលោកសព្វវាសយើងនេះមាន វត្ថុទានហៅថាសេចក្តីរាយការណ៍
ល្បើពីកុសលនៃជនម្នាក់ណា ដែលខ្លឹមសាររសាត់ដល់សូត្រាល័យ ។
រួចក៏បែរបកមកវិញមិនអន្តរាយ តែរីកសាយជាសង្គះដាលសព្វដែនដី
ជារាបណាវាបន្តយ៉ាងណាក្បៀ ទើបមានន័យថាជា **មនុស្ស**ពិតព្រាកដ ។
អរអោយល់ឃើញថាការពោលសរសើរ មានដំណើរនិងតម្លៃដោយសន្មត
ដូចគ្នានឹងការទិទៀនតាមបែបបទ ជាកំណត់ថាគេមិនភ័ន្តវិញ្ញាណ ។
មួយវិញទៀតគេឃើញលុះត្រូវនិងមិត្ត កាព្យអតីត អនាគតមិនបំពាន
ព្រោះស្នេហាដូចឈ្លោះចាញ់ ក្រនិងមាន អ្នកមានពុំមានទាក់ទាមគេសោះ ។

ជនបែបនេះហៅថាជាអ្នកមានទ្រព្យ  សម្បត្តិគាប់សព្វគ្រប់ឥតខ្វះចន្លោះ
ព្រោះពេលមានដល់ដំណាក់កាលខ្ពស់បង្អស់ ជាកេរកោះនៃសម្បត្តិគួរគាប់ចិត្ត ។
ក្នុងចិត្តរីករាយពន់ពេកយកថា ឱ! ឯងជាមនុស្សទេវាដោយពិតៗ
ព្រោះមានចិត្តពេញដោយគតិបណ្ឌិត គឺប្រព្រឹត្តត្រឹមត្រូវជាងគេក្នុងលោក ។
ប៉ុន្តែយើងសុំប្រគល់ចំណោងដៃ  មួយយ៉ាងថ្លៃចំពោះឯងឱ្យរើសយក
ម្ដងមួយពេលចង់ឱ្យរស់ចូរប្រាប់មក  យើងលែងលកខាបយកជីវិតឱ្យវិញ ។
កុំចិត្តរើសនកុលមានរូបល្អ  ស្រស់បវរសព្វគ្រប់អស្ចារ្យសែនក្ដៅពេញ
យកក្រមុំក្រមួងការជំទាស់ទាំងទោរម្ចេញ វាមិនពេញចិត្តសោះនឹងចម្លើយនេះ ។
សួរថា ក៏បដែលឯងស្រឡាញ់ជាងគេ  ម្ដេចមិនត្រូវគ្មាន់គិតគួរគួរត្រិះរិះ
រើសយកអរជូនវិញ ធ្នូរកុំវេះ  អរជូននេះឯងត្រូវការជាចាំបាច់ ។
ឯងត្រូវពឹងផ្អែកឱ្យល្អះសង្គ្រោះ  តែបានត្រៀមខ្លួនយកជ័យរួចជាស្រេច
ជាងខ្លាំងពូកែពិតចិត្តប្ដូរផ្ដាច់  មិនសម្រេចយកអរជូន តើព្រោះអ្វី ។
អរជូនអាចធ្វើគតិព្រេចបួនរាត្រ  ឱ្យក្បូយពាសពេញលើសមរភូមិជ័យ
គំរកខ្លាំងដូចគ្នាដែរមិនបាច់ស្ដី  តើហេតុអ្វីបានជាឱ្យនក្រមរស់ ។
កុំចិត្តរើសថាខ្ញុំសុខចិត្តស្លាប់ចុះ  ជាជាងកោះហៅព្រះធម្មដ៏ខ្ពង់ខ្ពស់
ដូចជាមនុស្សល្អឧត្ដមគតិនិងកិត្តិយស  នាំឱ្យឈ្មោះខ្ញុំអស់សោកសែងការណ៍ ។
ខ្ញុំចង់ឱ្យមនុស្សក្នុងលោកស្ដាប់ថា  ខ្ញុំស្នេហាធ្វើសក្ការក្ដីធម៌
លើកតម្កើងព្រះធម្មជាត្បាគារ  ទុះដល់មរណាគាកចុងក្រោយគត់ ។
ពិតាខ្ញុំបានមហេសីពីរអង្គ  មួយនាមព្រះនាងកុន្តីទេវី
មួយអង្គទៀតព្រះនាមព្រះនាងមាទ្រី  ទ្រង់ទាំងពីរស្នេហារាជបុត្រដូចគ្នា ។

ប៉ុន្តែឱ្យបុត្រមួយៗនៃមាតា ទាំងទ្វេហារបានរស់រានតាមទយា
មិនត្រូវឱ្យគាប់តែម្នាក់នាំមានពៀរ ជាវេរាដែលកើតពីចិត្តលម្អៀង ។
ខ្ញុំជាបុត្រព្រះនាងកុន្តីទេវី នាងមាទ្រីទ្រង់ស្នេហានកុលជាង
ខ្ញុំស្នេហាមាតាទាំងពីរឥតល្អៀង ឱ្យព្រះនាងសព្វព្រះទ័យស្មើៗគ្នា ។
ពុំឱ្យមួយរកាំចិត្តទ្រូងស្ទើរធ្លាយ មួយរីករាយព្រោះសល់បុត្រពីរអង្គា
ត្រូវឱ្យសល់បុត្រមួយម្នាក់ទើបល្អជា សូមភាវនាឱ្យនកុលខ្ញុំរស់ឡើង ។
យក្សរំភើបនឹងយោបល់នេះពេកពន់ តាំងពីមុនមិនដែលជួបជនថ្កុំថ្កើង
ប្រយុត្តិធម៌គេជាប់ចិត្តឥតរើសរើង ដោយចចើងពោះបង់អាត្មានិយម ។
យក្សពេញចិត្តរបួតដល់អនុគ្រោះ ប្អូនទាំងនោះឱ្យបានរស់រានជួបជុំ
ក្រោកឡើងវិញផុតទុក្ខព្រួយមួយសែនធំ នេះបានចំជាព្រឹត្តិការណ៍អស្ចារ្យ ។
យក្សក៏ញ៉ាំងព្រះធម្មរាជព្រោះសព្វព្រះ ទាំងព្រះម៉ែហើរភីមអរជុនមហា
ព្រះធម្មរាជទាំងបីពេកពួកយក្សា ក្លាននិន្ទាម្តងហោជាកុសលនេះ ។
យក្សម្នាក់នេះការពារធម្មទេព្តា ទាំងការរក្សាកិរិយាល្អខ្ពស់ខ្ពង់
ហេតុដូចជាមិនក្រោកជាយក្សទេ ពីក្រុមតេជ្ជនដេនេះជារឿង ។
យក្សបាត់ទាំងក្រុមចិត្តធ្វើព្រោះប្អូន ក៏រីករាយក្តីស្រឡាញ់អស្ចារ្យ
ព្រះធម្មរាជបួនដើរវិញទៅតាម និងរករឿងមករៀបរាប់ក៏មិនបាន ។
ព្រះចិត្តប្រាសចាកល្បើសសារសព្វសត្វលោក គួរមានជោគជ័យព្រមទាំងប្រាជ្ញាញាណ
ព្រោះកើតការណ៍ដូចថ្មីរីកក្នុងឧទ្យាន ទ្រង់ប្រទានព្រះវាចាយ៉ាងនេះថា ។

កុមារកុមារ ឱ! កុំព្រាសម្លាញ់ចិត្ត យើងនេះពិតប្រាកដណាស់ជាពិតា
ព្រោះធម្មៈដែលឱ្យកំណើតដល់បា ចូររក្សាកិត្តិយសបាឱ្យគង់វង្ស ។
ប្រុសស្រីអាចយកជោគជ័យបានទាំងអស់ ព្រោះមានឈ្មោះទាំងរាជរក្សាទៅមុខ
ពេទៅមុខឱ្យស្គាល់ជាប់ក្ដីរឿងរុង ព្រោះឯងគង់លើបល្ល័ង្កយុត្តិធម៌ ។
កុំក្ដីព្រោះឯងនឹងលោភលុះរឿងដោយវាច មិនស្ទួនត្រាប់បីផ្លូវធម៌ក្នុងតោគារ
ដែលរក្សារសជាតិប្រែជាក្លាតរ យុត្តិធម៌ជារវាងពោចក្រចំងង ។
ប្រុសស្រីបានឡើងដល់ឋានសួគ៌ព្រះព្រហ្ម បានជាធំទាំងប្រាបសព្វទីកន្លែង
កុំក្ដីព្រោះល្បីដូចរស្មីចាំងទីពេញង ព្រោះតែឯងប្រោស យុត្តិធម៌ឱ្យថ្លៃថ្លា ។
យុត្តិធម៌ជាដើមហេតុអភិវឌ្ឍន៍ យ៉ាងទៀងទាត់ទាំងសង្គមក្រុមទេព្ដា
ក្ដីវិការាយមិនកើតដល់នគរា ចូររក្សាកិរិយាបាឱ្យប្រសើរ ។
បើមិនស្មោះត្រង់ចំពោះយុត្តិធម៌ ដូចក្បត់នគរនិងរាស្ត្រ ជាដំណើរ
ស្មុគស្មាញវិនាសអន្តរាយគ្មានអ្វីស្មើ ដូចបណ្ដើរជាតិទៅកាន់គាប់ភិរិក ។

# ច្បាប់ព្រះវិទូរ

## បទកាកគតិ

ក្នុងកាលនោះណា    ព្រះមហាក្សត្រា-    ធិរាជជាញ្ជ័យ
ធបូពរាស្ត្រ    ទ្រង់ព្រួយព្រះទ័យ    ហៅវិទូរថ្លៃ
ឱ្យយាងមកគាល់ ។

ទ្រង់ត្រាស់ទៅថា    វិទូរអើយ ណា!    រៀមរែងពិភាល់
សែនរកាំចិត្ត    ដ្បិតផ្ចំមិនស្គាល់    តម្រិះបងទ័ល
សូមប្អូនជួយផង ។

វិទូរទ្រង់ត្រាស់    បញ្ជាក់យ៉ាងច្បាស់    ថ្វាយព្រះរៀមច្បង
ថាឱ! ជេដ្ឋា    ថ្លៃថ្លាកន្លង    សូមអម្ចាស់បង
ស្ដាប់ការរៀបរាប់ ។

មានមនុស្សប្រាំយ៉ាង    ដែលជួបសំណាង    មិនសូវគួរគាប់
រួចដេកមិនលក់    ហៅសែនអភ័ព្វ    ព្រោះជាជនជាប់
ចិត្តឥតងាករេ ។

ទីមួយគឺជន    លួចសហាយស្មន់    នឹងប្រពន្ធគេ
ពីរ ជនមោហោ    ចិត្តចោរជាមេ    ដេកមិនលក់ទេ
ក្លាយជាទម្លាប់ ។

ទីបី អ្នកណា    ដែលគិតខ្លីថា    ខ្លាចបាត់បង់ទ្រព្យ
លុះទ្រព្យបាត់អស់    តែងព្រួយចិត្តជាប់    ពៀរនេះមិនគាប់
មិនឱ្យលក់ឡើយ ។

មនុស្សជំពូកប្អូន ជាមនុស្សមានខ្លួន ពិតឥតល្ហែល្ហើយ
ហើយរំពេញការ មិនបានដល់ត្រើយ ចិត្តឥតធូរស្បើយ
ដេកមិនលក់ទេ ។

មនុស្សប្អូនអភ័ព្វ វាសនាមិនគាប់ ខ្សត់ខ្សោយជាងគេ
ត្រូវគេជិះជាន់ ឱ្យឈឺចិត្តទ្រូ ដេកមិនលក់ទេ
ព្រោះក្តីហ្មងសៅ ។

មនុស្សជំពូកប្រាំ សូមទ្រង់ចងចាំ ជារឿងសាហាវ
ហេតុតែខ្លួនខ្សោយ នាំឱ្យចិត្តក្តៅ ព្រោះខ្លាំងហើយខ្លៅ
ជិះជាន់ពាធា ។

ហេតុត្រូវព្រះអង្គ សូមទូលដោយត្រង់ ទ្រង់ប្រាកដជា
ពិតមែននៅក្នុង ពូជពង្សមនុស្សា ទាំងខូចទាំងជា
ទាំងប្រាំនេះឡើយ ។

ម្យ៉ាងទៀតព្រះអង្គ មិនមែនជាវង្ស ល្ងិតល្ងង់នោះហើយ
ទ្រង់ស្តីស្នូរពីណាញ់ ពិបាកាញ់ពោះតើយ តែត្រូវល្ហែល្ហើយ
ព្រះទ័យឥតហ្មង ។

សង្ឃឹមរស់ហើយ សូមប្អូនត្រាណត្រើយ ឆ្លើយប្រាប់ភក្តួង
ទៀតដោយពិស្តារ តាមការសាសង ដើម្បីឱ្យបង
ភ្លឺសព្វជញ្ញ: ។

ចូរប្អូនប្រាប់ប្រាប់ ព្រោះបងចង់ស្តាប់ អំពីលក្ខណ-
ការឬក្តីកើត និងពាលអប្បលក្ខណ៍ ឱ្យរស់ឥតរាក់
តើយ៉ាងដូចម្តេច ។

បើប្រៀបធៀប បណ្ឌិតនោះផង តែងជាប់នឹងកិច្ច
ចម្រើនចង់បាន ខ្ពង់ខ្ពស់ជានិច្ច ឥតបីភ្លាំងភ្លេច
កិត្តិយសអាត្មា ។

ទោះហៅបណ្ឌិត ក្នុងមួយជីវិត តែងគិតប្រាថ្នា
តែយុត្តិធម៌ សច្ចធម៌សព្វសារ- ពើជាគោលការណ៍
ពាក់ក្នុងលោកិយ ។

សម្បត្តិផ្សេងទៀត គេប្រឹងឆ្លាស់ឆ្លៀត ចាំជាប្រក្រតី
ពីស្គាល់ខ្លួនឯង តស៊ូ ខន្តី គុណធម៌ទាំងបី
ប្រព្រឹត្តខ្ជាប់ខ្ជួន ។

ម្យ៉ាងទៀតបណ្ឌិត តែងត្រួតពិនិត្យ ការពិតពីខ្លួន
កម្ចាត់កំបាំង កំបែងគុំគួន រីករាយខុសក្បួន
ក៏មិនមានផង ។

នៅក្នុងចិន្តា គ្មានមហិច្ឆតា បន្តិចឡើយហោង
មិនចេះយកតាក់- តួរខុសទំនង អារម្មណ៍មួហ្មង
ក៏រួចរដោះ ។

ពេលធ្វើអ្វី១ តាំងចិត្តខន្តី ឥតបីចន្លោះ
បណ្ឌិតបំពេញ មិនមានឱ្យខ្ចោះ ទុកជារបស់
នៃលោកទាំងពីរ ។

ទាំងមិនបណ្ដោយ ស្មារតីទន់ខ្សោយ ឱ្យចូលញាំញី
ព្រោះអ្នកបណ្ឌិត កើតក្នុងឥន្ទ្រិយ សុខដុមរមណី
បួលមីរក្នុងចិត្ត ។

មិនចេះពាយងាយ តែតែងរីករាយ ជាប់នឹងសុចរិត
គុណសម្បត្តិល្អ ជាធម៌ថេរថិត មិនក្រៅក្រមក្រឹត្យ
តាមចិត្តស៊េរ៉ី ។

មិនចេះអវហួស មិនលើកកម្ពស់ ពាក្យពោលសរសើរ
ឯពាក្យទិតៀន ហ៊ានលើកឱ្យស្មើ ឥតបីឥតបើ
ឱ្យខូចចិត្តជា ។

បណ្ឌិតអបអរ នឹងឱបគុណធម៌ ឥតបីចាកវៀរ
ជំហរដូចទឹក ទន្លេគង្គា ហូរនឹងគ្រប់គ្រា
មិនមានខ្វាវខ្វះ ។

មនុស្សតិរច្ឆានោ ចិត្តចោរមោហោ តែងខ្វះសីលធម៌
ជាពាលឥតពូជ ឈ្មោះខូចដូចមរណ៍ ចង់ស្តីដូចគ
ឥតមានគេស្តាប់ ។

ពាលតែងឡើងចាង ច្រងេងច្រងាង អាងបាញ់ចាក់កាប់
អាងអំពើពាល ឥតញញើតច្បាប់ ចិត្តចង់បានឆាប់
ចាប់ទាំងបង្ខំ ។

រីឯមហាក្សត្រិយ៍ កបគុណសម្បត្តិ សម្បូណ៌ឧត្តម-
គតិប្រសើរពិត មានមិត្តកុះករ នឹងបានជាធំ
ព្រោះប្រើប្រាជ្ញា ។

ត្រូវចេះស្គាល់ **មួយ** សម្រាប់ទុកជួយ **ពីរ** និងត្រួតត្រា
**បី** តាមរយៈ ធម៌ **បួន** ប្រការ **ប្រាំ** ជាតណ្ហា
ជម្នះឱ្យបាន ។

ស្តាប់នឹង ឆ្នាំមួយ ហើយកុំលើកស្ទួយ ឆ្នាំពីរ ជាថ្កាន
ត្រូវតមទល់ទប់ ត្រូវឈប់ខកខាន កុំធ្វើកល្យាណ
នឹងរឿងអាស្រូវ ។

តើ មួយ ជាអ្វី អនុជសូមស្តី ទូលថ្វាយជាផ្លូវ
មួយជាអាវុធ ស្រួចមុតពេកកូវ សូមត្រាស់ឱ្យត្រូវ
លោកបៅប្រាជ្ញា ។

វិសោតង ពីរ សូមទ្រង់សំភី តាមព្រះវិចារណ៍
គឺខុសនិងត្រូវ ទាំងពីរប្រការ នេះសូមជេដ្ឋា
ជ្រាបជាសេចក្តី ។

ឯមិត្តសម្លាញ់ សត្រូវត្រូវផ្ចាញ់ អ្នកផ្សេងដទៃ
រាប់រៀបរៀងគ្នា បូកបានជា បី នេះជាករណី
ទ្រង់ត្រូវទទួល ។

បួន មានទាន់ ដោយមានរួមទាំង សម្រុះសម្រួល
រឹងប៉ឹងហ្មត់ចត់ កុំបីប្រែប្រួល បួន ឱ្យបបួល
បំបាក់បំបែក ។

វិសោតង ឆ្នាំ ព្រះអង្គគួរចាំ ថាគ្មានអ្វីប្លែក
ត្រូវតាំងព្រះទ័យ ឱ្យរឹងដូចដែក ឱ្យឈ្នះគ្រប់ផ្នែក
លើវិញ្ញាណប្រាំ ។

ករណី ឆ្នាំមួយ យ៉ាងដែលត្រូវស្ទួយ ទុកជាបណ្តាំ
ជាបណ្តូលកិច្ច- ការសែនសកម្ម ថាអ្នកដឹកនាំ
ត្រូវស៊ាំនឹងអ្វី ។

ពីរាល់ឯកសារ ភ្ជាប់ដោយ "សញ្ញា" មិនថាវែងខ្លី
សន្និសញ្ញា កិច្ចសន្យាក្ដី គួរគិតគប្បី
ចាំគ្រប់ប្រការ ។

ចេះចាំឱ្យជាប់ ទុកជាទម្លាប់ គ្រប់សព្វមាត្រា
ស្ទាត់សព្វជំពូក អនុសញ្ញា ទាំងកតិកា-
សញ្ញានោះផង ។

អនុស្សរណៈ ត្រូវរៀបរៀងដាក់ ទុកជាកម្រង
កម្រិតគោលការណ៍ ជាត្រីះចម្បង ទាំងពិតគួរផង
រឿងសឹកសង្គ្រាម ។

ត្រូវពន្យាសវាងវៃ ដោយបេះលេកលៃ វវិះវវាប
បើមានការក្រ កុំទុកទឹមទាម ត្រូវអនុវត្តភ្លាម
កុំឱ្យជាប់ទ័ល ។

គោពេង ទ្រាំតឹង បួយ ពីស្រីញី ពីរ ពីល្បែងភ្នាល់
បី ការបរបាញ់ កុំបីប៉ះពាល់ ព្រះអង្គត្រូវស្គាល់
ដល់ផលប្រយោជន៍ ។

បួន ការស្ដីឆ្លោះ ដោយពាក្យអសុរោះ នាំឱ្យផ្សាខ្លោច
នឹងឱ្យខូចឈ្មោះ កិត្តិយសអសោច សូវស្លាប់ជាខ្មោច
ទើបប្រសើរជាង ។

ប្រាំ សូមផ្ដាំថា ការសេពសុរា ត្រូវតែចៀសវាង
ស្រាតែងបង្វែរ ឱ្យប្រែជាល្ងៀង ចិត្តពីក្ដីទៀង-
ត្រង់ជាត្រាំណាត្រើយ ។

បទទីប្រាំមួយ សូមចាំជាត្រួយ កិច្ចគួរកៀកកើយ
គឺដាក់ទណ្ឌកម្ម កុំតឹងពេកឡើយ ព្យួរឱ្យធូរស្បើយ
អាណិតកូនចៅ ។
បន្ទែចុងក្រោយ គឺកុំបណ្តោយ ឱ្យកើតក្តីក្តៅ
ក្រហល់ក្រហាយ នាំកាយហ្មងសៅ តាមចិត្តកម្លៅ
ឱ្យខ្លៅបៀនបៀត ។
បន្ទែនេះណា គឺលោកចង់ថា ឱ្យមានមារយាទ
រក្សាឱ្យគង់ សម្បត្តិធម្មជាតិ ត្រូវតែខ្ចីឃ្លាត
ខិតខំថែថ្នូន ។
ធម្មជាតិជាទ្រព្យ សម្បត្តិកេរតាប់ ចិត្តជាប់ត្រូវស្ងួន
បំផ្លាញធម្មជាតិ គឺធ្វើឃាតខ្លួន បើណោជាជូន
ស្លាប់នគរផង ។
ពោលដោយសង្ខេប ដូចមានបទបែប ចែងច្បាស់កន្លង
គឺត្រូវដឹងស្គាល់ ខុសនិងត្រូវផង ជាគោលចម្បង
ប្រើប្រាជ្ញាគិត ។
អាចយកជោគជ័យ លើអ្នកដទៃ សត្រូវឬមិត្ត
តាមរយៈបួន ជាស្ងួនជីវិត ប្រាំប្រឹងពិនិត្យ
ត្រួតត្រាឱ្យបាន ។
សុំានឹងប្រាំមួយ ប្រាំពីរកុំស្ងួយ លើកជាកល្យាណ
តែត្រូវចាកចៀស កៀសចេញពីប្រាណ ទើបទទួលបាន
អារម្មណ៍វិមុត្ត ។

បណ្ឌិតប្រៀបថា ថ្នាំពុលកាចសា- ហាវជាអាវុធ
អាចសម្លាប់មនុស្ស បានតែម្នាក់គត់ ព្រួញមួយមិនមុត
ខ្ទាំងពីរនាក់ឡើយ ។

វិយោបល់ខុស ខិលខូចទញ់តុះ សូមកុំឆ្លងឆ្លើយ
ដ្បិតចិត្តឥតស្មោះ គ្រោះឥតល្ហែល្ហើយ នឹងមិនសល់ឡើយ
ទាំងរាស្ត្រទាំងក្សត្រិយ៍ ។

សម្បត្តិបវរ គឺ **យុត្តិធម៌** ធម៌ប្រសើរក្កាត់
ជាតួយ៉ាងដើម នៃព្រះមហាក្សត្រិយ៍ សូមទ្រង់ថែរចាត់
ឱ្យនៅរៀងរាប ។

សេចក្តីសន្តោស ប្រណីប្រាណប្រោស ជាសន្តិភាព
ខ្ពង់ខ្ពស់បំផុត បីដូចបានលាភ កិរិយារាបទាប
ជាឫកនៃនាយ ។

ចំណេះវិជ្ជា នាំឱ្យមាតា ភ្លឺឡើងព្រោងព្រាយ
សុខក្នុងកាយា ចិន្តាទូលាយ អារម្មណ៍រីករាយ
នឹងធម៌ករុណា ។

ឧក្រិដ្ឋកម្ម អាក្រក់ត្រូវចាំ មានបីប្រការ
មួយ លួចប្លន់ទ្រព្យ គេឥតមេត្តា ពីរ គឺស្នេហា
ស្មន្ធនឹងគូគេ ។

វិបត្តិទីបី ដូចធ្លាក់អវិចី អប្រិយឡើងទ្វេ
គឺបែកបាក់មិត្ត- ភាពឥតគិតគ្នេរ នាំខាតទទេ
ខូចទាំងកិត្តិយស ។

បាបកម្មបីយ៉ាង បើហ៊ានកសាង នឹងឱ្យខូចឈ្មោះ
គឺ**កាមមុច្ឆា** **ពិរោធ**នាំឈ្លោះ រោគជាមហាគ្រោះ
គឺ**អភិជ្ឈា** ។

ធម៌បីសំខាន់ ព្រះអង្គត្រូវកាន់ ជាប់ក្នុងទយា
មួយ គឺប្រតិបត្តិ តាមព្រះបញ្ញា ពីរ សុំការពារ
បី សុំជ្រកកោន ។

សូមព្រះអង្គថ្លៃ គិតគូរកែខៃ តាមការលំឱន
ត្រូវយកអាសា សោះគ្នាស្រពោន ទាន់គ្នាលំទោន
កុំឱ្យគ្នាស្ដាយ ។

សូមកាន់ព្រះទ័យ ឱ្យល្អប្រពៃ ដោយវៀរឱ្យឆ្ងាយ
ពីរអប្បលក្ខណ៍បួន ដូចមានអភិប្រាយ បន្ទឹបន្ទាយ
ជាបន្ទែថា ។

មួយ បោរអប្បលក្ខណ៍ ខ្វះសម្បជញ្ញៈ ខ្វះចិត្តវាចា
ពីរ គឺដំររក់ ល្បើកឡក់ឥតសារ តែរោះររង្គើយឈោ
រាប់ថាទីបី ។

ឯមនុស្សទីបួន ជាជនមានខ្លួន ដែលប្រើសម្ដី
បញ្ចើចបញ្ចើ សរសើរឥតន័យ នោះកុំគប្បី
សេពគប់ឱ្យសោះ ។

ត្រូវចេះស្វែងយល់ ឱ្យដឹងឫសគល់ នៃភាពត្រង់ស្មោះ
ដោយប្រើប្រាជ្ញា កាត់យល់ឱ្យអស់ បើមានចន្លោះ
នឹងរស់តម្លៃ ។

បពិត្រព្រះអង្គ សូមប្រិតផ្ចិតផ្ចង់ ប្រតិបត្តិរាល់ថ្ងៃ
នូវវត្តប្រាំ យ៉ាងសែនខ្ពស់ក្រៃ មិនអាចឧបមេយ្យ
ឱ្យបានឡើយណា ។

ទីមួយនិងពីរ ខ្ពស់ជាងជីវី គឺមានមាតា
បិតាផងយើង ថ្កើងក្នុងគ្រួសារ ទីបីលោកថា
ជាភ្លើងប្រើប្រាស់ ។

វិត្រូបាចព្រាយ សូមកុំពាយងាយ លោកជាអម្ចាស់
ទុកជាទីប្អូន សមសួនក្រៃក្រាស់ ជាមនុស្សខ្ពស់ពេកាស់
ស្មើម្ដាយឪពុក ។

ទីប្រាំចុងក្រោយ សំខាន់ពេកាស់ឱ្យ បំបាត់កលិយុគ
ដោយត្រូវតែផ្ទុន ស្នូនពេញបន្ទុក ផ្ទៃនេះថ្ងៃមុខ
រក្សាព្រហ្មើង ។

នេះលោកចង់ថា ត្រឹមតែគ្រួសារ ក៏ត្រូវជញ្ជីង
បើបាត់បង់ហើយ នឹងស្បើយទីពឹង ត្រូវតែឱ្យរឹង
នូវព្រហ្មើងជាតិ ។

សូមចាំជាក់ថា រាស្ត្ររាល់រូបា ត្រូវប្រឹងខ្មីឃ្មាត
រវាំងរក្សា កុំឱ្យឃ្លៀងឃ្លាត អ្វីៗជាជាតិ
សុទ្ធតែព្រហ្មើង ។

គេតែងបរិច្ចាគ មិនខ្លាចលំបាក ទុកជាទីពឹង
អស់អ្វីអស់ចុះ ឱ្យរស់ព្រលឹង ជាតិនឹងបានរឹង
រៀងរាបដរាប ។

កំហុសប្រាំមួយ សូមកុំលើកស្ទួយ ព្រោះវាជាបាប-
កម្មអាក្រក់ក្រៃ នាំផ្លែដុនដាប អនុជសុំប្រាប-
ប្រាមព្រះអង្គថ្លៃ ។

មួយ គឺការផ្ទំ ពីរ ងងុយងំ ខុសអធ្យាស្រ័យ
បី គឺភ័យខ្លាច មិនក្លាព្រះទ័យ មិនគិតរំពៃ
រំពឹងឱ្យគ្រប់ ។

បន្លែទីបួន កុំយកតាមខ្លួន កុំបីសេពគប់
នឹងក្ដីពិរោធ ព្រោះនាំឱ្យងប់- ងុរនៅក្នុងភព
នៃភាពអវិជ្ជា ។

កំហុសទីប្រាំ ទុកជាបាបកម្ម ត្រូវចៀសវាងវៀរ
បោកចេញឱ្យផុត កុំយកជាគ្នា កិច្ចមិនល្អជា
គឺមិនអើពើ ។

ពាបបន្លែនេះ សូមព្រះតម្រិះ ថាជាមនុស្សភ្លើ
គឺជនអស់ចិត្ត ពពេចេះអើពើ ធ្វើក៏មិនធ្វើ
ស្ដីក៏មិនស្ដី ។

វិបត្តិចុងក្រោយ ចាត់តាមលំដោយ ថាមិនគប្បី
គឺភាពដំររក់ តក់ម៉ក់គ្មានន័យ កុំគាប់ព្រះទ័យ
នឹងភាពខ្ជីខ្ជា ។

អ្នករៀនពីរនាក់ បានឡើងដល់ថ្នាក់ ខ្ពស់ស្មើៗគ្នា
តែម្នាក់នៅល្ងង់ លង់ក្នុងអវិជ្ជា ម្នាក់ទៀតមានងារ
ថាជាអ្នកចេះ ។

អ្នកល្ងង់ឥតសារ គឺអ្នកយល់ថា ខ្លួនមានចំណេះ
លើសអស់ទាំងគេ ថាគេមិនខ្មែះ ឃើញខ្លួនឯងចេះ
ឥតសេសសល់អ្វី ។

មានចិត្តអន្ធពាល តាំងដាលតិះដៀល ដល់ធម៌វិន័យ
និងការអប់រំ ល្អៗប្រពៃ បីដូចមនុស្សព្រៃ
ព្រើលក្នុងសកល ។

អ្នកចេះប្រាកដ តែងតែសន្មត ពេញដោយកង្វល់
ថាខ្លួននៅល្ងង់ មិនទាន់ចេះដល់ រួចប្រឹងខ្វាយខ្វល់
រចល់សូត្ររៀន ។

បន្តស្វែងរក យកចំណេះមក ព្រោះខ្លួននៅឃ្លាន
បង្កើនវិជ្ជា ជាក្បួនជាស្ពាន ភាវនាសីលទាន
ទើបគ្មានទុក្ខភ័យ ។

នាយឥតពំនិត ពាប់នឹងទូលពិត មូលបង្អាច់ន័យ
គាប់នឹងលុតក្រាប ថាស្មោះប្រពៃ នេះហើយវិន័យ
នៃនាយអវិជ្ជា ។

បពិត្រព្រះអង្គ សូមទ្រង់ផ្ចិតផ្ចង់ តាមគាប់ទយា
វិចារណ៍ឱ្យច្បាស់ ជម្រះវេរា រួចទ្រង់ម៉ឺម្នា
ព្រះសណ្ដាប់គ ។

# ច្បាប់ព្រះវិធូរ (តនិងចប់)

បទព្រហ្មគីតិ

បពិត្រព្រះជេដ្ឋា ក្សត្រិយ៍ថ្លៃថ្លាសែនបវរ
អ្វីជាអាក្រក់ល្អ សូមលើកករថ្វាយបង្គំ ។
ទូលព្រះនរិន្ទឫទ្ធិ បរមបពិត្រដ៏ជាធំ
គុណធម៌សែនឧត្តម ប្រាំមួយយ៉ាងដ៏ប្រពៃ ។
ដំបូង **សច្ចធម៌** ជាគុណល្អខ្ពស់លលៃ
ការពិតត្រឹមត្រូវន័យ ជនគ្រប់វ័យតែងអបអរ ។
ឯគុណធម៌ទីពីរ នាំភូមិឱ្យខ្ចារខ្ចរ
គឺ **សប្បុរសធម៌** ដែលនាំនរជនឱ្យបាន ។
កេរ្តិ៍ឈ្មោះពីរោះល្បី លើដែនដីសព្វទីឋាន
កិត្តិយសជាដើមដាន នោះនឹងបានខ្ពស់ឥតប្រៀប ។
ទីបីជាជោគជ័យ លោកឱ្យន័យ **វិរិយភាព**
ព្យាយាមរ៉ាប់រងរៀប មិនត្រូវដំអក់ឬខ្ជិល ។
ទីបួនគឺ **មេត្តា** សូមជេដ្ឋាទ្រង់ពិតពិល
រាប់អានឥតបន្ទិល ដោយករុណាអស់សព្វសត្វ ។
ទីប្រាំគឺ **សន្ដោស** រឿងរឱសតូចតាចក្ដាត់
កុំយកមកបង្អាត់ បង្កឱ្យក្ដៅក្រហាយ ។

ប្រាំមួយ **ធម៌ខន្តី** ជាវិន័យល្អសព្វសាយ
ទ្រាំអត់ត្រួតព្រះកាយ ព្រះចិន្តាឱ្យស្ងៀមស្ងប់ ។
ទ្រង់ខ្វាល់ពីទ្រង់ឆោត ក្តីក្រេវក្រោធឆាប់បញ្ចប់
ខឹងខុសខូចខាតសព្វ នាំឱ្យថប់ព្រះទយា ។
គុណធម៌មានប្រាំបី ជាការបីព្រះរាជា
ដែលនាំជោគជយា ជាមាតានៃធម្មគុណ ។
មួយ គតិបណ្ឌិត ប្រាកដពិតថ្លៃពេកពន់
នាំទៅអ្វីជាគុណ ល្អលើសលន់លើលោកិយ ។
ទីពីរ លោកសំដៅ ថាវង្សផៅសែនពិសី
ពិសេសសព្វសេចក្តី ឥតបីដាមដោយទុច្ចរិត ។
ទីបីជាពព្រោ ពីស្គាល់ការត្រួតព្រាកិត្ត
វិញ្ញាណប្រាំជាក៏ប៉ិត ដ្បិតជាដើមចមអវិជ្ជា ។
ទីបួន ជាកិត្តិយស ពីខ្ពង់ខ្ពស់ខាងវិទ្យា-
សាស្ត្រសព្វសែនសោភា ត្រូវសិក្សាជាប់ជានិច្ច ។
ទីប្រាំ ភាពអង់អាច មិនត្រូវខ្លាចគៀចកែគេច
ត្រូវក្លាសព្វសាច់គ្រេច តែកម្តេចភាពព្រហើន ។
ប្រាំមួយ ឱ្យរាបសា កាយកិរិយាកុំភ្លើតភ្លើន
កុំប្រើសម្តីផ្តើន ច្រឡោងខាមនាំថោកបួក ។
ប្រាំពីរ គឺដាក់ទាន តាមក្រមានជាបាយទឹក
លុយកាក់ដាក់ល្វាចព្រឹក ដោយសង្កេតឱ្យហ្មត់ចត់ ។

មិនត្រូវដាក់ឆ្នុងៗ ដាក់ពេញល្បៀងខុសបែបបទ
សង្កេតមើលអ្នកអត់ ឱ្យប្រាកដសឹមប្រគល់ ។
ធម៌ក្រោយនេះជាស្នូល ត្រូវចាត់ចូលជានិម្មល
ត្រូវត្រិះរិះឱ្យយល់ គឺធម៌កតញ្ញុតា ។
ស្តូបព្រះអង្គទ្រង់ជ្រាប ដោយរៀងរាបទាំងចាត់ថា
ជាធម៌នៃក្សត្រា រាស្ត្ររាជការសព្វមន្ត្រី ។
ខ្លួនមនុស្សអាចប្រៀបបាន គេហដ្ឋានមានជាន័យ
សសរកន្លោងកើ បង្គួចប្រាំបួននិត្យនឹង ។
មានសាក្សីប្រាំនាក់ រាយប្រទាក់ជាទីពឹង
និងហានដួងព្រលឹង ជាអធិបតីផង ។
ទូលបង្គំយល់ថា ព្រះករុណាឆ្លាតកន្លង
អាចយល់ន័យនេះផង យ៉ាងច្បាស់ច្បងក្នុងព្រះទ័យ ។
អកុសលដប់ប្រការ ត្រូវចាត់ថាមិនប្រពៃ
ព្រោះនាំបរាជ័យ ផ្ទុយពីន័យនៃគុណធម៌ ។
មួយ គឺពុលឬញៀន ញៀនព្រោះឃ្លានឥតគិតក្រ
អាក្រក់ប្រែជាល្អ ខ្មៅជា ស ឥតក្រែងខ្លាច ។
ញៀនគួរឱ្យសោកស្តាយ ឱ្យអន្តរាយ គឺអំណាច
បង្កកាយកោងកាច អួតអង់អាចអើអញឯង ។
មិនមានក្តីអ៊ឹងម៉ាត់ មិនប្រយ័ត្នយូរអង្វែង
ធ្វើអ្វីឥតពិតក្រែង ស្តែងជាទីពីរដោយយ៉ាង ។

មនុស្សក្នុងអម្បូរថោក    កើតមានមកឈ្មោះកខ្វក់
ទុយិសកករល្អក់    តែងតែដក់នៅជាប់លាប់ ។
ខ្លះច្រណែន ដៀត ជេរ    ព្រោះឃើញគេបរិបូណ៌ទ្រព្យ
សម្បត្តិសប្បុរសពោប់    ពូជខ្ពស់ភ្ជាប់ម៉ែងវិជ្ជា ។
ល្អាទីសសុភម-    ង្គលរួមទាំងវាសនាផ្កា
ព្រោះឃើញគេល្អជា    កបជយាពេញកិត្តិយស ។
លោកចាត់ជននេះថា    ជាមនុស្សាមិនខ្ពង់ខ្ពស់
សែនទាបថោកកេរ្តិ៍ឈ្មោះ    នេះជាព្រោះតែមិនបាន ។
កុំពុលនឹងសម្បត្តិ    ត្រូវកម្ចាត់ចេញពីប្រាណ
អកុសលមួយឱ្យបាន    គឺការពុលនឹងអំណាច ។
ពុលទាំងពីរប្រការ    ជាកិរិយាគួរខ្ពើមខ្លាច
ព្រោះវាឱ្យកោងកាច    ចិត្តកំណាចជាងឆ្កួតស្រា ។
កុំល្មៀនចង់បានរុង-    រឿងលើសលប់លើអាត្មា
ចង់ខ្ពស់ហួសមាត្រា    នាំប្រាជ្ញាឱ្យឱនអាប់ ។
មិនអាចត្រួតត្រាចិត្ត    ធម៌ក្រមក្រឹត្យក៏លែងស្តាប់
អ្នកនោះមុខជាឆាប់    បានរងរ៉ាប់បរាជ័យ ។
ដូចចន្ទក្នុងរនោច    នឹងហិនហោចបាត់សួស្តី
វិញ្ញាណសែនប្រិមប្រិយ    គួរតប្បីយើងជម្នះ ។
ពោលគឺមិនត្រូវស្ងួន    ដោយតាំងខ្លួនជាកញ្ជះ
តែត្រូវប្រឹងជម្រះ    ចិត្តឱ្យឈ្នះវិញ្ញាណប្រាំ ។

វិញ្ញាណជាសត្រូវ ដែលស្ថិតនៅជាប្រចាំ
ក្នុងប្រាណយ៉ាងត្រែងត្រាំ សូមទ្រង់ចាំទុកជាផ្លូវ ។
ឈ្នះវិញ្ញាណទ្រង់សិន មុនភូមិន្ទឈ្នះសត្រូវ
ឈ្នះរបស់មនុស្សទូទៅ ទើបដល់នូវឈ្នះចម្បាំង ។
ព្រះអង្គនឹងផ្តើងផ្តាន មិនអាចមានការប្រឆាំង
ខន្តីជាកម្លាំង ការប្រយ័ត្នជាទីពឹង ។
ខ្លួនមនុស្សដូចរថថ្មី មានសារថីជាព្រលឹង
អស្សតរអាចប្រៀបនឹង វិញ្ញាណទាំងប្រាំនោះនៃ ។
បើសេះពូកែស្ទាត់ ពិតប្រាកដទើបប្រពៃ
អាចនាំព្រះនរបតី ព្រះដំណើរដោយសប្បាយ ។
បើអស្សតរមិនស៊ាំ មិនមួនមាំនាំខ្វល់ខ្វាយ
ព្រោះមិនស្រួលព្រះកាយ ទោះជិតឆ្ងាយទៅមិនដល់ ។
ការប្រួពព្រោសម្តី ជាករហើយកិច្ចត្រូវខ្វល់
ទោះពិបាកសោតសល់ ក៏កមលវិញ្ញជន ។
អាចឈ្នះបានដោយងាយ ការសម្ពាយមិនស្រាលធ្ងន់
ប្រើវាចាផ្អែមទន់ អាចពិគ្រោះបានហៃហូរ ។
ការប្រើសម្តីល្អ ចិត្តស្មោះសរមិនផ្លាស់ប្តូរ
នាំឱ្យបានបរិបូណ៌ នូវន័យល្អច្រើនប្រការ ។
សម្តីច្រឡោងខាម ដិតដូចដាមជាប់ចិន្តា
ជាមូលហេតុប្រាប់ថា ពូជពង្សសែនថោកទាប ។

អស់រុក្ខជាតិទោះបី ពេកាប់ក្រើឱ្យស្មើរាប
ឱ្យដើមនៅទាប១ គង់ដុះត្រៀបលាស់វិញបាន ។
តែសម្ដីអាក្រក់ ដូចព្រួញឆក់សែនសាមាន្យ
ធ្វើឱ្យឈឺសព្វប្រាណ ព្រោះវាបានមុតជាប់នៅ ។
ធម្មតាព្រួញបន្លា មុតកាយាមិនដែលជ្រៅ
អាចឆ្កឹះដកចេញទៅ វាមិននៅនាំឱ្យមោះ ។
មុតជ្រៅចូលឱរា គឺវាចាអសុរោះ
ច្រឡោងខាមនាំឈ្លោះ មិនអាចដោះឆ្កឹះចេញបាន ។
សម្ដីអសុរោះ ធ្វើឱ្យមនុស្សឈឺខ្លាំងថ្កាន
ក្ដៅក្រហាយសព្វប្រាណ ទាំងយប់ថ្ងៃឥតបីលស់ ។
អ្នកមានការអប់រំ ឫកឧត្ដមវង្សខ្ពង់ខ្ពស់
តែងវៀរពាក្យអសុរោះ ច្រឡោងខាមមិនគប្បី ។
មួយសោតគឺមនុស្សណា ដែលទេព្ដាចារទុកវៃ
ឱ្យជួបបរាជ័យ មិនខុសអ្វីពីបាត់ញាណ ។
ជននេះតែងងប់ងុរ ដោយបំពុលចិត្តឱ្យហ៊ាន
វៀរចាកចោលសីលទាន សួគ៌និព្វានទុកជាខ្នាំង ។
លោកថាប្រាជ្ញាញាណ តែងកើតមានការប្រឆាំង
ដែលនាំឱ្យមោហ៍បាំង ទើបបរាជ័យតាមជាប់ ។
ត្រូវជម្រះចិន្ដា ឱ្យជ្រះថ្លាពីទម្លាប់
អាក្រក់មិនគួរគាប់ ដោយស្នេហ៍ជាប់សព្វសត្វលោក ។

ទេព្ដាមិនរក្សា នរជនណាដែលស្មោកគ្រោក
មិនគិតដល់សត្វលោក គិតយល់យោគតែខ្លួនផ្ទាល់ ។
ប្រយោជន៍ចូលតាមខ្នាត សមាមាត្រជាសម្គាល់
គឺខ្នាតយុត្តិធម៌ និងសីលធម៌ជាប្រក្រតី ។
មិនដែលមានទេព្ដា ជួយជនអាក្រក់អប្រិយ
ទុច្ចរិតអន្យតិរ្ថិយ ធ្វើឫស្ដីតាមទំនើង ។
គេអាចស្គាល់មាសសុទ្ធ បានដោយដុតសាកនឹងភ្លើង
ស្គាល់ពូជពង្សថ្កុំថ្កើង តាមឥរិយាបទថ្លៃថ្នូរ ។
ស្គាល់ជនមានចិត្តស្មោះ- ស្ម័គ្រសប្បុរសមិនផ្លាស់ប្ដូរ
ចិត្តនឹងដូចទឹកហូរ ដោយសារចរិយាសម្បត្តិ ។
ស្គាល់មនុស្សដែលអង់អាច មិនខ្លបខ្លាច តែក្លាក្លាត់
គឺអ្នកចេះប្រយ័ត្ន ពេលអហេតុកភ័យ ។
ពេលមានគ្រោះទុរ្ភិក្ស ខ្វះបាយទឹក តែវិន័យ
នៅគង់ដូចប្រក្រតី នោះខន្តីស្តែងច្បាស់ច្បង ។
ពេលដែលមានអាសន្ន- អន់ក្រធ្ងន់នាំសៅហ្មង
ជាពេលល្អកន្លង ឱ្យស្គាល់ពិតនូវមិត្តភក្ដិ ។
ការគោរព សក្ការ ការសិក្សា ទាន តបៈ
សន្ដោស ធម៌សច្ចៈ ក្តីមេត្តា និង តុស្ដិ ។
សូមទ្រង់ចាំចុះថា នេះជាមាគ៌ាប្រាំបី
ដែលនាំមនុស្សប្រុសស្រី ទៅរកយុត្តិធម៌ពិត ។

មាតាបូនខាងក្រោយ　　នឹងនាំឱ្យអង្គទ្រង់ឫទ្ធិ
ឆ្លងផុតភាពងងឹត　　គឺពិតជាមហាបុគ្គល ។
ឯធម៌បូនខាងដើម　　ដ៏សែនផ្ដើមជាមង្គល
ដែលអាចជាឫសគល់　　នៃមហិច្ឆតាផ្ទាល់ខ្លួន ។
ធ្វើការឱ្យហើយគ្រប់　　កុំទុកយប់ ត្រូវថែថ្នូន
បម្រើការដេកពួន　　កម្លាំងស្ងួនសម្រាប់ស្អែក ។
ធ្វើហើយមុនផែនការ　　ជាកិរិយាល្អអនេក
មួយឆ្នាំត្រូវបែងចែក　　ត្រឹមជាផ្នែកប្រាំបីខែ ។
នោះយើងនឹងអាចឆ្លង　　វស្សាផងមិនបាច់បែរ
ព្រោះផុតកិច្ចត្រូវកែ　　ឯក្ដីស្នេហ៍ចាំងចិញ្ចែង ។
ត្រៀមសព្វអ្វីទាំងអស់　　កុំឱ្យខ្វះទាន់នៅក្មេង
បើបានអាយុវែង　　នឹងខែងវែងពេលជរា ។
កិច្ចសំខាន់ក្រោយគេ　　កុំធ្វេសទេក្រែងមានពៀរ
ពីបុណ្យ ទាន ភាវនា　　ជាបោតាទៅជាតិក្រោយ ។
ត្រូវចេះស្រាយចំណង　　ដែលបានចងចិត្តឱ្យខ្សោយ
ត្រូពព្រាកុំបណ្ដោយ　　ដោយកាន់យកឧបេក្ខា ។
នេះករណីទីមួយ　　ជាជំនួយត្រូតតព្ភា
ត្រូវត្រង់ត្រាប់សាសនា　　ឱ្យបានត្រឹមត្រូវប្រាកដ ។
ត្រូវរៀនឱ្យឃើញថា　　ការទិតៀនតាមសន្ទត
សរសើរតាមបែបបទ　　ជាអាត្មនរបស់ខ្លួន ។

ដូច្នេះកុំវាយបក ឆ្ពោះទៅរកការតុំកួន
ការបន្ទោសដោយជូន តែត្រូវស្ងួនកុំបីលុះ ។
មនុស្សមានឧបេក្ខា លោកយល់ថាទោះរងគ្រោះ
នឹងការស្តីបន្ទោស អ្នកស្តីនោះនឹងឈឺចិត្ត ។
តែងបង់នូវសីលធម៌ ដែលល្អៈល្អជាក្រមក្រិត្យ
ពុំអាចមិនឹងផ្តេកផ្តិត និត្យនៅនឹងឧបេក្ខា ។
សូមកាត់ឱ្យជៀវជាក់ ថាមិត្តភក្តិសែនថ្លៃថ្លា
កុំបែកបាក់ឡើយណា តែបង្ការជនអន្ធពាល ។
ឬកចោកហើយព្រហើន សម្តីផ្តើនដាលពាសវាល
កុំបែងប្រែងជំទាស់ ជាពួកពាលពេញស៊ុខ្ចង ។
អស់រោះដោយវាចា ដូចបន្លាមុតជាប់ទ្រូង
សាច់សរសៃបេះដូង ឱ្យរងគ្រោះមួយជីវិត ។
បើទ្រង់ចៀសមិនបាន សូមក្សត្រិយ៍ក្សាន្តគន់គួរគិត
បន្ទោលតែការពិត ជាជាងបញ្ចើចបញ្ចើ ។
បើសោជាចាំបាច់ ព្រោះសម្រេចតាមដំណើរ
ត្រូវពោលពាក្យសរសើរ នោះត្រូវប្រើសីលធម៌ផង ។
សត្វលោកកើតហើយស្លាប់ ព្រោះត្រូវជាប់ដោយចំណង
កើតស្លាប់ ស្លាប់កើត ផង នៅក្នុងវាលវដ្តសង្សារ ។
តែងរងនូវកម្មផល ដាបដូចដល់ដោយធម្មតា
គេចមិនរួចឡើយណា ពីការរងក្តីសោកស្តាយ ។

ទាំងនាំឱ្យគេសោក និងនាំយកក្ដីសប្បាយ
ទុក្ខរីករាយស្រស់ស្រាយ សម្បូរណ៍បែបនិងក្រខ្សត់ ។
ទាំងចំណោញនិងខាត ទោះឱកាសតាមបែបបទ
ក្រ ឬមាន ឬអត់ លោកកំណត់ទុកមកស្រាប់ ។
លុះដល់ពេលចុងក្រោយ កំណត់ឱ្យ គឺក្ដីស្លាប់
ម្នាក់ៗត្រូវតែរ៉ាប់- រងក្ដីស្លាប់រាល់រូបា ។
កំហឹងជាសត្រូវ នាំចូលផ្លូវស្រោសបន្ទា
ពុំនោះដូចសុរា ល្វីងជូរចត់ហាងហើយហឺរ ។
វានាំផលវិបាក សែនគោកយ៉ាកចាកសព្វសីល
ឈឺច្រងាប់ច្រងិល ពេទ្យគ្រូសិល្ប៍មើលមិនជា ។
កំហឹងជាជំងឺ គួរឱ្យព្រឺស្មើកម្មពៀរ
ព្រោះវាមិនកើតជា ចេញពីសរីរាង្គយើង ។
មនុស្សឧត្ដុង្គឧត្ដម តែងខិតខំតាស់រំលើង
រំលស់រំលត់ភ្លើង កំហឹងនេះឱ្យអន្តរាយ ។
នេះគតិបណ្ឌិត ប្រសើរពិតដូចបរិយាយ
មនុស្សខ្ពង់ខ្ពស់មិនស្ដាយ មិនគបកាយនឹងវិញ្ញាណ ។
មហិច្ឆតាខ្លាំងហួសពេក គួរកុំត្រេក កុំប្រឹងហ៊ាន
ទ្រាំអត់ កុំឱ្យមាន ការនិយាយស្ដីច្រើនហួស ។
បើស៊ីកុំតាមឃ្លាន ស៊ីតាមមាននាំឱ្យជ្រួស-
ជ្រុលដូចត្រូវរបួស កុំនាំគ្រោះព្រោះតែឃ្លាន ។

បើខឹងឱ្យខំទប់- ទល់ហើយឈប់កុំបំពាន
មិនត្រូវផ្ដាច់វិញ្ញាណ តាមការឃ្លានក្ដីរីករាយ ។
ពោះវៀនគ្មានរបៀប មិនរៀងរាបព្រោះពាយងាយ
បញ្ញាត្រូវរំលាយ ប្រាំមួយនាយជាអាវុធ ។
សែនសាហាវពេកក្រៃ ព្រោះសព្វថ្ងៃវាតែងមុត
ដោយមិនបាច់ប្រយុទ្ធ វាមុតឱ្យស្លាប់ទាំងរស់ ។
កម្លាំងក្សត្រិយ៍មានប្រាំ សូមចងចាំទាំងប្រាំឈ្មោះ
មានទាំងទាបទាំងខ្ពស់ មិនមានមោះទើបគ្រប់គ្រាន់ ។
កម្លាំងទាបបំផុត គឺអាវុធយុទ្ធភណ្ឌ
ទីពីរ ពឹងពាក់ព័ន្ធ ពួកសេនាដែលល្អគាប់ ។
ទីបី គឺសេដ្ឋកិច្ច អាចសម្រេចជារាជទ្រព្យ
បើអាចចម្រើនជាប់ នឹងល្អគាប់ដោយវាសនា ។
ទីបួន សន្តិវង្ស គឺពូជពង្សទ្រង់ថ្លៃថ្លា
បិតា បុព្វបិតា មាននាមថាវីរក្សត្រិយ៍ ។
កម្លាំងខ្ពស់បំផុត សែនវិសុទ្ធវិសេសក្កាត់
ជាមហាគុណសម្បត្តិ លោកចែងចាត់ថា **ប្រាជ្ញា** ។
បន្ថែខាងក្រោយនេះ ត្រូវរេរិះថាជាមហា
សម្បត្តិពេញត្រូវការ គឺប្រាជ្ញាឃ្លាសវាងវៃ ។
បុគ្គលអស់តណ្ហា គឺជនណាចេះលកលៃ
ឱ្យវិញ្ញាណរំពៃ គិតមមៃឃើញស្មើគ្នា ។

ឃើញភក់ មាស និង ថ្ម　សុទ្ធតែល្អអាចចាត់ជា
ប្រយោជន៍ផ្សេងៗគ្នា　តម្លៃវាសុទ្ធតែគាប់ ។
ត្រូវទុកការទិតៀន　ជាមេរៀនតាមទម្លាប់
មិនត្រូវចងចិត្តជាប់　យកគួរគាប់ពាក្យសរសើរ ។
គុណធម៌ទាំងប៉ុន្មាន　ជាដើមដាននៃដំណើរ
ជាប្រេងសម្រាប់ប្រើ　ចាក់ទៅលើអណ្ដាតភ្លើង ។
ជាភ្លើងក្ដីរុងរឿង　ភ្លឺព្រឿងៗឱ្យឆេះឡើង
ពីឃើញភាពថ្កុំថ្កើង　ចម្រើនឡើងរៀងរាល់ថ្ងៃ ។
របស់ទាំងអំពើល្អ　ជាគុណធម៌បវរក្រៃ
ជាធម៌បរមចិន្ត្រៃយ៍　តែងសព្វសាយរីករាលដាល ។
ឯសេចក្ដីឈឺចាប់　ត្រូវរងរ៉ាប់ទោះធ្ងន់ស្រាល
ជារឿងអន្តរកាល　រួមទាំងក្ដីរីករាយផង ។
អ្វីដែលកន្លងបាត់　សូមកម្ចាត់ចោលជាម្ដង
ត្រូវភ្ជាប់វិញ្ញាណផង　ទៅនឹងធម៌អចិន្ត្រៃយ៍ ។
លុះដល់ចាស់ជរា　យើងគ្រប់គ្នានឹងក្សិណក្ស័យ
លាលោកធ្លាប់អាស្រ័យ　ដោយគ្មានអ្វីយកទៅតាម ។
ក្រៅតែពីកិត្តិយស　និងកេរ្តិ៍ឈ្មោះជាប់ជាស្នាម
អកុសលដែលត្រូវច្បាម　គឺបាបកម្មរបស់ខ្លួន ។
ត្រូវកាន់យុត្តិធម៌　ដោយស្មោះសរស្ម័គ្រខ្ជាប់ខ្ជួន
កិត្តិយសជាច្បាប់ក្បួន　ត្រូវតែស្ងួនជាប្រចាំ ។

ទន្លេនៃជីវិត អាចគិតដូចវិញ្ញាណប្រាំ
កំហឹងជាត្រីឆ្លាម ឯតណ្ហាជាក្រពើ ។
ទីមានទឹកកួចវង់ តម្រូវអង្គឱ្យប្រឹងរើ
ហែបហែលឆ្លងកាត់លើ នោះគឺវាលវដ្តសង្សារ ។
ឯទន្លេព្រលឹង ជាទីពឹងនៃអាត្មា
គឺគុណសម្បត្តិសាសនា មានការលាងជម្រះបាប ។
សច្ចធម៌ប្រៀបដូចទឹក ល្អពន្លឺកមិនសូន្យសាប
ត្រូវងូតទឹកលាងបាប នៅក្នុងទន្លេពិសិដ្ឋ ។
ឯច្រាំងមានន័យថា ការត្រួតត្រាត្រង់ផ្លូវចិត្ត
ក្តីសប្បុរសសុចរិត ជាកំហិតថារលក ។
អ្នកមានយុត្តិធម៌ពិត តែងរិះគិតរកជម្រក
ដោយបោះបង់ពន្លក នៃតណ្ហាឱ្យស្រឡះ ។
ជនល្អតែងប្រព្រឹត្ត យ៉ាងម៉ឺងម៉ាត់ឥតប្រែផ្លាស់
នូវធម៌នេះយ៉ាងច្បាស់ ព្រោះជាឧត្តមបុគ្គល ។
វិញ្ញូជនថ្លែងថា ក្តីមរណាយើងត្រូវយល់
ថាកើតក្នុងមណ្ឌល មានឫសគល់ពីអវិជ្ជា ។
ដូច្នេះអមតភាព សូមទ្រង់ជ្រាបជាមាតិកា
បំបាត់អស់អវិជ្ជា គឺបំបាត់សេចក្តីស្លាប់ ។
តាមធម្មតាសត្វខ្លា តែងស្រវាស្ទុះចូលចាប់
សព្វសត្វយ៉ាងប្រញាប់ ដើម្បីរាប់ជាចំណី ។

ប៉ុន្តែសេចក្តីស្លាប់ មិនអាចគ្រាប់ដូចខ្លាអី
ព្រោះជាអរូបិយ មិនមានអ្វីអាចបញ្ជាក់ ។
ខ្លះឃើញទ្រង់ទ្រាយថា ម្ចាស់មរណាគឺយមៈ
ន័យនេះជាប់ព័ន្ធពាក់ នឹងភាពខ្សោយនៃអារម្មណ៍ ។
ឯយមរាជនោះឯង សូមសម្តែងដោយចំៗ
ទូលថ្វាយក្សត្រិយ៍ឧត្តម ពីរូបពិតរបស់វា ។
រូបមួយ គឺកំហឹង ទីពីរហ្នឹង គឺអវិជ្ជា
ទីបី គឺអភិជ្ឈា ជាក្តីស្លាប់ក្នុងខ្លួនមនុស្ស ។
ន័យនេះសំខាន់ណាស់ ត្រូវយល់ច្បាស់ចាក់ឱ្យធ្លុះ
បំណាច់កើតជាមនុស្ស គួរស្គាល់ខុសត្រូវខ្លួនឯង ។
មហិច្ឆតាដែលខ្លាំងជ្រុល អាចឱ្យពុលចិត្តឥតក្រែង
ឱ្យប្រព្រឹត្តស្តែងៗ នូវអយុត្តិធម៌ផង ។
កំឡុងជនបែបនេះ លោកតែងរិះគិតហ្មត់ហ្មង
ថាគ្មាននរណាផង ឈ្នះធម្មជាតិពិតនៃខ្លួន ។
ព្រោះតែមានមោហ៍បាំង ដូចចោរខ្លាំងលួចលាក់ពួន
គ្មានអ្វីជួយថែថូន ត្រូវធ្លាក់ខ្លួនចូលអវិចី ។
ដោយមានតែវិញ្ញាណ ដូចជាព្រានសែនអប្រិយ
ផ្ទុយជាប្រក្រតី នេះជាក្តីស្លាប់មុនងាប់ ។
រីឯអំពើល្អ ផលនោះក៏ល្អគួរគាប់
មិនអាចឱ្យអភ័ព្វ ត្រូវបានភ្ជាប់ទៅសុគតិ ។

មនុស្សសាងអកុសល ឈានមិនដល់ព្រះព្រហ្មា
មិនអាចផ្ដាច់មាតិកា ជាលោកិយនោះបានទេ ។
បើមិនស្គាល់ខ្លួនឯង កុំបាច់ស្វែងរកស្គាល់គេ
ធ្វើនេះខុសទទេ ត្រូវគិតគ្នេរឱ្យស្រឡះ ។
វិជ្ជាពិតជាក់ស្ដែង គឺខ្លួនឯងស្គាល់ឱ្យច្បាស់
ទើបអាចរើបម្រះ ពីខ្លៅនិងអវិជ្ជា ។
ចេះច្រើនមិនអួតអាង ឡឹតឡើងចាងឈ្លើយឬកពា
ចេះតិចតួចពិតជា អួតខ្វះខ្វាវព្ញដូចស្គរ ។
កុំតាំងចិត្តរាយមាយ កុំនិយាយពាក្យភូតភរ
ពាក្យសព្យត្រូវសាទរ ទើបក្ដីល្អចេញជាក់ស្ដែង ។
អ្នកចង់ឱ្យគេកោត រហូតឆោតលើកខ្លួនឯង
អួតអាងឥតពិតព្រែង នឹងបាត់សែងមិនលែងឡើយ ។
បើអារម្មណ៍លម្អៀង អ្វីមិនទៀងថាជាត្រើយ
នឹងនាំវិញ្ញាណឆ្លើយ- ឆ្លងគោលការណ៍ខុសមាតិកា ។
អាត្មនមិនបរិសុទ្ធ អន់បំផុតមិនគាប់ជា
តែងស្វែងរកមាយា- ការគ្មានប្រាកដនិយម ។
អ្វីល្អលើលោកិយ គួរគប្បីផ្ដល់ស្វាគមន៍
ជាសក្ការៈធំ គួរអភិរមតាមទ្រព្យធន ។
នៅក្នុងចិត្តមនុស្សា មានតណ្ហាកើតឡើងមុន
កំហឹងយកជាទុន កាមមុច្ឆាបន្ដគ្នា ។

អកុសលកម្មទាំងបី ជាករណីនៃកម្មពៀរ
ដែលរុញខ្លៅអវិជ្ជា ឱ្យស្ទុះស្ទាយកក្តីស្លាប់ ។
អវិជ្ជាជាយមៈ មិនត្រពាក់ឬស្ទុះចាប់
ឧត្តុបជនចំណោប់ ដែលបង្ក្រាបអាត្ម័នបាន ។
នៅក្រោមឥទ្ធិពល វិជ្ជាផ្ទាល់ជាកល្យាណ
ក្តីស្លាប់ដ៏សាមាន្យ នឹងបាត់ដានដោយឯងៗ ។
កម្មវត្ថុតបៈ សូមចមចក្រទ្រង់ស្វះស្វែង
យល់តាមភាពជាក់ស្តែង ថាអ្វីចែងខ្ពស់កន្លង ។
មិនអាចរកវាចា បកខ្លឹមសារត្រូវឡើយហោង
ព្រោះហួសអារម្មណ៍ផង ដែលត្រូវឆ្លងឆ្លើយជាបេ ។
តបៈមិនត្រឹមថា ការត្រួតត្រាសម្តីទេ
អ្វីសំខាន់ជាងគេ គឺត្មាន់ត្មេរត្រួតត្រាចិត្ត ។
លោកឃើញការលះបង់ ប្រាំមួយអង្គសែនពិសិដ្ឋ
បណ្ឌិតតែងស្នេហ៍ស្និទ្ធ កៀកកើយកិតឥតបីភោយ ។
ទីមួយ កុំជញ្ជឹង ពិសោធនឹងក្តីសប្បាយ
រីករាយទាំងចិត្តកាយ ក្នុងសម័យរុងរឿងក្តាត់ ។
ទីពីរ ត្រូវលះបង់ បំពោងត្រង់គុណសម្បត្តិ
ដែលចេញពីការចាត់- ចែងប្រតិបត្តិផ្អែកសាសនា ។
មានសូត្រធម៌ព្រោះព្រំ ទាំងគួបផ្សំគ្រឿងសក្ការ
បូជាថ្វាយទេវតា កុំប្រាថ្នាអ្វីជាផល ។

ទីបី គឺតណ្ហា បានដល់ការចៀសកិច្ចកល
លោកិយកុំឱ្យសល់ ដោយលែងខ្វល់ក្នុងហប្វទ័យ ។
ទីបួន មិនបណ្តោយ អាត្មានឱ្យរងទុក្ខភ័យ
ព្រួយព្រោះបរាជ័យ លើកិច្ចអ្វីរបស់ខ្លួន ។
ទីប្រាំ សូមប្រាប់ប្រាម ជាការហាមយ៉ាងខ្ជាប់ខ្ជួន
ពីប្រពន្ធកូនខ្លួន ឬអ្នកជាទីស្នេហា ។
ត្រូវតែមកុំទទួច សុំងោចៗអ្វីឡើយណា
ត្រូវគិតក្នុងចិត្តថា ជាកិរិយាមិនគួរគាប់ ។
ទីប្រាំមួយនោះមាន ការធ្វើទានតាមទម្លាប់
ដោយត្រូវត្រិះរិះជាប់ ជនភោគប្បីគួរឱ្យ ។
ការអនុវត្តបរិសុទ្ធ ល្អបំផុតមិននាំធ្លោយ
មិនបណ្តែតបណ្តោយ លោកឱ្យហៅព្រហ្មចារ្យ ។
ពើពាក្យនេះកោនន័យ តាមឧបមេយ្យដូចម្តេចម្តា
អនុវត្តព្រហ្មចារ្យ គឺស្វែងរកសច្ចធម៌ ។
បើបានដល់ទាំងពីរ ព្រះភូមិត្រូវសាទរ
ព្រោះវាជាគុណធម៌ ឱ្យយល់ល្អច្បាស់កន្លង ។
សាងខ្លួនឱ្យបរិសុទ្ធ អាចឆ្លងផុតក្តីសៅហ្មង
ជាបណ្តិតពិតហោង ល្អតហ្មងដូចកូនក្មេង ។
នេះជាតបៈខ្ពស់ កបកិត្តិយសលែងវង្វេង
អាចលេចឡើងទន្ទេង ព្រោះជាព្រេងល្អសោតសល់ ។

ហាក់ដូចលោកប្រទាន ថាយើងឈានឆ្ពោះទៅដល់
ព្រះព្រហ្មជាសកល- លោកដ៏ធំគួរកោតកើយ ។
ព្រះព្រហ្មជាទេព្ដា ធំអស្ចារ្យពិតមែនហើយ
ដូចសាគរឥតត្រើយ តែស្ដើងជាងមុខកាំបិត ។
គេមើលមិនឃើញសោះ ព្រោះរូបនោះគ្មានអ្វីពិត
តើនៅឆ្ងាយឬជិត ឬមួយគិតថាដូចអ្វី ។
ទោះមេឃ តារាករ ទាំងលំហ ភព ផែនដី
សមុទ្រ ចន្ទរង្សី សុរិយាក្ដី មិនអាចប្រៀប ។
ក្រាបទូលព្រះរៀមច្បង សូមទ្រង់ត្រងត្រាប់ជ្រួតជ្រាប
តំណាលតាមរបៀប រាយរៀងរៀបជាគន្លង ។
ជាគន្លឹះវិជ្ជា ឱ្យមនុស្សម្នាផុតឆ្គាំឆ្គង
កុំបីមើលរំលង តោងរំឭកជាប្រក្រតី ។
នេះឯងច្បាប់វិទូរ ជាអភិរូបសែនពិសី
ពិសេសសព្វសេចក្ដី ក្នុងលោកិយឥតសូន្យសោះ ។
ទាំងនេះជាគុណធមិ សែនល្អះល្អឥតមានខ្ចោះ
ចូរកូនចៅទាំងអស់ សិក្សាចុះសព្វករណី ។

# ច្បាប់ព្រះក្រឹស្នា
# ភគវ័ទ_គីត

បទពាក្យ៧

ច្បាប់នេះមានន័យសម្រាយថា ចម្រៀងទេព្តាលើផែនដី
ដែលព្រះក្រឹស្នារុងរង្សី ពណ៌នាជាន័យមួយសែនជ្រៅ ។
ទ្រង់ដាស់តឿនអរជូនជាប្អូន[១] ដែលអស់ចិត្តសួន្យមិនចង់ទៅ
ប្រហារបងប្អូនជាសត្រូវ ដោយនូវអយ្យកោ គ្រូ និងមិត្ត ។
ថាជ័យជម្នះនេះនឹងផ្ដល់ ផលអកុសលធំពេកពិត
មិនគួររីករាយនឹងជីវិត ទុច្ចរិតបែបនេះសោះឡើយណា ។
ក្រឹស្នាជ្រាបអស់សេចក្ដីនេះ ក៏ទ្រង់ត្រិះរិះដោយប្រាជ្ញា
លួងអរជូនឱ្យប្រែចិន្ដា ទៅជាហានក្លាដូចប្រក្រតី ។
ឱ! អរជូនអើយ! ចូរចាំស្ដាប់ បងនឹងប្រាយប្រាប់ជាសក្ខី
ថាមនុស្សជាតិយើងក្នុងលោកិយ គប្បីថ្លឹងថ្លែងមើលហេតុការណ៍ ។
ត្រូវហ៊ានបោះបង់អ្នកណាម្នាក់ ដែលជាគ្រោះថ្នាក់ដល់ជីវ៉ា
នៃមនុស្សឯទៀតមួយគ្រួសារ ឱ្យចៀសមរណាស្ដារយកសុខ ។
ត្រូវហ៊ានពលីមួយគ្រួសារ ដើម្បីវាសនាមនុស្សមួយស្រុក
បើមានជនបរទេសអុកឡុក មនុស្សម្នាមួយស្រុកត្រូវពលី ។
ដើម្បីឱ្យព្រលឹងជាតិរស់ ពលរដ្ឋទាំងអស់ត្រូវសាមគ្គី
ហ៊ានស៊ូប្ដូរឈាមក្រោលធរណី មិនត្រូវស្ដាយជីវិខ្លួនឡើយ ។

---

១. អរជូនជាព្រះអនុជថ្លៃរបស់ព្រះក្រឹស្នា ។

ប្អូនត្រូវតាំងចិត្តក្លាហានឡើង ដើម្បីតម្កើងកិច្ចជាត្រើយ
ពីការទទួលច្បាំងនេះហើយ ដែលជាចម្លើយត្រូវពិតគន់ ។
ពិតហើយថាគេជាបងប្អូន ជីដូនមួយមែន ទាំងញាតិពន្ធ
និងព្រះអយ្យកោត្រូសិល្ប៍មន្ត្រ សុទ្ធតែជាជនគួរគោរព ។
ប៉ុន្តែប្អូនត្រូវយល់ច្បាស់ថា គេជាបច្ចាមិត្តក្នុងភព
ដែលយើងលែងទទួលគោរព ត្រូវឈប់គិតពីញាតិសិស្សគណ ។
ដែលប្អូនមិនព្រមធ្វើតតេ ជាការធ្វេសរទ្វេមួយយ៉ាងធ្ងន់
ព្រោះតទៅមុខនាំឱ្យស៊ុន គួរគន់គិតគួរកាតព្វកិច្ច ។
ពួកគេខាងនោះពុំមានចិត្ត អាសូរអាណិតយើងបន្តិច
គេកំពុងស្វែងរកកលល្បិច ដើម្បីបំផ្លិចបំផ្លាញប្អូន ។
ដាច់ខាតកុំបណ្ដែតបណ្ដោយ ឱ្យភាពទន់ខ្សោយមកសណ្ដួន
ប្អូនយកក្ដីក្លាហានពីប្អូន ឱ្យអស់សោះសូន្យពីអារម្មណ៍ ។
ត្រូវតាំងចិត្តឱ្យបានក្លាហាន ខំមាត់ទប់ប្រាណប្រឹងខិតខំ
ជម្នះចិត្តរួចរករៀបចំ ខ្លួនឱ្យសក្ដិសមជាទីពឹង ។
បងសូមពន្យល់ប្អូនឱ្យជ្រាប ថាអនន្តភាពនៃព្រលឹង
មិនអាចបាត់បង់សាបសូន្យឈឹង ឬឱ្យជញ្ជឹងគិតយល់បាន ។
មានតែរូបកាយយើងប៉ុណ្ណោះ ដែលរលាយអស់បាត់ពីឋាន
មិនអាចឱ្យរូបរាងអង្គប្រាណ គង់បានក្នុងភាពអចិន្ត្រៃយ៍ ។
ពិតណាស់ថាមនុស្សគ្រប់ជាន់ថ្នាក់ ត្រូវឆ្លងដំណាក់កាលច្រើនក្រៃ
ជីវិតជួបព្រឹត្តិការណ៍រាល់ថ្ងៃ តាំងពីដើមដៃដល់អវសាន ។

ចាប់ផ្ដើមឃើញពន្លឺសុរិយា ត្រូវឆ្លងកុមារភាព ទើបបាន
ធំពេញវ័យ រួចជរាប្រាណ មុនដល់អវសាននៃជីវិត ។
នេះជាដំណាក់កាលធំបួន ប្រចាំខ្លួនខ្ជាប់ខ្ជួន តែមិននិត្យ
ព្រោះជាច្បាប់ធម្មជាតិពិតៗ ចុងក្រោយជីវិតគឺក្ដីស្លាប់ ។
ក្ដីស្លាប់ជាការផ្ដល់ឱកាស ឱ្យព្រលឹងផ្លាស់ទីទៅចាប់
យករូបមួយទៀតយ៉ាងប្រញាប់ ប្អូនត្រូវចាប់ស័ព្ទនេះឱ្យបាន ។
មានតែនៅពេលដែលវិញ្ញាណ ទៅប៉ះពារពានលើដើមដាន
គោលដៅវិញ្ញាណទាំងប៉ុន្មាន ទើបបានទៅជាវេទនារម្មណ៍ ។
គឺកើតភាពក្ដៅនិងត្រជាក់ ដែលពាក់ព័ន្ធប្រាណដោយចំៗ
រីករាយទុក្ខសោកជាបឋម តែងចូលលាយឡំនៅក្នុងចិត្ត ។
តែនេះលោកប្រៀបដូចពពក រសាត់ទៅមកមិនថេរឋិត
មិនជាប់លាប់នៅជាកំហិត ដ្បិតវាមិនស្ថិតជានិរន្តរ៍ ។
កើតមកត្រូវជួបទាំងអស់គ្នា តែងតែរងវេទនាក្នុងជីវិត
និងព្រឹត្តិការណ៍ជីវិតជាល្បាន់ សុខទុក្ខច្រើនជាន់មកប្ដូរផ្លាស់ ។
ប៉ុន្តែកិរិយាល្អចម្បង គឺការរៀនឆ្លងឱ្យស្រឡះ
កុំឱ្យកិលេសអ្វីផ្ដេសផ្ដាស មកប៉ះពាល់អារម្មណ៍ឱ្យសោះ ។
នោះទើបយើងអាចឈានខ្លួនឯង ទៅដល់កន្លែងខ្ពស់បង្អស់
គឺអមតភាពមួយប៉ុណ្ណោះ ដែលខ្ពស់ហួសអស់ដំណាក់កាល ។
លោកសន្និវាសនេះសែនធំធេង លេចឡើងទន្ទេងដោយដុះដាល
នូវអនន្តភាពដូចជាថ្កាល មិនអាចរកកាលកម្ចេចបាន ។

បើប្អូនស្លាប់ទៅប្រសើរជាង     ដែលល្អរូបរាងតែផ្តេសផ្តាស

ពីដើមធ្លាប់ល្បីឈ្មោះល្អណាស់     មានអ្វីអាម៉ាស់ជាងនេះទៀត ។

បើប្អូនអាចច្បាំងបានជោគជ័យ     យកបានផែនដីឥតបីឃ្លាត

ប្អូននឹងគ្រប់គ្រងរាស្ត្រផៅញាតិ     ទៅតាមធម្មជាតិវង្សខត្តិយៈ ។

បើប្អូនចាញ់ហើយត្រូវពលី     ជីវិតលើទីសក្ការៈ

យកសមរភូមិជាពំនាក់     នោះជាក់ជាប្អូនឡើងសួគ៌ា ។

ប្អូនធ្លាប់ខ្លាចណាស់នូវបាបកម្ម     ហើយតែងចងចាំចង់ចាកវៀរ

ឥឡូវត្រូវដល់ពេលពុះពារ     ពាំងចិត្តឱ្យជាកុំបីលុះ ។

ការវៀរចាកផុតពីបាបកម្ម     ប្រាកដជានាំឱ្យរាល់មនុស្ស

ទទួលកេរ្តិ៍ឈ្មោះនិងកិត្តិយស     ពីរោះខ្ពង់ខ្ពស់ឥតគណនា ។

តើមនុស្សយើងត្រូវធ្វើដូចម្តេច     នេះឯងជាកិច្ចនៃការងារ

ដែលបងសូមថ្លាថ្លែងពណ៌នា     ទុកជាមាគ៌ានៃជីវិត ។

ត្រូវរៀនធ្វើប្រព្រឹត្តកម្ម     ស្មើជាប្រចាំក្នុងគំនិត

រីករាយនិងទុក្ខសោកគួរគិត     ថាពិតជាគ្មានអ្វីខុសគ្នា ។

ខាតនិងចំណេញ ចាញ់និងឈ្នះ     ផ្ទះខ្ទមនិងផ្ទះមហាគ្រឹហា

មិនត្រូវមើលឃើញដោយគណនា     ថាវាខុសគ្នាមួយទៅមួយ ។

ចូរកុំបណ្តោយឱ្យស្មារតី     លុះដោយករណីជាទុក្ខព្រួយ

ជាមោហ៍មកបាំងឱ្យរញ្ជួយ     រលេះរលួយខូចអារម្មណ៍ ។

នេះជាក្រឹត្យក្រមឥរិយាបទ     មានឈ្មោះប្រាកដតាមពាក្យផ្សំ

គឺ "ពុទ្ធិយោគ" ហៅដោយចំ     ជាមាគ៌ាសម្រាប់យោងយឹត ។

មនុស្សឱ្យរំដោះពីបាបកម្ម ជាចំណងខាំជាប់ជីវិត
ដែលស្វែងរកផ្គាប់ចិត្តជុំជិត តាមការកេងតិតប្រយោជន៍ផ្ទាល់ ។
នេះឯងជាមហាសប្បដិភ័យ មួយដែលមានន័យគួរសម្គាល់
កុំឱ្យស្មារតីយើងប៉ះពាល់ នូវទុក្ខសោកផ្ទាល់អស់ពេលយូរ ។
ត្រូវចេះញ៉ាំងអារម្មណ៍ឱ្យវៀរ ចាកអ្វីផ្ទុយគ្នាជាគូៗ
ដោយហ្វឹកហ្វឺនចិត្តឥតបន្ទូរ ឱ្យស៊ូជាមួយភាពបរិសុទ្ធ ។
ភាពនេះជាគោលដៅតែមួយ ដែលត្រូវលើកស្ទួយជាចំហុត
អ្វីៗដែលមិនមែនបរិសុទ្ធ ចូរកុំលំអុត ត្រូវវាងវៀរ ។
ប្អូនមានករណីយកិច្ចមួយ គឺត្រូវលើកស្ទួយដល់ការងារ
តែមិនត្រូវគិតពីផលវា ថាជាប្រយោជន៍សម្រាប់ខ្លួន ។
ប៉ុន្តែទោះបីជាយ៉ាងណា គេត្រូវធ្វើការយ៉ាងខ្ជាប់ខ្ជួន
ដោយមិនមានសិទ្ធិនឹងគេចពួន ឬក៏ភ្ជាប់ខ្លួននឹងផលសោះ ។
មនុស្សរាល់គ្នាត្រូវតែធ្វើការ មធ្យ័តក្នុងស្មារតីស្ម័គ្រស្មោះ
ហៅថា "យោគៈ" ល្អលើសអស់ អ្វីជាកេរកោះនៃជីវិត ។
ជាប្រាជ្ញាញាណមួយដ៏ខ្លាំង មិនមានមោហ៍បាំងរាំងរូបរឹត
គឺជាមេបាតពីបណ្ឌិត ពាក្យពិតថា "ស្ថិតប្រាជ្ញា" ។
ជាដំណាក់កាលនៃស្មារតី ដែលជម្រះអ្វីជាតណ្ហា
ពោលគឺសព្វកិលេសឥតសារ ឱ្យអារម្មណ៍ស្គាល់សុខគ្រប់មុខ ។
មិនរំភើបនឹងក្ដីរីករាយ ហើយមិនពាយងាយនឹងក្ដីទុក្ខ
មិនបណ្ដោយឱ្យវាវាយលុក ចូលជាបន្ទុកក្នុងឱរា ។

សារធាតុបីយ៉ាងគឺ កំហឹង ក្តីភ័យខ្លាច និង ក្តីប្រាថ្នា<br>
ឬហៅម្យ៉ាងទៀតថាតណ្ហា មិនញាំងឱ្យក្លាក្នុងស្មារតី ។<br>
អាក្រក់និងល្អឃើញដូចគ្នា ជោគជ័យដូចជាបរាជ័យ<br>
ខាតនិងចំណេញក៏មានន័យ ប្រពៃដូចគ្នាក្នុងចិន្តា ។<br>
នេះជាផ្នែកមួយនៃយោគៈ ប្រសើរនៃមនសិការ<br>
លោកចាត់ទុកជាឧបេក្ខា គឺតាំងចិន្តាមិនលម្អៀង ។<br>
មិនចេះស្រឡាញ់ឬក៏ស្អប់ ស្មារតីត្រូវស្ងប់ទប់ទាត់ទៀង<br>
ដូចអណ្តើករួញសរីរាង្គ ឱ្យចូលឥតល្អៀងទៅក្នុងស្នូក ។<br>
បើវិញ្ញាណបានសង្រួមហើយ ព្រលឹងក៏ឆ្លើយជួយចែវចូក<br>
ជួយទប់វិញ្ញាណឱ្យនឹងស្លុក រីករាយទុក្ខសោកក៏សាបសូន្យ ។<br>
ជាដំណាក់កាលពេញកិត្តិយស ឈានដល់ទីខ្ពស់ហាក់ដូចក្បូន<br>
ដែលជួយចងចម្លងសណ្តូន ខ្លួនប្អូនទៅកាន់ភាពឧត្តម ។<br>
គឺឱ្យដល់ព្រលឹងបរិសុទ្ធ មាននាមកំណត់ដោយសក្តិសម<br>
ជាអធិបតីស្តីដោយចំ នោះគឺព្រះព្រហ្មបង្កើតលោក ។<br>
វិញ្ញូជនឃើញថាពេលខ្លះ វិញ្ញាណត្រូវបះបោរកញ្ច្រោក<br>
រុញច្រានស្មារតីឱ្យយោលយោក ដូចព្យុះបក់បោករុញនាវា ។<br>
ឱ្យលោតចុះឡើងតាមរលក គ្មានអ្វីអាចមកជួយការពារ<br>
ជាដំណាក់កាលសែនគ្រាំគ្រា សម្រាប់មាគ៌ានៃវិញ្ញាណ ។<br>
ប៉ុន្តែប្អូនអាចត្រួតឥន្ទ្រិយ តាមការសំភីប្រុងប្រិតប្រៀន<br>
ប្រាណប្រឹងស្មឹងស្មាធិ៍សម្អាតញាណ ដើម្បីនឹងឈានទៅដល់បង[១] ។

១. បង គឺព្រះក្រឹស្ណា ជាអវតារទី ៨ នៃព្រះវិស្ណុ ។

ពោលគឺបោះបង់ឧបាទាន កុំឱ្យកើតមានសោះតែម្ដង
ពីព្រោះវាជាខ្សែចំណង ដែលចងយើងភ្ជាប់ទៅតណ្ហា ។
តណ្ហាជាឫសគល់កំហឹង លែងឱ្យរឹងប៉ឹងក្នុងចិន្ដា
សតិវិបល្លាសជាផ្លែផ្កា អន្ដរាយរូបានៅចុងផុត ។
បើតណ្ហាហូរចូលស្មារតី ត្រូវគិតពីអ្វីដែលបរិសុទ្ធ
ដូចទឹកហូរសំដៅសមុទ្រ ចូលផុតរួចហើយរហោយអស់ ។
នោះទើបគេអាចនាំសន្តិភាព មកពោរពេញព្រៀបគ្មានចន្លោះ
ជាទីបរមសុខមួយឥតខ្ចោះ ព្រោះវិញ្ញាណហោះដល់ព្រហ្មា ។
ករណីនេះមានមាគ៌ាពីរ សម្រាប់សំភីជាវិជ្ជា
មួយ សមាធិឬភាវនា ពីរ ធ្វើការងារដោយខិតខំ ។
បំពេញឱ្យត្រូវកុំនៅស្ងៀម ត្រឹមម្ដងមួយយាមមិនសម្ញំ
ដោយគ្មានការបង្ខិតបង្ខំ នេះជាក្រឹត្យក្រមច្បាប់ធម្មជាតិ ។
ប្អូនអាចឃើញមនុស្សអង្គុយនឹង ស្ងាត់មាត់ស្ងៀមឈឹងដូចបាត់ធាតុ
តាមពិតអារម្មណ៍គេមិនឃ្លាត តែឆ្លាតឆ្លាស់ឆ្លៀតក្នុងការគិត ។
វិញ្ញាណគេកំពុងធ្វើការ ដោយប្រើប្រាជ្ញានិងគំនិត
បីដូចមនុស្សលាក់ពុតពិតៗ នេះជាជីវិតឧត្ដមជន ។
ជនមួយបែបទៀតដូចបានថា គឺស្ថិតប្រាជ្ញា អ្នកគិតគន់
ត្រូតវិញ្ញាណបានល្អពេកពន់ ធ្វើការស្រោលធ្ងន់គ្មានចំណង ។
ពោលគឺជម្រះឧបាទាន មិនឱ្យកើតមាននាំសៅហ្មង
ជាជនខ្ពស់លើសអស់មនុស្សផង ចូរត្រងត្រាប់ជាករណីយកិច្ច ។

បើមិនធ្វើការដោយទាត់ទៀង តើសិរីរាង្គរស់ដូចម្ដេច
ជីវិតពីការបំពេញកិច្ច មិនត្រូវភ្លាំងភ្លេចឬទោម្នេញ ។
យើងអាចផ្ដាច់ឱ្យផុតចំណាង នៃការងារផងទាំងនោះមិញ
ដោយទុកវាជាសក្ការវិញ ពោលគឺបំពេញដោយជ្រះថ្លា ។
សូមប្អូនប្រឹងឈ្វេងយល់ឱ្យជាក់ ថាសក្ការៈមានន័យថា
ជាសេចក្ដីល្អគ្រប់ប្រការ តាមកិច្ចប្រាថ្នាជាទូទៅ ។
នេះឯងអាចិកំបាំងកិច្ចការ គឺភោគផលាមិននិត្យនៅ
នៃបនឹងប្អូនទេ តែវាត្រូវ បានទៅជាប្រយោជន៍អ្នកផង ។
ចូរប្អូនឧទ្ទិសរាល់កិច្ចការ ធ្ងន់ស្រាលម្ដេចម្ដាដោយឥតហ្មង
ឱ្យស្មោះចំពោះទៅរកបង និងផ្សងប្រយុទ្ធយកជោគជ័យ ។
ចូរខំប្រឹងតាំងចិត្តផ្ចិតផ្ចង់ តម្រែតម្រង់ភាពវាងវៃ
គឺប្រឹងពង្រឹងផ្ដោតស្មារតី ភ្ជាប់ទៅនឹងន័យអនន្តភាព ។
ត្រូវផ្ដាច់ឥន្ទ្រិយពីតណ្ហា និងពីអាត្មាឱ្យរៀងរាប
រួចធ្វើការទាំងមានរបៀប ដោយមិនបាច់ជ្រាបពីលទ្ធផល ។
ខាតចំណេញឬអាក្រក់ល្អ ជាកុសលធម៌ឬអកុសល
ចូរប្អូនតមកុំគិតគួរដល់ ទើបប្អូនជួបផលការរំដោះ ។
មែនហើយមានមនុស្សច្រើនអាត្មា ដែលប៉ងប្រាថ្នាការល្អសោះ
ប៉ុន្តែនៅតែប្រព្រឹត្តផ្លោះ- ផ្លោយ ចុះព្រោះអ្វីចូរប្អូនស្ដាប់ ។
មានតែតណ្ហានិងកំហឹង ទាំងពីរយ៉ាងហ៊ឹងក្នុងភទ្រកប្ប
ជាអកុសលធម៌ដ៏អូអ័ព្ទ ដែលប្រាប់ឱ្យប្រព្រឹត្តបាបកម្ម ។

អារម្មណ៍ពីរនេះជាសត្រូវ ដ៏សែនឃោរឃៅនៅត្រែងត្រាំ
ព័ទ្ធព្រលឹងជិតជាប្រចាំ នាំភាពសាំញាំដល់ប្រាជ្ញា ។
វិជ្ជាពិតៗនៅខាងក្នុង ទៅជាជិតស្លុងបាំងនេត្រា
ដូចទារកសម្ងំអាត្មា ក្នុងផ្ទៃមាតាមុនសម្ភព ។
ឬដូចអណ្តាតភ្លើងតូចធំ ត្រូវផ្សែងរុំជុំងងឹតឈ្លប់
ឬដូចកញ្ចក់ដាសសុសសព្វ ព្រោះកប់នៅក្នុងផង់ធូលី ។
យ៉ាងណោមិញគេមើលមិនដឹង មិនឃើញព្រលឹងក្នុងស្ថានទី
ព្រោះព្រលឹងហាក់ដូចអគ្គី ត្រូវផ្សែងញាំញីព័ទ្ធជិតជុំ ។
ខ្យល់តែបន្តិចដែលបក់ផាត់ ក៏អាចកម្ចាត់ផ្សែងដែលរុំ
កញ្ចក់ដាសដោយធូលីជុំ អាចជូតឬផ្ទុំឱ្យភ្លឺថ្លា ។
ទារកត្រូវរង់ចាំច្រើនខែ ទាំងមានការថែទាំរក្សា
យ៉ាងប្រុងប្រយ័ត្នពីមាតា មុនឃើញសុរិយាចាំងរស្មី ។
តាមពាក្យដូចបានពណ៌នាមក សូមប្អូនចាប់យកជាសេចក្តី
ជម្នះឥន្ទ្រិយគ្រប់ករណី ដើម្បីអាចឱ្យឃើញព្រះព្រហ្ម ។
អស់ច្រើនជាតិបងជាទេវៈ ជាគ្រូឃោតៈម្នាក់ដ៏ធំ
នៃអាទិទេពអ្នកប្រក់ព្រំ នាមតាមនិយមវិវស្វ័ត[១] ។
ព្រះអង្គបង្រៀនព្រះមនុ[២] ព្រះឥក្សាកុ[៣]ក៏ឆ្លងកាត់
ពីព្រះមនុដោយហ្មឹកហាត់ រូបចាត់ឱ្យមានការសិក្សា ។
នៅគ្រប់ជំនាន់នៃមនុស្សលោក បងតែងយោនយកចាប់ជីវ៉ា
ច្រើនលើកក្នុងវាលវដ្តសង្សារ នេះជាវាចាពិតប្រាកដ ។

---

១. ២. ៣ មើលសេចក្តីពន្យល់សង្ខេបខាងក្រោយ ក្នុងទំព័រ ៧១ ។

ប្អូនក៏កើតហើយស្លាប់ច្រើនដង  បីដូចរូបបងតាមកំណត់
តែប្អូនមិនបានដឹងបែបបទ  ដែលពេសន្ទតជាសម្ងាត់ ។
ពោលគឺអាថិកំបាំងនៃលោក  ដែលមនុស្សគរគោកមិនប្រយ័ត្ន
ដោយច្រើសប្រហែសការប្រតិបត្តិ  មិនព្រមដុសខាត់ចិត្តឱ្យថ្លា ។
អាថិកំបាំងនេះសូមប្អូនជ្រាប  ជ្រោងឱ្យពេញព្រៀបក្នុងប្រាជ្ញា
ថារូបបងនេះជាទេព្ដា  មិនចេះមរណាឬកើតឡើង ។
គឺបងជាអនន្តបុគ្គល  ជាអ្នកអាចយល់ក្ដីថ្កុំថ្កើង
ជាអម្ចាស់នៃសត្វលោកយើង  ដែលមកតម្កើងយុត្តិធម៌ ។
កាលណាមានកើតភាពគោកយ៉ាក  លំបិនលំបាក កើតអន្តរ-
ធានលុកលុយលើយុត្តិធម៌  បងក៏មកកើតនៅក្នុងភព ។
បងជាអវតារខ្លួនបងផ្ទាល់  ដែលគេអាចស្គាល់នៅសព្វគ្រប់
ក្នុងយុគសម័យយើងជាម្ជប់  ថាជាអ្នកគ្រប់គ្រងកុសល់ ។
ដើម្បីកម្ទេចអំពើពាល  ដេរដាសពាសវាលជាកង្វល់
និងស្ដារឡើងវិញនូវកុសល  បានដល់ការផ្សាយព្រះធម្មៈ ។
តែករណីទេវភាពនៃបង  បងមិនបាច់ប៉ងចង់បញ្ជាក់
ឱ្យឃើញច្បាស់ទែងពេញលក្ខណៈ  ឯភាពសច្ចៈនៅត្រឹមថា ។
អ្នកណាមិនអាចកើតឡើងវិញ  អ្នកនោះឯងមិញដូចទេព្ដា
បានចារថាឱ្យគេយាត្រា  ទៅដល់អាត្មារបស់បង ។
អ្នកនោះឯងជាមនុស្សអស់កម្ម  ព្រោះចិត្តមិនផ្សាំជាប់បំណង
តណ្ហា ឧបាទាន កំហឹង ផង  ដែលមានដើមទងពីអភិជ្ឈា ។

បានន័យថាគេបានស្វះស្វែង    រកឃើញកន្លែងជ្រកនៅនា
នឹងរូបបងនេះព្រោះបានវៀរ-    ចាកអស់កម្មពៀរជាលោកិយ ។
គឺព្រះអគ្គីនៃវិជ្ជា    ដែលនាំមនុស្សម្នាតាមវិធី
ដោយអាចឱ្យរកឃើញសេចក្ដី    បរិសុទ្ធជាន័យថាដល់បង ។
ទោះបីមនុស្សបានធ្វើសក្ការ-    បូជាបែបណាតាមគេផ្សង
មាតាទាំងអស់នាំទៅបង    ដូចក្ដីបំណងរាល់អាត្មា ។

---

១. **វៃវស្វ័ត** ជាមនុទី៧ ដែលឱ្យកំណើតដល់មនុស្សយើងសព្វថ្ងៃ (មើល មនុ) ។

២. **មនុ** ជាព្រះនាមនៃព្រះប្រឋមក្សត្រិយ៍ក្នុងខាងដើមភទ្រកល្ប គឺព្រះនាមនៃក្សត្រិយ៍មួយអង្គដែលពួកមនុស្សព្រមគ្នាសន្មតឱ្យធ្វើជាស្ដេចមុនដំបូងបំផុត ក្នុងខាងដើមនៃភទ្រកល្បនេះ ហៅថាព្រះបាទមនុ ឬព្រះបាទសម្មតរាជ (តាមលទ្ធិពុទ្ធសាសនា) ។ តាមលទ្ធិព្រាហ្មណ៍ គឺព្រះនាមនៃព្រះព្រហ្ម ដែលជាអ្នកបង្កើតលោក ឬនាមរបស់បុរសដែលជាបិតាដើមរបស់ពួកមនុស្សក្នុងបឋមកប្ប ។ មនុមានទាំងអស់១៤ ដោយចាប់ផ្ដើមពីមនុស្វយម្ភុវៈ ដល់មនុភៅត្យៈ និងមានអាយុកាលនីមួយៗ ៤.៣២០.០០០ ឆ្នាំមនុស្ស ហៅថា មន្វន្តរៈ ។ (មើលបន្ថែមក្នុងវចនានុក្រមរឿងរាមាយណៈ និង វចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជ ជួន ណាត)) ។

៣. **ឥក្ស្វាកុ**. ព្រះបាទឥក្ស្វាកុ ឬតាមភាសាបាលី គឺព្រះបាទឱក្កាករាជ ជាមហាក្សត្រិយ៍ ដែលបន្តរាជវង្សនៃព្រះបាទមនុវៃវស្វ័ត ជាមនុទី៧ (ក្នុងបឋមកប្ប) ដែលជាប្រឋមក្សត្រិយ៍ ឬជាដើមរាជវង្សនៃក្សត្រិយ៍ទាំងឡាយតៗមក ។ ព្រះបាទមនុវៃវស្វ័តជាបុត្រ របស់ព្រះវិវស្វ័ត (ព្រះអាទិត្យ) ។ ដូច្នេះ ព្រះបាទឥក្ស្វាកុត្រូវជាព្រះនត្តា (ចៅ) របស់ព្រះអាទិត្យ ។ ទ្រង់មានព្រះរាជបុត្រ១០០អង្គ ក្នុងនោះ ព្រះរាជបុត្រច្បងទ្រង់ព្រះនាមថា វិកុក្សិ ដែលសោយរាជ្យបន្តនៅក្រុងអយុធ្យា ។ បុត្រមួយអង្គទៀតព្រះនាមព្រះបាទ និមិរាជ ដែលទ្រង់បានបង្កើតព្រះសន្តតិវង្សនៅក្រុងមិថិលា ។ (សូមមើលបន្ថែមក្នុងវចនានុក្រមនៃរឿងរាមាយណៈ និងក្នុងវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជ ជួន ណាត) ។

# ច្បាប់ព្រះក្រឹស្នា

## ភគវ័ទ_គីតា (ត)

### បទកាកគតិ

បងសូមបញ្ជាក់ បន្ថែមពីអ្នក បំពេញកិច្ចការ
ថាត្រូវរំដោះ ចិត្តដោយជ្រះថ្លា ចេញពីតណ្ហា
ការប្រាថ្នាផល ។

ដែលកើតចេញពី ការគិតសំភី ថាកុំខ្វាយខ្វល់
ចង់បានប្រយោជន៍ នោះទើបកុសល នាំចិត្តទៅដល់
សេចក្តីរីករាយ ។

ទោះបីធ្វើការ ច្រើនតិចម្តេចម្តា ការក្រការងាយ
ធ្វើដោយជាប់លាប់ ឥតបីរាយមាយ តាមន័យទូលាយ
ជាន័យឧបមា ។

គឺបីដូចជា គេគ្មានវេទនា- រម្មណ៍ថាធ្វើការ
ឯន័យប្រាកដ ពិតជាចង់ថា គេផ្តាច់ផលា
ពីការជាស្រេច ។

ការស្គាល់ទេព្តា យល់ក្បួនតម្រា ដ៏ខ្ពស់បណ្តាច់
ជាការកម្ដេច នូវគុណបំណាច់ ដូចចិត្តបានផ្តាច់
ពីផលជាធំ ។

មនុស្សណាធ្វើការ ដោយគ្មានចិន្តា អាត្មានិយម
មិនឱ្យខ្លួនជាប់ ចំណេងរឹតរុំ អ្នកនោះឯងពុំ
មានមោហ៍មកបាំង ។

អារម្មណ៍ល្អណាស់ ព្រោះជ្រះស្រឡះ តណ្ហាជាខ្លាំង
ដែលនៅក្នុងខ្លួន ចាំទប់តតាំង តែមិនអាចរាំង-
រាគេបានហោង ។

ចូរចេះលះបង់ នូវរាល់ចំណង់ ណាជាចំណង
ទើបប្អូនអាចឈាន ទៅដល់រូបបង ទាំងឥតមានហ្មង
នឹងសន្តិភាព ។

មនុស្សមានចិន្តា ពេញដោយអាត្មា- និយមរៀងរាប
ក្រាស់ដោយតណ្ហា ប្រាថ្នាតែលាភ ជាជនជាប់ឃ្នាប
ខ្ទោះឃ្នាងលោកិយ ។

ជនជាយោគី បានឈានដល់ទី ជាសញ្ញាសី
តែងបំពេញការ- ងារជាប្រក្រតី ដោយផ្ដាច់ហប្ញទ័យ
ចេញពីភាគផល ។

វិការលះបង់ មានន័យដោយត្រង់ គួរកុំគិតឆ្ងល់
ពីការពោះបង់ មិនឱ្យសេសសល់ អ្វីជាកង្វល់
បានដល់តណ្ហា ។

ការងារទាំងឡាយ ជាមធ្យោបាយ ទៅរកខ្លឹមសារ
នៃយោគៈពិត តាមសព្ទវាចា ទើបលោកហៅថា
ជាការលះបង់ ។

កាលបើបានឈាន បានបោះជំហាន ដោយចិត្តផ្ចិតផ្ចង់
ទៅដល់ដំណាក់- កាលការលះបង់ ក្តីស្ងប់នឹងរង់-
ចាំយើងតែម្តង ។

សេចក្តីរីករាយ ដែលចេញបែកធ្លាយ ពីរាល់ចំណង
ឬហៅតណ្ហា ជាគ្រឿងសៅហ្មង ជាគ្រឹះចម្បង
នៃក្តីទុក្ខសោក ។

អ្វីដែលកកើត ចាប់ជាកំណើត លេចសារធាតុមក
មិននៅឋិតថេរ តែឈានទៅរក ចូលក្នុងរង្វក
នៃទីបញ្ចប់ ។

ក្តីរីករាយនេះ ត្រូវត្រងត្រិះរិះ ឱ្យបានគ្រប់សព្វ
ថាវាតែងតែ មានទីបញ្ចប់ គឺមិនប្រសព្វ
នឹងអនន្តភាព ។

វិញ្ញូជនណា ដែលសាងអាត្មា ដោយស្មោះរាបទាប
នឹងដល់ដំណាក់- កាលល្អឥតប្រៀប គឺឃើញស្មើភាព
នូវគូផ្ទុយគ្នា ។

ឃើញត្រជាក់ក្តៅ រីករាយសោកសៅ សប្បាយវេទនា
កិត្តិយសខ្ពស់ទាប ភាពអាម៉ាស់ជា ករណីដូចគ្នា
ចិត្តនឹងបានស្ងប់ ។

ជននេះយល់ថា ផ្ទៃដីមួយអារ មានន័យបង្គប់
ដូចថ្មមួយគរ មាសមួយកញ្ចប់ មានតម្លៃសព្វ
ជាន័យដូចគ្នា ។

សេចក្តីរីករាយ នឹងត្រូវរំលាយ ដោយទុក្ខវេទនា
ក្តីរីករាយមិន អាចនិត្យនៅជា- និច្ចគ្រប់វេលា
ជាអនន្តភាព ។

អ្វីមានដើមចុង មានក្រៅមានក្នុង មានខ្ពស់មានទាប
មានកើតមានស្លាប់ បណ្ឌិតត្រូវជ្រាប ថាមិនអាចធៀប
នឹងភាពអមតៈ ។

ជនជាវិញ្ញូ តែងចេះគិតគូរ មិនឱ្យខ្លួនធ្លាក់
ចូលក្នុងស្ថានភាព ដែលជាដំណាក់- កាលគ្មានសច្ចៈ-
ភាពជាចំណង ។

យោគីពិត១ តែងយល់ដោយគិត ឃើញយ៉ាងច្បាស់ច្បង
មិត្តនិងសត្រូវ បក្សផ្សេងគ្នាផង សុខទុក្ខទាំងសង
គ្មានអ្វីខុសគ្នា ។

ជនកបកិរិយា បែបនេះហៅមហា ឧត្តមមហិមា
អាចរីករាយសព្វ ចិត្តស្ងប់គ្រប់គ្រា គឺអស់កម្មពៀរ
អនិច្ចំទុក្ខំ ។

អរជូន ចូរស្តាប់ បងនឹងរ៉ាយរ៉ាប់ ពីរឿងសច្ចំ
គឺការសម្ងាត់ នៃអាថិកំបាំង គួរឱ្យឆ្ងល់ខ្លាំង
តើដូចម្តេចម្តា ។

បងបានយោនយក កំណើតនេះមក ជារូបមនុស្សា
តែមនុស្សទាំងអស់ មិនសង្ស័យថា រូបបងនេះណា
ជាមហាបុគ្គល ។

ជាអធិបតី សត្វលោកនិងអ្វី នៅក្នុងមណ្ឌល
ឬព្រះជាម្ចាស់ តាមដែលគេយល់ ទាំងត្រូវវរវល់
រៀបជាពិធី ។

សក្ការបូជា ឱ្យទៀងវេលា និងប្រឹងសំភី
ថាបងនេះជា បិតាគ្មានពីរ នៃព្រះធរណី
និងអស់សព្វសត្វ ។

ក្នុងរូបមនុស្សា បងជាទេព្តា ប្រសើរពេកក្តាត់
គឺជាទិសដៅ នៃការស្ញើងស្ញាច់ និងជាដើមអាទិ៍
រាល់ការបូជា ។

ជនទាំងឡាយណា បូងសួងសច្ចា ខិតខំភាវនា
រួមទាំងឧទ្ទិស សក្ការបូជា រៀងរាល់វេលា
ទៀងទាត់ទៅបង ។

នៅទីបញ្ចប់ នឹងបានប្រសព្វ ដោយឥតផ្សងផ្សង
មកនៅនៃបនិត្យ ជុំជិតឥតហ្មង ជាមួយរូបបង
ជាអ្នកប្រក់ព្រំ ។

មិនថាប្អូនធី ឬធ្វើអ្វីៗ តាមការនិយម
ដូចជាពិធី បូជាតូចធំ ចូរចាត់ចែងជុំ
ឧទ្ទិសទៅបង ។

ប្អូននឹងរំដោះ ខ្លួនបានរួចអស់ ពីរាល់ចំណង
នៃបាបកម្ម ជាអកុសលផង គឺផលដែលឆ្លង
ពីកិច្ចការប្អូន ។

បងជាព្រលឹង ដែលស្ថិតនិត្យនឹង មិនចេះសាបសូន្យ
ក្នុងសព្វសត្វលោក រួមទាំងរូបប្អូន ពោលគឺជាក្បួន
សម្រាប់ចម្លង ។

ជាបុគ្គលផ្តើម ព្រោះបងជាដើម ជាកណ្តាលផង
និងចុងបញ្ចប់ ទាំងសព្វតែម្តង ចូរប្រឹងប្រែងចង-
ចាំឱ្យបានល្អ ។

បងជាវិស្ណុ បរមវត្ថុ ក្នុងពួកទិនករ
បងជារស្មី ភ្លឺក្រៃបវរ ដែលលេចបន្ត
ពីព្រះសុរិយា ។

នៅក្នុងចំណោម បណ្ដាចង្កោម ហ្វូងដួងតារា
បងជាព្រះចន្ទ បំភ្លឺលោកា ក្នុងក្ដីស្នេហា
លើធម៌សច្ចះ ។

ចំណោមគម្ពីរ វេទដែលជាទី កើតធម្មវចនះ
ឬទេពវិទ្យា បងជាសាមះ ជាសម្បជញ្ញះ
នៃពួកវិញ្ញាណ ។

នៅនឹងសត្វលោក ដ៏មានជ័យជោគ បងជាប្រធាន
នៃការយល់ដឹង គឺប្រាជ្ញាញាណ ដែលបងប្រទាន
ទៅគ្រប់មនុស្សា ។

ចំណោមព្រះរុទ្រ គួរភ័យរន្ធត់ បងជាសង្ការ[១]
បងជាមេរុ ក្នុងពួកបព្វតា ក្នុងសព្ទវាចា
បងជា ឱម[២] ។

បងជាក្ដីស្លាប់ ដែលកម្ទេចច្បាប់ ជាភាពអមតះ
នៃអ្នកបោះបង់ នូវធម៌សច្ចះ ឬព្រះយមះ
គឺអ្នកបរិសុទ្ធ ។

---

១. សង្ការ ឬ រុទ្រ ជាព្រះនាមព្រះសិវះ កាលណាព្រះអង្គបញ្ចេញអាការៈកាច ។
២. ឱម ជាបទសន្ធិនៃអក្សរពាក្យគឺ អ.ឧ.ម. ឬ ព្រះវិស្ណុ. ព្រះសិវះ. ព្រះព្រហ្ម ។

ចំណោមសព្វា- វុធខ្លាំងនានា សម្រាប់ប្រយុទ្ធ
បងជារន្ទះ ខ្លាំងក្លាមុះមុត ដែលតែងសម្លុត
បិសាចវប្ញត្រ ។

អ្វីជាសម្គាល់ រង្វាស់រង្វាល់ វែងខ្លីឆ្ងាយជិត
តូចធំឆាប់យូរ តាមគួរគន់គិត សូមប្រាប់ដោយពិត
បងជាព្រះកាល ។

និយាយដោយខ្លី ទៅតាមសេចក្តី ដូចបានតំណាល
បងជាពន្លក ដ៏ល្អត្រកាល ដែលដុះក្នុងថ្កាល
ជីវិតសត្វលោក ។

អ្វីកបកិត្តិយស កបដោយសម្ពស្ស កបដោយជ័យជោគ
កបដោយកម្លាំង គ្មានអ្វីស្មោកគ្រោក សុទ្ធតែកើតមក
ពីបារមីបង ។

នេះគឺបានន័យ មួយយ៉ាងប្រពៃ ប្រាកដកន្លង
ថាលោកសន្និវាស នេះគឺរូបបង ជាអ្នកគ្រប់គ្រង
ជ្រាបសព្វកន្លែង ។

ប្អូនមើលឱ្យច្បាស់ បងនឹងប្រែផ្លាស់ ឱ្យឃើញជាក់ស្តែង
នូវរូបរាងបង ដែលភ្លឺចិញ្ចែង ព្រោះបងនេះឯង
ជាតួអវតារ ។

# ច្បាប់ព្រះគ្រីស្ទា

## ភគវ័ន-គីត (គនិងចប់)

### បទព្រហ្មគីតិ

ក្រីស្ទាទ្រង់ប្រទាន នូវវិញ្ញាណមួយអស្ចារ្យ
គឺផ្តល់ទិព្វនេត្រា ថ្វាយអរជូនជាស្ងួនគ្រង ។
ព្រមជាមួយនោះឯង រស្មីចែងចាំងបំព្រង
ពាសពេញវេហាស៍ផង ចេញពីអង្គព្រះក្រីស្ទា ។
សែនរុងរឿងថ្កុំថ្កើង លេចធ្លោឡើងនូវសញ្ញា
ថាសន្និវាសនេះណា ជាកាយានៃព្រះអង្គ ។
អរជូនកើតអស្ចារ្យ ក្នុងចិន្តារូបផ្ចិតផ្ចង់
លើកករលំឱនអង្គ ឆ្ពោះតម្រង់បាដិហារ្យ ។
ពេលក្រោយថ្វាយបង្គំ ព្រះជាធំលើលោកា
ទាំងមានបន្ទូលថា ឱ! ក្រីស្ទាជាអម្ចាស់ ។
នៅនឹងកាយព្រះអង្គ ទេព្តាគង់នៅច្រើនណាស់
ទូលបង្គំឃើញច្បាស់ មានអម្ចាស់ច្រើនអង្គទៀត ។
ពេលនេះទូលបង្គំ ឃើញព្រះព្រហ្មគង់មិនឃ្លាត
ពីឫសីឯទៀត បីដូចញាតិច្រើនពេកពន់ ។
ឱ! អម្ចាស់ក្រីស្ទា ឯបាដិហារ្យគួរឱ្យគន់
បង្ហាញពីអនន្ត- ភាពពិតៗនៃព្រះអង្គ ។

ទ្រង់រុងរឿងសម្បើម ព្រោះគ្មានដើមកណ្តាលចុង
ពុំមានអ្វីក្រៅក្នុង ពន្លឺរុងសាយសុសសព្វ ។
មិនអាចវិនាសឡើយ គ្មានកោះត្រើយទីបញ្ចប់
ខ្ពស់ក្រៃគួរស្ញែងស្ញប់ ទិសទាំងដប់ឱភាសដល់ ។
ព្រះអង្គទ្រង់យាងមក ជាជម្រកនៃសកល-
លោកនិងជាអ្នកផ្តល់ ការរក្សាច្បាប់អនន្ត ។
នេត្រាព្រះអង្គជា ព្រះសុរិយានិងព្រះចន្ទ
ព្រះភក្ត្រមានឆព្វណ្ណ- រង្សីចាំងដូចអគ្គី ។
ឱ្យលោកសន្ថិវាស អាចឱភាសសព្វទិសទី
ដោយសារបុណ្យឫទ្ធី និងបារមីនៃព្រះបង ។
ដី មេឃ សួគ៌ អាកាស កំពុងដាសជិតជាម្តង
ដោយកាយល្អឥតហ្មង មនុស្សម្នាផងរំភើបខ្លាំង ។
ឃើញបុត្រធឫតរាស្ត្រ លាយឡំពាសពួកចម្បាំង
ភីស្មៈ ទ្រោណ ព្រមទាំង ជនខ្លាំងៗដូចរធិយា ។
និងវីរបុរស ជារបស់យើងផងណា
កំពុងរត់ត្រៀបត្រា ចូលក្នុងព្រះឱស្ឋព្រះអង្គ ។
ដូចជ្រោះជ្រលងភ្នំ ទាំងតូចធំហូរតម្រង់
ឥតបង្អែបង្អង់ ចរចូលបង់ក្នុងសមុទ្រ ។
ឬដូចហ្វូងមមាច ហើរដូចលាជចូលទៅដុត
ខ្លួនឆេះឆាប់បំផុត នៅក្នុងអណ្តាតអគ្គី ។

ទាំងដាក់កាយនិងចិត្ត ឱ្យផ្តេកផ្តិតនឹងសទ្ធា
ខ្ពង់ខ្ពស់មហិមា នោះឯងជាភាពដាច់ខាត ។
ភាពនេះគឺខ្លួនបង ដែលអ្នកផងត្រូវសង្វាត
រៀបចំខំឱកាត ឈានព្រះបាទទៅកុំរា ។
ត្រូវឧទ្ទិសអាត្មា ផ្សំដោយការរៀបបូជា
ហើយខិតខំភាវនា ទើបទៅជាយោគីល្អ ។
មាគ៌ាមួយងាយជាង គឺក្តីទៀងត្រង់ស្មោះសរ
ប្រឹងសាងកុសលធម៌ ហើយបវរណោទៅបង ។
រាល់អំពើគ្រប់មុខ បងចាត់ទុកឥតផ្សេងផ្សង
ជាកម្មវត្ថុផង នៃសក្ការបូជា ។
ដែលគេឧទ្ទិសទៅ ផ្សំដោយនូវការភាវនា
ទាំងចិត្តពេញសទ្ធា ធ្វើការងារដោយស្មោះស្ម័គ្រ ។
នោះបងនឹងសង្គ្រោះ រួចពេលនោះពីគ្រោះថ្នាក់
ឈ្មោះសមុទ្រមរណៈ ឬហៅវាលវដ្តសង្សារ ។
ចូរប្អូនតាំងអារម្មណ៍ ឱ្យបានចំកុំសាវ៉ា
ដាក់ការពិចារណា ទាំងចិន្តានៅនឹងបង ។
បណ្ឌិតថែងចារថា ការងារណាដែលមានចង
ជាប់ដោយតណ្ហាផង ត្រូវលះបង់កុំស្រណោះ ។
គឺត្រូវឧទ្ទិសផល ដែលធ្លាក់ដល់ដោយចិត្តស្មោះ
ទៅសត្វលោកទាំងអស់ ទើបមានឈ្មោះជាយោគី ។

នេះក៏បានន័យថា រាល់កិច្ចការក្នុងជីវី
យើងត្រូវមាននាទី នឹងបំពេញជាចាំបាច់ ។
តែលះបង់តណ្ហា និងឧបាទានឱ្យដាច់
ដោយដាក់ចិត្តជាស្រេច ថាមិនឱ្យមានពាក្យ "អញ" ។
ដែលជាមូលហេតុធំ នៃការគុំកេងប្រវ័ញ្ច
រំភើបឬក្តក់ក្តាញ់ នឹងជោគជ័យបរាជ័យ ។
អ្នកលះបង់អាត្មា ពីតណ្ហានោះមានន័យ
ថាជាមនុស្សប្រពៃ មិនទីទៃពីទេវតា ។
មានចក្ខុវិស័យ ភ្លឺថ្លាក្រៃ និងត្រួតត្រា
ឥន្ទ្រិយប្រាំប្រការ បែរអាត្មាចេញស្រឡះ ។
ពីគោលដៅវិញ្ញាណ គឺមិនឃ្លាន មិនឃើញខ្វះ
ស្រឡាញ់ ឬស្អប់ណាស់ ចូរបម្រះចិត្តដោយស្ទាត់ ។
ចេះត្រួតសព្វវាចា ពោលស្តីថាដោយប្រយ័ត្ន
ប្រឹងទប់ចិត្តដុសខាត់ ប្រឹងកម្ចាត់រាល់កិលេស ។
ត្រូវប្រុងប្រឹងស្មឹងស្មាធី ដុសសម្អាតកុំប្រហែស
ឱ្យអារម្មណ៍ភ្លឺថែស ដោយប្រឹងវេះវាងឱ្យបាន ។
ពីកាមរាគនិងការ- លើកអាត្មាហួសប្រមាណ
ហិង្សា អួតអាងប្រាណ លោភលន់ កំហឹង តណ្ហា ។
កម្មសិទ្ធិត្រូវបោះបង់ ដោយផ្ចិតផ្ចង់អង្គអាត្មា
ក្នុងសមាធិ បញ្ញា ទើបមនុស្សឈានដល់ព្រះ ។

គឺទៅដល់រូបបង ដូចបានផ្សងដោយចិត្តជ្រះ-
ថ្លាព្រមទាំងអាចឈ្នះ អាចជម្រះវិញ្ញាណអស់ ។
តណ្ហានិងទុក្ខសោក គ្រប់សត្វលោកអាចរំដោះ
បានដូចគ្នាគ្មានខ្វះ ព្រោះចិត្តស្មោះចំពោះបង ។
ដោយបំពេញកិច្ចការ ទាំងចិន្តាគ្មានបំណង
នោះទើបបានរូបបង ជាបង្គងពឹងអាស្រ័យ ។
នឹងខ្ពស់ដោយកិត្តិយស ឈ្មោះពីរោះពន់ពេកក្រៃ
ឃើញភាពអចិន្ត្រៃយ៍ ដែលគ្មានអ្វីកម្ដេចហោង ។
សូមឧទ្ទិសអាត្មា ទាំងសក្ការបូជាផង
ឱនអង្គឥតផ្សារផ្សង ចំពោះបងជាប្រចាំ ។
បងនឹងជួយប្រោសប្រោះ ឱ្យផុតអស់ពីបាបកម្ម
នេះឯងជាបណ្ដាំ ពេញដោយគតិបណ្ឌិត ។
គឺជាអាថិកំបាំង នៃកម្លាំងសម្ងាត់ពិត
ដែលប្អូនត្រូវពិនិត្យ គួររិះគិតដោយក្ដីគាប់ ។
ចូរប្អូនប្រឹងប្រតិបត្តិ នូវបញ្ញត្តិនេះឱ្យជាប់
ទើបប្អូនអាចមានភ័ព្វ វាសនាគាប់ទៅដល់បង ។
បងជាក់ជាជម្រក សកលលោកនេះជាម្ដង
វៀរអារម្មណ៍សៅហ្មង ចូរចាំចងរៀងរាល់ថ្ងៃ ។

៚ ៚

# ច្បាប់ព្រះភីស្មៈ

បទពាក្យ៧

កាលនោះព្រះបាទយុធិស្ឋិរ ដែលថ្កើងព្រះកេរ្តិ៍ព្រះយសក្រៃ
ទ្រង់ស្តេចយាងទៅគាល់ព្រះអយ្យ- កោថ្លៃ គឺព្រះមហាភីស្មៈ ។
ដើម្បីសុំស្វាធ្យាយសិក្សា វិន័យសិក្ខាតាមទស្សនៈ
នៃក្រមរាជធម៌ល្អសមសក្តិ ដែលត្រូវទុកដាក់ជាគោលការណ៍ ។
ទ្រង់ត្រាស់ទូលទៅព្រះអយ្យកោ ថាឱ! អយ្យកោ សូមករុណា
ត្រាស់ពីករណីយកិច្ចនៃមហា- ក្សត្រិយ៍ឱ្យនត្តាបានដឹងផង ។
ភីស្មៈទ្រង់ព្រះតម្រាស់ថា ឱ! ចៅអើយ! តាអរកន្លង
តានឹងប្រាប់ចៅតាមបំណង ចូរចៅចាប់ចងចាំឱ្យជាក់ ។
កិច្ចមុនបង្អស់របស់ក្សត្រិយ៍ គឺចាត់ទុកជាសក្ការៈ
នូវអស់ពួកព្រាហ្មណ៍និងទេវៈ ពោលគឺស្មោះស្ម័គ្រនឹងសាសនា ។
ចូរចាំជាពិសេសថាក្សត្រិយ៍ ជាអ្នកប្រតិបត្តិរាល់កិច្ចការ
បើខ្វះខាតនឹងបាត់ខ្លឹមសារ វាសនាជួយស្តារក៏មិនបាន ។
អនុវត្តន៍ខ្លាំងក្លាជាងវាសនា យោងតាមគោលការណ៍គួរសន្និដ្ឋាន
ប្រតិបត្តិនេះហើយជាត្រើយត្រាណ ដែលផ្តួចផ្តើមបាននូវវាសនា ។
សាមគ្គីជុំវិញរាជបល្ល័ង្ក ជាក្រឹត្យក្រមញាំងឱ្យខ្លាំងក្លា
បើបែកបាក់ឬក្បត់ក្សត្រា បច្ចាមិត្តនឹងហ៊ានចចើង ។

គុណសម្បត្តិមួយគឺសច្ចធម៌ ជាធម៌បវរត្រូវតម្កើង
កាន់ឱ្យខ្ជាប់ខ្ជួនមួនមាំឡើង នោះចៅនឹងថ្កើងដោយសាររាស្ត្រ ។
ស្តេចជាជម្រកសមិទ្ធផល ត្រូវឱ្យកើនដល់ពោរពេញពាស
កិរិយាឥតខ្ចោះជាពេជ្រមាស អាចកៀសបញ្ចៀសពាក្យនិន្ទា ។
ត្រូវត្រួតពិនិត្យខ្លួនឱ្យបាន ទៅតាមលម្អានចិត្តពុះពារ
យុត្តិធម៌រាបសាជាមាត់កា នៃជោគជ័យប្រាកដពិត ។
ករណីបីយ៉ាងស្តេចត្រូវជ្រាប គឺលាក់លៀមភាពខ្សោយឱ្យជិត
តែផ្តែកខ្សោយនៃបច្ចាមិត្ត ត្រូវស្វែងយល់ពិតសព្វសេចក្តី ។
ទីបីត្រូវចេះលាក់បំបាំង មិនត្រូវឱ្យខ្លាំងទាំងមន្ត្រី
ជ្រាបពីផែនការសម្ងាត់អ្វី នៅក្នុងហឫទ័យនៃរាជា ។
ស្លូតបូតហួសពេកជាគ្រោះថ្នាក់ ដែលអាចបំបាក់ជោគជ័យា
ព្រោះអាចឱ្យអស់រាស្ត្រប្រជា លែងមានសទ្ធាជាសំណព្វ ។
តែកិរិយាសាហាវត្រូវចៀស- វាងកុំឱ្យរាស្ត្រអាប៉ុនសព្វ-
មន្ត្រីខ្លាចជំនួសគោរព ព្រោះជាប្រភពអពមង្គល ។
ការរើសមន្ត្រីជាសិល្បៈ ពិសេសឥតអាក់ដែលត្រូវយល់
ថាជាផ្នែកមួយក្នុងមណ្ឌល ជាកិច្ចរវល់តិចតួចមែន ។
តែត្រូវចៀសវាងការជ្រុលជ្រួល ពីការអនុគ្រោះហួសព្រំដែន
ព្រោះនាំឱ្យថ្នាក់ទាបច្រណែន បត់បែនទុកជាឱកាសល្អ ។
ភាពអាសន្នជាការចាំបាច់ ដែលស្តេចត្រូវទុកជាគុណធម៌
ជ្រាបពីសត្រូវមិត្តស្មោះសរ ឱ្យខ្ជាប់ខ្ជួនល្អជាប្រក្រតី ។

យកព្រះទ័យទុកដាក់ដោយស្មោះ
លើរាស្ត្រទាំងអស់ជាករណីយ-
កិច្ចចម្បងនៃព្រះនរបតី
ដូចស្ត្រីផ្ទមផ្ទៃពេលពពោះ ។
គឺត្រូវថែទាំរាស្ត្រប្រជា
ឱ្យបាត់វេទនាវៀរចាកគ្រោះ
ជម្ពះតណ្ហាណាគ្មានយស
ឱ្យរាស្ត្រអាចរស់ដោយសុខសាន្ត ។
មិនត្រូវទុកចិត្តគេទាំងស្រុង
យកការប្រុងប្រយ័ត្នជាកល្យាណ
មន្ត្រីជិតស្និទ្ធក៏ត្រូវខាន
ដឹងដល់ដើមដានរឿងសម្ងាត់ ។
ដែលទ្រង់តម្រិះក្នុងព្រះទ័យ
គឺត្រូវលកលែលាក់បំបាត់
ដល់ពេលសមស្របសឹមថែងចាត់
យកការប្រយ័ត្នទុកជាតាង ។
ត្រូវឈ្លាសវាងវៃនៅក្នុងការ
ដោះស្រាយបញ្ហាប្រាំមួយយ៉ាង
មួយ គឺសន្តិភាពត្រូវកសាង
នឹងអ្នកជិតខាងខ្លាំងជាងខ្លួន ។
ពីរ បើមានសង្គ្រាមត្រូវធ្វើ
ត្រូវប្រមើលមើលឱ្យសមសួន
កម្លាំងស្មើគ្នានេះជាក្បួន
ចាប់ផ្តើមដោយជួនធ្វើចម្បាំង ។
ទីបី ចូរចៅចងចាំទុក
ថាចៅអាចលុកលុយប្រឆាំង
នឹងប្រទេសទន់ខ្សោយជាខ្លាំង
ដែលមានកម្លាំងអន់ជាងយើង ។
បើនឹងសម្រេចចិត្តធ្វើហើយ
កុំបីខ្លាចឡើយនឹងរំលើង
គិតតែធ្វើម្តេចឱ្យបានថ្កើង
ដំឡើងតម្លៃឱ្យខ្ពង់ខ្ពស់ ។
ទីបួន គឺជំនួយការពារ
ក្នុងគ្រានៃស្ថានភាពវង្គគ្រោះ
កុំបណ្តោយឱ្យបង់កិត្តិយស
ពីព្រោះដើរក្រោយព្រឹត្តិការណ៍ ។
ទីប្រាំ យើងត្រូវចេះបំបាក់-
បំបែកពួកបក្សក្នុងបណ្តា
មន្ត្រីប្រទេសជាបច្ចា-
មិត្តតាមកិច្ចការចារបុរស ។

ប្រាំមួយ គឺការប្រើសំណូក ប្រលោមលួងសូកតាមចន្លោះ
អន្ទងទាញទាក់ឱ្យធ្លាក់អស់ ឱ្យខ្មាំងស៊ុគ្រស្មោះមកខាងចៅ ។
ប្រើវាចារាក់ទាក់រីករាយ មន្ត្រីលោកនាយត្រូវប៉ិនប៉ៅ
រើសយកអ្នកមានចិត្តដូចចៅ ពង្សផៅឧត្តមសីមចែងចាត់ ។
ចៅត្រូវចាំឱ្យជាក់ច្បាស់ថា សេនីយ៍សេនាក៏ដូចក្សត្រិយ៍
ខុសគ្នាត្រឹមតែស្វេតច្ឆត្រ ន័យនេះគួរកាត់ត្រឹមជាម្លប់ ។
មហាក្សត្រិយ៍ត្រូវត្រងបុរីរម្យ ឱ្យបានឧត្តមប្រសើរគ្រប់
ដោយធ្វើឱ្យរាស្ត្រក្នុងពិភព រីករាយនឹងសុភមង្គល ។
ដូចកូននិងមាតាបិតា នៅក្នុងគ្រួសារមួយដែលយល់
ថាក្តីសុខទុក្ខជាបួសគល់ ជារឿងរវល់នៃមេបា ។
ការប៉ិនប្រសប់ឈ្លាសវាងវៃ ជ្រើសរើសមន្ត្រីឱ្យកាន់ការ
ជាអមាត្យឬអគ្គមហា- សេនាជាការធំកន្លង ។
ប្រសប់ សច្ចៈ និងឈ្លាសវៃ ជាគុណធម៌បីត្រូវត្រាប់ត្រង
ជាការចាំបាច់ដ៏ចម្បង ឱ្យសមរម្យផងតាមក្រឹត្យក្រម ។
បើទណ្ឌិតត្រូវទទួលទោស ស្តេចត្រូវសន្តោសឱ្យសក្តិសម
មិនត្រូវដាក់ទោសទាំងបង្ខំ វាយដំធាក់ច្រំលើកាយា ។
ត្រូវឱ្យព្រះឃ្លាំងជារាជទ្រព្យ ពេញលេញជាប់លាប់ជាធម្មតា
សព្វមុខមន្ត្រីខ្ញុំរាជការ ក្សត្រិយ៍ត្រូវត្រួតត្រាដោយខ្លួនឯង ។
មិនត្រូវទុកចិត្តពេញទាំងស្រុង លើអ្នកយាមក្រុងមិនខ្វះខ្វែង
ព្រោះអាចឱ្យចៅដាច់សង្វែង ដូចគេភ្នាល់ល្បែងលែងប្រាកដ ។

នៅក្នុងនគរខ្មាំងជិតខាង
ត្រូវចេះកសាងផែនការក្បត់
ដោយចងមិត្តភាពតាមសន្ធិត
ទៅតាមបែបបទជាសម្ងាត់ ។
ត្រូវត្រៀមទប់ទល់ទ័ពឧទ្ទាម
ត្រៀមធ្វើសង្គ្រាមដោយមធ្យ័ត
មេកោយកងទ័ពត្រូវចែងចាត់
អ្នកចេះប្រយ័ត្នមានចិត្តនឹង ។
បើរក្សារាស្ត្រនិងនគរ
កុំឈរលើភាពត្រឹមត្រង់ភ្លឹង
តែរឿងត្រង់វៀចត្រូវជញ្ជឹង
គិតឱ្យជាប់នឹងនយោបាយ ។
ដើម្បីផ្ចាញ់ផ្ចាលបច្ចាមិត្ត
ត្រូវចេះគន់គិតឱ្យវែងឆ្ងាយ
វៀចផងត្រង់ផងជាឧបាយ
តែបង្ហាញកាយដូចត្រង់ស្មោះ ។
យុធិស្ថិរទ្រង់ត្រាស់សួរថា
ក្សត្រិយ៍ជាមនុស្សាដូចគេសោះ
ដៃជើងខ្លួនប្រាណពុំានចន្លោះ
អ្វី១ទាំងអស់សឹងដូចគ្នា ។
ហេតុម្តេចក៏មានការបែងចែក
ជាពូក ជាផ្អែក ជាមុខងារ
នៅខ្ពស់ហួសគេ ព្រមទាំងភា-
សាសព្ទរាជាគេប្រើផ្សេង ។
ព្រះភីស្មៈមានព្រះឱង្ការ
ថា អើ! នត្តា កាលពីព្រេង-
នាយកន្លងទៅយូរទន្ទេង
ចូរចៅប្រឹងឈ្វេងយល់តាប្រាប់ ។
ពីដើមមិនមានក្សត្រិយ៍គ្រប់គ្រង
ទណ្ឌនីតិផងគ្មានប្រញាប់
មនុស្សម្នាមិនទាន់ត្រូវការច្បាប់
គេរស់ក្នុងកប្បនៃយុត្តិធម៌ ។
មនុស្សចេះជួយថែរក្សាគ្នា
តាមគោលមាគ៌ាស្មគ្រស្មោះសរ
កាន់ចិត្តវាចាអំពើល្អ
ឯអយុត្តិធម៌ក៏សូន្យដែរ ។
លុះកាលចេះតែកន្លងទៅ
ចិត្តមនុស្សមិននៅនឹង ប៉ុន្តែ
បែរជាទទួលការភ័ន្តប្រែ
លាយឡំឡប់ឡែលែងល្អះល្អ ។

អកុសលកម្មចាប់ដាលដុះ    នាំការថយចុះដល់យុត្តិធម៌
អភិជ្ឈាលេចឡើងភ្លាមបន្ទ    បង្កចិត្តឱ្យចង់តែបាន ។
អ្វីៗមិនមែនរបស់ឯង    ចិត្តគិតហួងហែងវែងហារហាន
លោភលន់មិនគន់គិតប្រមាណ    ចង់តែឱ្យបានមកខាងខ្លួន ។
តណ្ហាបន្ទាប់តាប់ចិន្តា    ពីកាមមុច្ឆាកើតជាសួន
ដោយមានកំហឹងនៅពីងពួន    ដុះដាលខ្វាប់ខ្ជួនក្នុងអារម្មណ៍ ។
ដូច្នេះយុត្តិធម៌ត្រូវតែវាយ    ដកខ្លួនទៅនាយលែងសម្រុំ
តណ្ហាទាំងនេះចេះតែខំ    រីកយ៉ាងក្លាក្លៃក្នុងចិត្តកាយ ។
រួចកើតអារម្មណ៍ច្រឡំបល់    អកុសលនាំផលជាអន្តរាយ
គម្ពីរក្បួនច្បាប់ផងទាំងឡាយ    ខ្ចាត់ខ្ចាយឆ្ងាយពីការសិក្សា ។
ទេព្តាឃើញហេតុដូច្នោះហើយ    ទ្រង់មិនកន្តើយក៏ឆ្លេឆ្លា
ហោះទៅសុំគាល់បិតាមហា    ពីព្រះព្រហ្មាបង្កើតលោក ។
រួចទើបទូលទៅព្រះព្រហ្មថា    សូមបិតាមហាដ៏មានជោគ
បើកទិព្វនេត្រាទតមនុស្សលោក    និងទ្រង់យល់យោគជួយកម្សាយ ។
កម្ចាត់រាល់ហេតុដែលគំរាម    កំហែងភ្លាមៗដោយមហន្តរាយ
ដើម្បីស្តារយកក្តីសប្បាយ    សូមទ្រង់បរិយាយឱ្យត្រង់ត្រាប់ ។
ព្រះព្រហ្មព្រមតាមពួកទេវា    ដោយប្រើមាគ៌ាល្អចំណាប់
ទ្រង់គាក់តែងចែងចងជាច្បាប់    សម្រាប់អនុវត្តគ្រប់ជំនាន់ ។
ជាការអភិប្រាយស្រាយកបកែន    មាត្រាមួយសែនសព្វគ្រប់គ្រាន់
ទុកជាមេរៀនមានពាក់ព័ន្ធ    នឹងការប្រែភ័ន្តនៃហេតុការណ៍ ។

ទ្រង់ចែងពី **ធម្មៈ, អត្ថៈ,** **កាមៈ, មោក្សៈ** តាមមាត្រា
ដោយទ្រង់បរិយាយយ៉ាងពិស្តារ អំពីបញ្ហាមួយចម្បង ។
គឺទណ្ឌនីតិជាក្រឹត្យក្រម ចែកជាបឋមមានពីរកង
មានចំហាផង សម្ងាត់ផង ល្អល្អះឥតហ្មងគួរអបអរ ។
ចែងការអភិរក្សប្រាក់មាសទ្រព្យ សម្បត្តិកេរគាប់ពាណិជ្ជករ
ឬសីត្រូវប្រឹងស្វាធ្យាយធម៌ បង្កើនបន្តដោយតបៈ ។
កម្ទេចឱ្យអស់ការលួចប្លន់ ខិលខូចខាងស្នេហ៍គ្មានសច្ចៈ
បំផ្លិចបំផ្លាញរាល់អប្បលក្ខណ៍ ឱ្យអស់ឥតអាក់ជាប្រចាំ ។
ម្ល៉ោះហើយមានចែកជាសាខា សម្រាប់ត្រួតត្រានីតិកម្ម
សាសនា កិរិយា ទាំងឧបត្ថម្ភ ចារកម្មជាភ្នាក់ងារសម្ងាត់ ។
ដើម្បីកម្ចាត់អយុត្តិធម៌ មាគ៌ាល្អៗត្រូវអនុម័ត
សម្រាប់ឱ្យមនុស្សលោកប្រតិបត្តិ កសាងសីលសត្យដូចធម្មតា ។
លុះព្រះព្រហ្មចងក្រងរួចហើយ ទ្រង់ត្រាស់ឆ្លងឆ្លើយសារស័ព្ទថា
ត្រូវតែផ្សព្វផ្សាយក្នុងលោកា នូវអស់ខ្លឹមសារច្បាប់ព្រះអង្គ ។
គឺធម្មៈ, អត្ថៈ, កាមៈ ដោយមានទណ្ឌៈជួយតម្រង់
បោរទណ្ឌនីតិតាមព្រះអង្គ ជាមាគ៌ាត្រង់ត្រូវប្រព្រឹត្ត ។
ច្បាប់នេះត្រូវបានពួកទេព្តា យកទៅសិក្សាសាកពិនិត្យ
ដោយយោងតាមរយៈកាលជីវិត មនុស្សក្នុងកម្រិតមួយខ្លីហួស ។
ដំបូងព្រះសិវៈសង្ខេប ទៅតាមបទបែបមិនឱ្យជ្រួស
រួចហើយព្រះសុក្រមកជំនួស ជួយសង្ខេបជួសកាន់តែខ្លី ។

នៅសល់មេរៀនត្រឹមមួយពាន់ ជាចំនួនគ្រាន់ល្មមសេចក្ដី
រួចទើបពួកទេព្ដាឃ្មាតខ្មី នាំន័យទូលព្រះវិស្ណុថា ។
បពិត្រអម្ចាស់នៃត្រៃលោក សូមជួយរិះរកយកមនុស្សណា
ឧត្ដុង្គឧត្ដមដោយកិរិយា សមរម្យជាមហាបុគ្គលពិត ។
ព្រះនារាយណ៍ក៏ទ្រង់ត្រាស់ថា ទ្រង់នឹងយាត្រាចាប់ជីវិត
ដោយចរចូលទៅនៅនៃបនិត្យ សណ្ឋិតក្នុងខ្លួនជនណាម្នាក់ ។
អ្នកនោះនឹងទៅជាអម្ចាស់ ខ្ពស់ណាស់ខាងសម្បជញ្ញៈ
រួមទាំងមនុស្សម្នាជាច្រើននាក់ ដែលជាក់ជាកើតនៅពេលនោះ ។
មានក្សត្រិយ៍មួយអង្គព្រះនាមថា ព្រះបាទវេណាសែនល្បីឈ្មោះ
ពីព្រះហស្ដស្ដាំមានកើតមនុស្ស រូបរាងសម្ផស្សដូចឥន្ទ្រា ។
ទ្រង់ប្រសូតមកទាំងអាវក្រោះ សង្ហាលើសអស់សព្វមនុស្សម្នា
ព្រមដោយនូវអស់គ្រឿងសព្វា- វុធនានាជាកេតនភណ្ឌ ។
ទ្រង់ចេះសព្វសិល្បៈចម្បាំង អស់ទាំងគម្ពីរវេទ វេទន្ត
ចាំច្បាស់ប្រាកដអត់មានភ័ន្ត វេទាង្គគ្រប់គ្រាន់ផ្នែកទាំងបី ។
អស់ពួកឫសីព្រមតម្កើង លើកព្រះអង្គឡើងគ្រងផែនដី
ជាក្សត្រិយ៍ពេញដោយបុណ្យបារមី មានព្រះសុក្រថ្លៃជាគុរុ ។
ព្រះអង្គជាបុត្រទីប្រាំបី ដ៏ស្រស់ប្រិមប្រិយ៍នៃវិស្ណុ
ទ្រង់ព្រះនាមថាព្រះប្រឹថុ ដែលឱ្យពសុធារាបផ្ទៃ ។
ព្រះវិស្ណុនិងពួកទេវា នាំគ្នាចុះចាកសួគ៌ាល័យ
មករៀបអភិសេកសែនប្រពៃ លើកប្រឹថុថ្លៃជាមហាក្សត្រិយ៍ ។

ពសុធាលេចមកយ៉ាងសង្ហា នាំបណ្ណាការច្រើនពេកក្លាត់
ត្បូង កែវ មាស ពេជ្រ ជាសម្បត្តិ ដោយចាត់ជាកិច្ចកតវេទី ។
ព្រះប្រឹថុចិញ្ចឹមពសុធា ក្នុងរូបរាងជាព្រះគោញី
ដោយផ្តល់ធញ្ញជាតិទាំងប្រាំពីរ ឱ្យថែជីវិសព្វសត្វលោក ។
តម្រូវឱ្យមនុស្សគ្រប់ជាន់ថ្នាក់ យកចិត្តទុកដាក់ទាំងយល់យោគ
ដល់ព្រះធម្មៈដ៏មានជោគ តាមការយកមកជាមាតា ។
ទ្រង់ទទួលនាមថា **រាជន** ដោយសារព្រះគុណធ្ងន់មហិមា
ព្រោះទ្រង់ធ្វើឱ្យរាស្ត្រប្រជា រីករាយគ្រប់គ្រាគ្មានមោះមៃ ។
ដូចទ្រង់ព្យាបាលរបួសរោគ ឱ្យរាស្ត្រអស់សោកអស់ទុក្ខភ័យ
ជ្រោងទណ្ឌនីតិសែនមានន័យ ល្អគួរគប្បីឱ្យប្រតិបត្តិ ។
ក្នុងក្តីស្នេហាពេកកន្លង រាស្ត្រហៅព្រះអង្គថាជា **ក្សត្រិយ៍**
គឺម្ចាស់ទឹកដីតាមបញ្ញត្តិ ទាំងចាត់ទ្រង់ជាម្ចាស់ជីវិត ។
ពោលគឺទ្រង់ជាទីសក្ការ បីដូចទេព្តានៅជាប់ជិត
និងដោយគុណធម៌បវរពិត រាស្ត្រគិតទ្រង់ថាជា **ប្រឹថពី** ។
គឺនៅក្នុងកាយព្រះប្រឹថុ ដែលព្រះវិស្ណុម្ចាស់ជីវី
ចូលទៅប្រតិដ្ឋនិត្យនៅទី ជាព្រះភូមីនៃមនុស្សម្នា ។
ជាចំណែកព្រះវិស្ណុមួយ ដុះពន្លកត្រួយលើពសុធា
មានប្រាជ្ញាស្មើពួកទេវា ព្រោះជាអវតារនៃព្រះអង្គ ។
មិនអាចរាស្ត្រណោហ៊ានមើលងាយ ការងារសម្ពាយត្រូវត្រឹមត្រង់
ដោយត្រងត្រាប់តម្រាស់ព្រះអង្គ តែទ្រង់មិនត្រូវស្តាប់បញ្ជា ។

យុធិស្ឋិរឱនអង្គបន្ទាប | ចង់ជ្រាបពីភារកិច្ចនានា
ជាចម្បងនៃរាស្ត្រប្រជា | ភីស្មៈពណ៌នាតាមដើមទង ។
ដំបូងរាស្ត្រត្រូវរើសក្សត្រិយ៍តាំង | លើរាជបល្ល័ង្កគ្រាន់គ្រប់គ្រង
រៀបបុណ្យអភិសេកកុំរំលង | កុំឱ្យឆ្គាំឆ្គងខុសទម្លាប់ ។
រាស្ត្រត្រូវគិតដល់រាជឃ្លាំង | ដោយបង់ពន្ធទាំងរបស់ទ្រព្យ
ពាហនៈប្រាក់មាសឱ្យទៀងជាប់ | ទៅតាមបង្គាប់មួយភាគប្រាំ ។
មួយភាគដប់នៃគ្រាប់ធញ្ញជាតិ | កុំឱ្យចាកឃ្លាតពីចំណាំ
ចំណែកនៃពន្ធបង់ប្រចាំ | ពីផ្សាំដល់ការកសាងជាតិ ។
កែនទ័ពត្រៀមអាវុធយុទ្ធភណ្ឌ | ឱ្យបានគ្រប់គ្រាន់កុំឃ្លៀងឃ្លាត
សម្រាប់ជួយក្សត្រិយ៍និងរាស្ត្រទៀត | ដើម្បីជួយជាតិឱ្យគង់វង្ស ។
រាស្ត្រត្រូវគោរពលើកតម្កើង | មហាក្សត្រិយ៍ខ្លួនឡើងឱ្យទ្រើសទ្រង់
ទើបបច្ចាមិត្តខ្លាចក្រែងក្រង | ផែនការក្បត់គង់តែរលាយ ។
មហាក្សត្រិយ៍ត្រូវឱ្យមានកងទ័ព | សន្ទឹកសន្ទាប់ក្នុងបន្ទាយ
ក្នុងក្រុងនិងតាមព្រំដែននាយ | តែកុំទម្លាយការសម្ងាត់ ។
ត្រូវចេះត្រួតខ្លួនព្រះអង្គផ្ទាល់ | គឺចេះដឹងស្គាល់និងកម្ចាត់
សត្រូវក្នុងខ្លួនឱ្យបង់បាត់ | ទើបក្សត្រិយ៍ទទួលជោគជ័យធំ ។
ព្រះតម្រិះ សេចក្ដីសម្រេច | ត្រូវចាត់ឱ្យដាច់ពីជំនុំ
ចាត់តាំងចារកម្មតាមសមរម្យ | ដោយលាក់សម្ងំជាសម្ងាត់ ។
ពិសេសជាមួយបច្ចាមិត្ត | ត្រូវលាក់ឱ្យជិតស្ងួនស៊ុងបាត់
បើដឹងកាលណាវារសាត់ | លឿនដូចខ្យល់ផាត់គ្មានបណ្ដាក់ ។

ចារកម្មត្រូវរកអ្នកក្លែងធ្វើ ជាមនុស្សភ្លីភ្លើដូចថ្លង់ខ្វាក់
តែមានសមត្ថភាពយ៉ាងប្រត្យក្ស ឈ្លាសវៃហើយស្ម័គ្រសព្វសីមប្រើ ។
សុខភាពកាយសម្បទាល្អមាំ អាចទ្រាំត្រជាក់ក្តៅបានស្មើ
អាចទ្រាំទុរ្ភិក្សតាមដំណើរ សឹមប្រើឱ្យដើរទេសធ្វើការ ។
ពួកចារបុរសស្តេចអាចតែង- តាំងក្នុងតំណែងទីប្រឹក្សា
ក្នុងពួកមិត្តភក្តិ រាជបុត្រា ឯការដឹងគ្នាត្រូវចៀសវាង ។
ប្រឹងប្រែងកសាងសន្តិភាព បើជ្រាបថាខ្មាំងខ្លាំងក្លាជាង
តែបើក្នុងករណីទាត់ទៀង ថាយើងខ្លាំងជាងសឹមប្រយុទ្ធ ។
ត្រូវចេះប្រើល្បិចទ័ពវាយឆ្មក់ លបលាក់លួចឆក់ដូចមានពុត
កុំញញើតនឹងប្រើអាវុធ ថ្នាំពុលអាចពត់លត់ដំខ្មាំង ។
យកពន្ធរាស្ត្រមួយភាគប្រាំមួយ សម្រាប់លើកស្ទួយដល់ចម្បាំង
ព្រោះជាប្រភពផ្តល់កម្លាំង ឱ្យច្បាំងឈ្នះខ្មាំងតាមទិសដៅ ។
មហាក្សត្រិយ៍ត្រូវបានចាត់ទុកថា ទ្រង់ជាបិតា រាស្ត្រ កូនចៅ
តែក្នុងន័យនេះព្រះអង្គត្រូវ គិតទៅដល់ការសន្តោសផង ។
ជាពិសេសនៅពេលធ្វើទោស កុំប្រោសឱ្យហួសពេកកន្លង
ត្រូវទុកច្បាប់ជាគោលចម្បង កុំឱ្យមានហ្មងផ្នែកអនុវត្តន៍ ។
ឱ្យជនមានចិត្តស្មោះត្រង់ល្អ កាន់ការយុត្តិធម៌ដោយហ្មត់ចត់
ទើបនគររុងរឿងប្រាកដ តាមដោយបែបបទដរាបរៀង ។
លើរាល់កិច្ចការយុត្តិធម៌ បើធ្វើបានល្អឥតបីល្អៀង
ទេព្តាឱ្យផ្គរពពកភ្លៀង បង្អុរទាត់ទៀងតាមរដូវ ។

បើក្សត្រិយ៍អាស្រ័យយុត្តិធម៌ នគរនឹងអាចទៅជាផ្លូវ
នាំឱ្យក្រឹតយុគ[១] ចរចូលទៅ ប្រតិស្ឋាននៅជាស្ថាពរ ។
បើសច្ចធម៌ស្ថិតអធិរ៉ែ្ទ្រយ៍ យុត្តិធម៌ឱ្យផ្ដៃចាករីករវរ
កើតការអភិវឌ្ឍន៍ឥតឈប់ឈរ ទេព្តាឱ្យពរដល់មនុស្សសត្វ ។
គម្ពីរវេទថែងថ្លែងពណ៌នា ថារាស្ត្រប្រជានិងសម្បត្តិ
ទាំងអស់ជារបស់មហាក្សត្រិយ៍ ដោយលើកលែងកាត់តែពួកព្រាហ្មណ៍ ។

ដែលក្សត្រិយ៍ត្រូវរក្សាថែថូន ជាកិច្ចផងខ្លួនតាមទំនៀម
ទុកជាព្រះគ្រូ ជាព្រះរៀម ក្នុងនាមព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ។
ក្សត្រិយ៍ត្រូវមានមិត្តជាច្រើននាក់ ជាអ្នកស្មោះស្ម័គ្រផ្ដល់កិត្តិយស
អាចចែកជាបួនដោយចំពោះ គឺគិតពីមនុស្សចិត្តស្មោះត្រង់ ។
មួយ គឺមនុស្សណាមានគោលដៅ ស្របគ្នាឥតសៅនឹងព្រះអង្គ
ពីរ អ្នកឧទ្ទិសខ្លួនដោយផ្ចង់ ចិត្តឆ្ពោះព្រះអង្គត្រង់ឥតវេ ។
បី គឺអ្នកនៅក្នុងរាជវង្ស ដែលជាប់ពូជពង្សពីបុព្វេ
បួន គឺមនុស្សដែលក្សត្រត្មាន់ត្មេរ តាមការផ្គូរផ្គងប្រទានទ្រព្យ ។
អាចមានមនុស្សប្រភេទទីប្រាំ ជាអ្នកបញ្ចាំចិត្តយ៉ាងជាប់
នឹងផ្ដេកតែមួយតាមគេគាប់ គឺភ្ជាប់ខ្លួននឹងភាពត្រង់សុទ្ធ ។
ចំពោះមនុស្សនេះចូរចៅចាត់ រាល់ការសម្ងាត់ចៀសឱ្យផុត
ព្រោះដ្បិតចិត្តគេស្មោះចំហុត នឹងភាពត្រង់សុទ្ធពិតឥតក្លែង ។

---

១. យុគ.- សូមអានអត្ថបទកាព្យស្ដីពីយុគទាំង ៤ នៅទំព័រ ១២៦ និងទំព័រ ១៣២ ។

អនុលោមតាមកាលៈទេសៈ ត្រូវចេះទុកដាក់ទាំងពិតក្រែង
ភាពត្រង់ឬវៀចដោយថ្លឹងថ្លែង ប្រយ័ត្នប្រយែងតាមវិចារណ៍ ។
មនុស្សខូចអាចស្តែងជាស្មោះត្រង់ អ្នកស្មោះអាចបង់បាត់កិរិយា
ជាអ្នកស្មោះពិតនឹងក្សត្រា ព្រោះអារម្មណ៍មនុស្សតែងប្តូរផ្លាស់ ។
ដូច្នេះកុំទុកចិត្តទាំងស្រុង ព្រោះអាចឱ្យផុងខ្លួនជ្រៅណាស់
អាចធ្លាក់ចូលក្នុងចិត្តវិបល្លាស នៃមន្ត្រីខ្លះៗមិនលែង ។
មិនត្រូវស្ទះស្ទែងដោយប្រកិត រកការទុកចិត្តពីគេឯង
នេះជាកំហុសធំក្រៃលែង ចៅត្រូវថ្លឹងថ្លែងយកទាំងពីរ ។
ទាំងទុកចិត្តនិងមិនទុកចិត្ត ពោលគឺផ្តេកផ្តិតចិត្តទាំងទ្វី
ទុកចិត្តទាំងស្រុងខុសពេញទី តាមប្រពៃណីយើងជាក្សត្រិយ៍ ។
ស្តេចត្រូវធ្វើឱ្យរាស្ត្រកោតខ្លាច តែកុំកោងកាចរហូតកាត់
ផ្តាច់ពីក្តីគោរពប្រណិប័តន៍ ព្រោះរាស្ត្រអាចខ្ចាត់ចៀសចេញឆ្ងាយ ។
ក្សត្រិយ៍គ្មានប្រជារាស្ត្រជាទ្រព្យ ជាក្សត្រិយ៍អភ័ព្វលែងសប្បាយ
តោងកុំទុកចិត្តតែកាន់កាយ រួសរាយដូចជាទុកចិត្តណាស់ ។
ទើបរាស្ត្រមានសាមគ្គីមាំមួន ជុំវិញក្សត្រិយ៍ខ្លួនមិនក្រឡាស់
កិច្ចការអាចចាត់ចែងបានច្បាស់ កិត្តិយសខ្ពស់ណាស់ដល់រាជា ។
ពួកនីតិពន្ធ ពួកសេនីយ៍ ឧកញ៉ា ចក្រី រាជបរិពារ
ត្រូវកាន់ឬករាបសានឹងក្លា ទើបរាស្ត្រប្រជាអាចកក់ក្តៅ ។

ត្រូវស្ទួយសច្ចធម៌ភាពស៊ីទ្ធស្មារតី — រូបរាយគ្រប់កាលក្នុងក្រៅ
ចេះត្រួតវិញ្ញាណរបស់ចៅ — សម្តីសំដៅត្រូវប្រត្យក្ស ។
ឧកញ៉ាចក្រីកាន់ចម្បាំង — ត្រូវរើសមនុស្សខ្លាំងទាំងចិត្តស៊ីគ្រ
ស្មោះត្រង់នឹងក្សត្រិយ៍ជាចមចក្រ — ខ្ពស់ទាំងវណ្ណៈ ទាំងវិជ្ជា ។
សព្វមុខមន្ត្រីនៃរាជវាំង — រួមទាំងពូកព្រះរាជបរិពារ
ត្រូវមានពូជពង្សខ្ពស់ដូចគ្នា — សីមព្រះរាជាផ្តល់អម្រស់ ។
ត្រូវតែមានចិត្តស្វាមីភក្តិ — គ្រប់កាលៈទេសៈទាំងអស់
ដង្ហែព្រះអង្គមិនបង់បោះ — ទោះត្រូវឬខុសត្រូវការពារ ។
កូនទ័ពទាំងមេនិងឧកញ៉ា — សេនីយ៍ សេនា គ្រប់មុខងារ
ត្រូវឱ្យពេញកាយសម្បទា — រាងសមសោភា មាឌមាំមួន ។
ទាំងកាន់កិរិយាល្អឥតខ្ចោះ — ចំពោះមហាក្សត្រិយ៍ឱ្យខ្ជាប់ខ្ជួន
ដោយត្រូវដាក់ចិត្តឧទ្ទិសខ្លួន — ជាសួនជីវិតនៃមហាក្សត្រិយ៍ ។
ចៅត្រូវចងចាំជាប់ជានិច្ច — កុំឱ្យភ្លាំងភ្លេចភ្លាត់បង់បាត់
ចាត់ការផែនដីដោយមធ្យ័ត — ទើបក្សត្រិយ៍ទទួលបុណ្យបារមី ។
យុត្តិធម៌ត្រូវតែដើរមុនគេ — បើក្សត្រិយ៍ធ្វេសទ្វេនឹងអប្រិយ
ព្រោះជាគ្រឹះមាំនៃជោគជ័យ — និងក្តីចម្រើនលើពសុធា ។

៙៣៙

# ច្បាប់ព្រះភិក្ខុ (គ)

## បទកាកគតិ

ត្រូវរើសព្រាហ្មណ៍បួន អង្គដែលមាំមួន ក្នុងសព្វវិទ្យា-
សាស្ត្រផ្នែកត្រៃវេទ ទាំងការឫកពា ឧត្តមមហិមា
មិនមានចន្លោះ ។
ប្រាំបីអង្គចាត់- តាំងក្នុងវង្សក្សត្រិយ៍ រូបឆោមល្អស្រស់
ទាំងកាយសម្បទា មាំទាំទាំងអស់ ប្រសប់ឥតខ្ចោះ
នឹងសព្វាវុធ ។
រើសពួកវេស្សៈ ត្រឹមម្ភៃមួយនាក់ ជាអ្នកមុះមុត
ទាំងបរិបូណ៌ទ្រព្យ ល្អគាប់ទាំងពុត និងត្រូវស្រគត់
ស្រគំកិរិយា ។
ឱ្យពួកសូទ្រៈ ចំនួនបីនាក់ កាន់កិច្ចរាជការ
រើសយកសូតៈ តែម្នាក់អាត្មា អ្នកទាំងនេះណា
ជារាជមន្ត្រី ។
ត្រូវកាន់កិរិយា ប្រពៃថ្លៃថ្លា ជាប់ជាប្រក្រតី
ធូរធារដោយទ្រព្យ ចំណេះគប្បី ខ្ពង់ខ្ពស់ពិសី
ពិសេសទាំងសព្វ ។

ដំបូងតេទុះ ត្រូវលើកកិត្តិយស ទុកជាសក្ការ
សម្រាប់យើងគឺ មាតាបិតា ព្រមទាំងគ្រូបា-
ធ្យាយឱ្យប្រពៃ ។

បម្រើបិតា នឹងនាំបុត្រា ឆ្លងផុតលោកិយ
បម្រើមាតា បានសួគ៌ាល័យ បម្រើបាធ្យាយ
នឹងដល់ព្រហ្មា ។

សោតឯ **ធម្មៈ**, **កាមៈ**, **អត្ថៈ** តែងកើតព្រមគ្នា
កាលបើមនុស្សម្នាក់ ស្វែងរកទ្រព្យា នៅក្នុងមាគ៌ា
ដែលជា **ធម្មៈ** ។

ការស្វែងរកទ្រព្យ សម្បត្តិកេរតាប់ គួរកើតជៀងជាក់
នៅក្នុងគុណធម៌ នោះទើបសុភ- មង្គលរូបរ័ក្ស
ដល់អ្នកជាម្ចាស់ ។

សារធាតុទាំងបី តែងកើតក្នុងផ្ទៃ នៃចិត្តក្មេងចាស់
ធ្វើឱ្យគុណធម៌ កែប្រែប្តូរផ្លាស់ អារម្មណ៍ក៏ក្រាស់
ដោយក្តីប្រាថ្នា ។

ចង់ឱ្យវិញ្ញាណ ទាំងប្រាំជាយាន នៃមនសិការ
ស្គាល់ក្តីរីករាយ ស្របនឹងតណ្ហា តាមចិត្តប្រាថ្នា
អ្វីជាលោកិយ ។

ការតមតណ្ហា តមក្តីប្រាថ្នា ផ្តាប់ញាណស្មារតី
ជាការរំដោះ ខ្លួនយ៉ាងគប្បី ធម៌នេះមានន័យ
ថាការពារខ្លួន ។

រីឯទ្រព្យធន គួរគិតគួរគន់ តាមការថែថួន
សម្រាប់ប្រើឱ្យ ទាញទុកជាស្នូន គឺដាក់ជាប់ខ្លួន
អ្វីជាគុណធម៌ ។
ការផ្ដាប់វិញ្ញាណ អាចនាំឱ្យហ៊ាន បំពានក្ដីល្អ
ព្រោះមានតណ្ហា ជាគ្រឿងញាប់ញ័រ នៃអកុសលធម៌
ទាំងបីនេះឯង ។
តែផ្ទុយទៅវិញ បើគេបំពេញ តាមការស្វះស្វែង
រកតណ្ហាមួយ ល្អល្អះក្រៃលែង គឺស្គាល់ខ្លួនឯង
ទើបហៅវិជ្ជា ។
នឹងបានជាធំ ប្រសើរឧត្តម សក្តិសមមហិមា
ទាំងជួបពាក្យពោល សរសើរគ្រប់គ្រា ឯពាក្យនិន្ទា
នឹងបាត់ស្ងាត់ឈឹង ។
ត្រូវតែស្វែងរក យកគុណធម៌មក ឱ្យនៅនិត្យនឹង
ជាប់ក្នុងអារម្មណ៍ ទុកជាទីពឹង នោះទើបព្រលឹង
អាចបរិសុទ្ធល្អ ។
ទ្រព្យធនទាំងឡាយ ត្រូវហ៊ានចំណាយ ក្នុងសប្បុរសធម៌
គឺដោយមិនគិត គួរដល់ផលប្រ- យោជន៍ដែលកើតត
ពីការចាយវាយ ។
**ធម្មៈ, អត្ថៈ** ព្រមទាំង **ភាវៈ** ចាក់ឫសយ៉ាងងាយ
ជាប់នៅក្នុងចិត្ត ដែលគិតពាយងាយ មិនអាចរលាយ
បានដោយខ្លួនឯង ។

ប៉ុន្តែតណ្ហា ទាំងបីប្រការ តាមភាពជាក់ស្តែង
អាចសូន្យសុងសោះ បាត់អស់ខ្លួនឯង បើគេប្រឹងប្រែង
ឱ្យដល់ **មោក្ខៈ** ។

បើឈានដល់ហើយ បីដូចដល់ត្រើយ ព្រោះអស់លោភៈ
តណ្ហានានា លែងជាប់ជំពាក់ ចិត្តស្អាតស្អំជាក់
ព្រោះបានរំដោះ ។

ការរំដោះខ្លួន ជាកិច្ចត្រូវស្ងួន ដោយចិត្តស្ម័គ្រស្មោះ
ព្រោះជាគោលដៅ ដ៏ខ្ពស់បង្អស់ តែមួយប៉ុណ្ណោះ
នៃជនគ្រប់គ្នា ។

ប្រាជ្ញាឈ្លាសវៃ ជាមិត្តប្រពៃ បីដូចទ្រព្យា
ដែលអាចជួយក្នុង ផែនការនានា ពិសេសក្នុងគ្រា
គ្រាជាអាសន្ន ។

ជួនមានសត្រូវ ពីដើមនោះត្រូវ អាចត្រូវប្រែក្លាយ
បែកជាមិត្តវិញ នៅពេលបច្ចុប្បន្ន តាមហេតុបន្ទាន់
កាលៈទេសៈ ។

ពេលនោះតែម្តង ដែលប្រាជ្ញាផង ស្តែងឡើងប្រត្យក្ស
ឱ្យឃើញដោយពិត ថាជាមិត្តភក្តិ មានចិត្តស្មោះស្ម័គ្រ
ចាំជួយភ្លាមៗ ។

គឺកើតដោយសារ ការប្រើប្រាជ្ញា ជាទ្រព្យចាំត្រៀម
សម្រាប់សម្រេច ចិត្តឬនៅស្ងៀម លើសឹកសង្គ្រាម
និងសន្តិភាព ។

មានកត្តាពីរ គឺពេលនិងទី ដែលក្សត្រិយ៍ត្រូវជ្រាប
ជូនជាមួយខ្មាំង ត្រូវចងមិត្តភាព ទៅតាមគំនាប
កាលៈទេសៈ ។

សន្និសញ្ញា មិត្តភាពសព្វសារ- ពើ កុំទុកដាក់
នៅក្នុងអារម្មណ៍ ជាគោលប្រត្យក្ស ព្រោះអាចជំពាក់
អាត្មានិយម ។

បើតាមពិតទៅ មិត្ត និង សត្រូវ ជាពាក្យផ្សំផ្គុំ
មិត្តភាពអាចគង់- វង្ស មិនរលំ បើប្រយោជន៍ធំ
នៅមានដោយពិត ។

អាត្មានិយម ជាកត្តាធំ នៅក្នុងជីវិត
ដូចមោហ៍វិលវង់ ក្នុងភាពងងឹត តែងជាប់នៅនិត្យ
តាមចិត្តបំពាន ។

មិត្តភាពស្មោះត្រង់ នឹងបែកបាក់បង់ នៅពេលណាមាន
ប្រយោជន៍ផ្ទាល់ខ្លួន ចូលមកទន្ទ្រាន ឯសទ្ធាទាន
ត្រូវតែរលាយ ។

មនុស្សមានប្រជា- ប្រិយរាល់វេលា គួរចាត់ជានាយ
មិនក្បត់ចិត្តខ្លួន មានចិត្តទូលាយ ទាំងចេះនិយាយ
យ៉ាងផ្អែមពីរោះ ។

លក្ខណៈទីបី ដែលល្អប្រពៃ គឺស្មោះចំពោះ
ទៅលើសាសនា នោះទើបមានឈ្មោះ ពេញដោយកិត្តិយស
ជាអ្នកបម្រើ ។

ប្រាជ្ញចែងមកថា មនុស្សពីរអាត្មា ជាម្រាក់ឫក្លើ
សាមគ្គីនឹងគ្នា មិនខ្វែងដំណើរ ចិត្តស៊ប់ត្រស្មោះស្មើ
តែលើមិត្តភាព ។
នេះបានន័យថា ទាំងពីរអាត្មា កំពុងប្រុងប្រៀប
ឆ្លៀតរកចំណេញ កេងកាញ់ជាលាភ ដោយប្រឹងយកប្រៀប
លើដៃគូខ្លួន ។
អ្នកណាឆ្លាតជាង ប្រាកដទាត់ទៀង បានប្រយោជន៍សួន-
តូជាជោគជ័យ ដោយតែលាក់ពួន តាមន័យនៃក្បួន
មួយទៀតលោកស្ដី ។
ថាបើប្រយោជន៍ កាន់តែហិនហោច លែងបានគប្បី
នោះសាមគ្គីភាព នឹងបាត់សូស្ដី អ្វីធ្លាប់ពិសី
នឹងសូន្យអសារ ។
បើមានគំនិត ខ្លាចបច្ចាមិត្ត ត្រូវកាន់កិរិយា
ដូចជាមិនខ្លាច រអែងរអា នេះជាតម្រា
នៃនយោបាយ ។
ម្យ៉ាងទៀតយើងត្រូវ មើលឱ្យឃើញផ្លូវ ដោយបង្ហាញកាយ
ថាដូចទុកចិត្ត ទាំងស្រុងឥតស្រាយ តែគិតវែងឆ្ងាយ
កុំទុកចិត្តសោះ ។
រួចហើយនគ្គា សួរអយ្យកោថា បាបកម្មទាំងអស់
កើតមានប្រភព ពិតជារបស់ វាតាមចន្លោះ
នៃមូលហេតុណា ។

ឱ! ចៅតាអើយ អភិជ្ឈានេះហើយ ដែលជាកត្តា
ដើមគេបង្អស់ ជាមែកសាខា ឱ្យកើតផ្លែផ្កា
បានជាបាបកម្ម ។

បាបកម្មជាពិស មានគល់ចាក់ឫស ជាប់ជាប្រចាំ
នៅនឹងអភិជ្ឈា ជាថ្នាលដុះដាំ ហើយតែងតែចាំ
កម្ទេចកុសល ។

មួយទៀតអភិជ្ឈា អាចចាត់ទុកជា និទាឃៈផ្ទាល់
នៃអំពើពាល ពុតត្បុតរំបល់ កំហឹងកំហល់
កាមមុច្ឆា ។

វាឱ្យបាត់បង់ ទឹកចិត្តទៀងត្រង់ ការពិចារណា
សុភនិច្ឆ័យ អស់ន័យខ្លឹមសារ ជំងឺគ្រៀបគ្រា
គ្រាំគ្រែងរបំងុរ ។

ជំងឺនានា ដែលមានអភិជ្ឈា ចាក់ជាឫសគល់
មានការខកចិត្ត ពំនិតពិសពុល រវៀសរវល់
ផ្ដាប់តែតណ្ហា ។

កាន់ឫកព្រហើន គុំកួនផ្ដាប់ផ្ដើន តាមមហិច្ឆតា
មិនចេះខ្មាសគេ មិនខ្មាសអាត្មា កេរ្តិ៍ឈ្មោះអសារ
អសោចរហ៊ុម ។

មួយទៀតអភិជ្ឈា អាចឱ្យកើតជា ក្ដាមូលមកជុំ
ដូចជាទ្រឹស្ដិស្នូរ លោភលន់ ចិត្តធំ ឫកមិនសមរម្យ
គឺមានអំនួត ។

អ្នកពីកំណើត អ្នកខ្លួនល្អឆើត អ្នកឪតាទួត
អ្នកមានធនទ្រព្យ អ្នកគាប់ខាងត្រួត អ្នកហៅសែនឆ្លាត
អ្នកចេះគ្មានសល់ ។

អ្នកពីកូនចៅ ពីពូជពង្សផៅ ពីល្បិចកិច្ចកល
កម្សត់ក្លាហាន ថាគ្មានគេដល់ អ្នកបុណ្យកុសល
ថាមានទាំងអស់ ។

ជំងឺតណ្ហា នាំឱ្យកិរិយា វិលវល់ហើរហោះ
រកតែបាបកម្ម បាត់បង់ភាពស្មោះ ស្តីច្រឡោះបោះ
ល្បុះដោយទូលពិត ។

កើតចិត្តជាចោរ ទោរសោរមោហា បំផ្លាញញាតិមិត្ត
ទោះបីខ្លួនចាស់ ក៏នៅមិនគិត ឱ្យភាពទុច្ចរិត
ផុតហេតុះឡើយណា ។

ឱ! យុធិស្ឋិរ ចូរគិតពីកេរ្តិ៍- ឈ្មោះរាជវង្សា
ចូរកាន់ឱ្យតាប់ ជាប់ក្នុងចិន្តា ទុកជាតម្រា
សម្រាប់រាជា ។

ចៅត្រូវជម្នះ ការធ្វើកញ្ជះ រោគអភិជ្ឈាៗ
បើរឹងប្រព្រឹត្ត ពិតជាវេទនា រាល់រាស្ត្រប្រជា
នឹងស្គាល់តែទុក្ខ ។

មនុស្សលោកគ្រប់គ្នា បើយកអភិជ្ឈា ធ្វើជាត្រីមុខ
ទោះបីរៀនសូត្រ ច្រើនពេញបន្ទុក ក៏គង់អាប់មុខ
ឈ្មោះមិនល្អជា ។

# ច្បាប់ព្រះភិក្ខុ (ត)

បទពាក្យ៨

យុធិស្ឋិរត្រាស់សុំទៅអយ្យកោ ថាឱ! អយ្យកោសូមទ្រង់ពណ៌នា
ឱ្យអស់នូវន័យនៃ អវិជ្ជា តើបែបបទវាយ៉ាងដូចម្តេចខ្លះ ។
ទូលព្រះបង្គំយល់ដោយសើ១ ជ្រួតជ្រាបដំណើរមិនទាន់បានច្បាស់
សូមអយ្យកោវែកញែកឱ្យស្រឡះ តាមព្រះតម្រាស់នាពេលនេះម្តង ។
នត្តាអើយ! អស់ទាំងអវិជ្ជា មានប្រភពវាជាគ្រឹះចម្បង
នៅនឹងអភិជ្ឈាជាធមិសៅហ្មង ធមិទាំងពីរកងកើតឡើងព្រមគ្នា ។
អភិជ្ឈានាំឱ្យបាត់បង់គំនិត ត្រឹមត្រូវល្អពិតហួសនឹងពណ៌នា
ទាំងពីរនេះតែងចងរឹតសាមគ្គា ជាគូគ្រប់គ្រា បំបែកមិនបាន ។
ករណីយកិច្ចដែលខ្ពង់ខ្ពស់បង្អស់ ចូរចៅចាំចុះចាត់ជាកល្យាណ
គឺត្រួតឥន្ទ្រិយសាមាន្យឱ្យបាន នេះហើយត្រើយត្រាណនៃជោគជយា ។
ព្រោះជាគុណធមិឱ្យកើតខន្តី សន្តោស ប្រណី ផុតក្តីចងពៀរ
កើតចិត្តសប្បុរសបាត់អស់ក្រោធា អស់អភិជ្ឈាកើតចិត្តទូលាយ ។
សម្តីផ្អែមល្ហែមថែមទាំងកិរិយា សុភាពរាបសាចិន្តារីករាយ
ស្ម័គ្រស្មោះចាំជួយការងារសម្ចាយ មិនមានពាយងាយនឹងសច្ចធមិ ។
ជនដែលត្រួតត្រាវិញ្ញាណខ្លួនបាន មិនអាចផុងប្រាណទៅជាទាសករ
នៃឧបាទានជាញាណមិនល្អ ជាបាបធមិដ៏ធំណាស់សា ។

ឥឡូវពោលើកពីសច្ចធម៌ ជាគុណធម៌ល្អមួយសែនថ្លៃថ្លា
ជាករណីយកិច្ចមនុស្សរាល់អាត្មា ដែលលោកចាត់ថាជាមហាតបៈ ។
លោកថាជម្រកដ៏ខ្ពស់បំផុត គឺចិត្តបរិសុទ្ធនឹងធម៌សច្ចៈ
ដែលត្រូវចាត់ទុកជាសក្ការៈ ខ្ពង់ខ្ពស់ឥតអាក់ជាក់ដល់ព្រះព្រហ្ម ។
សច្ចធម៌ជាធម៌នៃត្រៃលោកនេះ ចូរចៅត្រិះរិះចាត់ជាផ្នែកធំ
មានដប់បីយ៉ាងជាតាងសង្គម ដ៏សែនសមរម្យរៀងដូចតទៅ ។
មួយ គឺមិនត្រូវកាន់ពូកកាន់បក្ស រើសអើងវណ្ណៈ ព្រោះនាំអាស្រូវ
ពីរ គឺត្រួតត្រាខ្លួនឱ្យត្រឹមត្រូវ កាន់ឱ្យជាប់នូវវិញ្ញាណបរិសុទ្ធ ។
បី គឺសន្ដោសប្រោសប្រាណប្រណី មិនគួរគប្បីវាយដំសម្លុត
បួន គឺរាបសាសុភាពបំផុត ឱនអង្គលំអុតលម្អកិរិយា ។
ប្រាំ គឺខន្តីឬថាអំណត់ គឺត្រូវចេះអត់ ចិត្តមិនខ្លាំងក្លា
ប្រាំមួយ កុសលកម្មជាចរិយា ត្រូវផ្គង់ចិន្ដាបំពេញឱ្យបាន ។
ប្រាំពីរ ស្ថិតនៅលើការលះបង់ បំបាត់ចំណង់ជាគ្រឿងសាមាន្យ
ប្រាំបី គឺការភាវនាជាត្រាណ- ត្រើយដែលឱ្យបានទៅដល់ទេព្ដា ។
ប្រាំបួន នៅលើសេចក្ដីថ្លៃថ្នូរ ចូរផ្ដួលផ្ដាច់ប្ដូរកាយចិត្តកិរិយា
ដប់ គឺប្រឹងអត់ធន់ក្នុងចិន្ដា ដោយប្រើប្រាជ្ញាជាកត្តាធំ ។
ដប់មួយ បានដល់សេចក្ដីមេត្តា អាសូរករុណាចៀសវាងពិនុំ
ដប់ពីរ ជាឧបេក្ខាគឺពុំ ញ៉ាំងឱ្យអារម្មណ៍កើតការផ្អើលភ្ញាក់ ។
ដប់បី តមកុំធ្វើទុក្ខបុកម្នេញ ពេងឯនោះមិញ ព្រោះអាចឱ្យអ្នក
រងគ្រោះតបត កកើតកាប់ចាក់ ដូចយកគ្រោះថ្នាក់មកដាក់លើប្រាណ ។

ធម៌ទាំងដប់បីនេះជាទិដ្ឋ- ភាពនៃសច្ចធម៌ដ៏ថ្កើងថ្កាន
ជាធម៌អមតៈផ្លាស់ប្តូរមិនបាន វាស្ថិតក្នុងស្ថានភាពជានិរន្តរ៍ ។
ដូច្នេះយើងត្រូវតែខំស្វែងយល់ ពីក្តីអំពល់ដែលត្រូវគ្មេរគ្មាន
ដើម្បីរត់តាមព្រឹត្តិការណ៍ឱ្យទាន់ ចៅកុំធុញទ្រាន់បន្តសណ្តាប់ ។
សកលលោកនេះតាមភាពជាក់ស្តែង កំពុងកំហែងដោយសេចក្តីស្លាប់
មួយថ្ងៃមួយយប់ហាក់ដូចជាចាប់ យកសេចក្តីស្លាប់មកកាន់តែជិត។
ជូនកាលគោលដៅមិនទាន់សម្រេច ស្រាប់តែត្រូវដាច់បាត់ជន្មជីវិត
ដូចខ្លាចាប់ម្រឹគរួចមិននៅនិត្យ តែខាំហើយមឹតពាំនាំយកទៅ ។
សេចក្តីស្លាប់មានភាពទៀងទាត់ពិត ប៉ុន្តែជីវិតមិនទៀងនឹងនៅ
អាចឈានមកដល់ក្នុងពេលឥឡូវ ឬក៏អាចត្រូវនៅយូរយារទៀត ។
ដូច្នេះអ្វី ៗដែលគ្រោងបំពេញ ត្រូវតែម្នោម្នេញមានះឆ្លាស់ឆ្លៀត
បង្ហើយឱ្យស្រេចបំណាច់នឹងឃ្លាត ទៅជាតិមុខទៀតយើងលែងវិលវល់។
ច្បាស់ជានឹងបានជួបជូនផលល្អ នៃគុណធម៌ជាសុភមង្គល
ព្រោះសេចក្តីស្លាប់ពុំមានយោគយល់ មិនថាបុគ្គលនោះជាអ្នកណា ។
មនុស្សលោកគ្រប់រូបលើប្រឹថពី តែងត្រូវញាំញីដាបដោយតណ្ហា
ជាចំណងចងរាប់ពាន់ប្រការ ព្រោះតែចិន្តាចង់ផ្តាប់វិញ្ញាណ ។
ជាប់ជំពាក់ចិត្តនឹងមនុស្សដូចគ្នា ស្វាមី ភរិយា បុត្រា ព្រៀងលាន
ការងារ ដីធ្លី សព្វទ្រព្យធនធាន វាចាក់ស្រេះគ្មានអ្វីអាចស្រាយបាន។
ហាក់បីដូចជាសំណាញ់ពីងពាង ដែលត្បាញឥតល្បៀងដូចជាងចំណាន
មិនឱ្យមនុស្សរុះបានដោយគ្មានល្ហាន ឯឧបាទានមានន័យដូចគ្នា ។

មានតែសេចក្ដីស្លាប់ប៉ុណ្ណោះឯង ដែលមកសម្ដែងឱ្យឃើញវេទនា
ដោយកម្មេចសំណាញ់ចាក់ស្រេះគ្នា ដូចនាំវេវាដល់បរលោកនាយ ។
មិនមានអ្វីអាចធ្វើជាកម្លាំង ប្រយុទ្ធប្រឆាំងវាបានដោយងាយ
ក្រៅពីសច្ចធម៌ដែលត្រូវវេចស្ពាយ ទើបអាចទម្លាយឧបាទានបាន ។
អ្នកស្គាល់តម្លៃរបស់ពិតៗ នឹងកើតគំនិតពិតយល់ជាថ្កាន
នូវអនន្តភាពអ្វីទាំងប៉ុន្មាន ដែលកើតផតស្រាន្តនៅក្នុងលោកា ។
ជនណាអាចចិញ្ចឹមសច្ចធម៌ ជានិរន្តរនៅក្នុងចិន្តា
ជននោះមិនលុះជាមួយមរណោ មិនអាចរអា រអែង រងា ។
នៅក្នុងខ្លួនប្រាណនៃមនុស្សតែមួយ គេអាចឃើញត្រួយដុះជាមួយគ្នា
គឺមរណភាព អមតភាព ជា សច្ចធម្មាក្នុងដៃឆ្វេងស្ដាំ ។
ប៉ុន្តែចំពោះជនជាបណ្ឌិត លោកអាចត្រួតចិត្តនិងវិញ្ញាណប្រាំ
ដោយឃ្មនៅខ្ពស់ហួសតណ្ហាជាថ្នាំ ដែលតែងតែផ្សាំជាប់នឹងក្រោធា ។
លោកចាត់ថាទុក្ខសោកនិងរីករាយ ជារឿងសម្ចាយគ្មានអ្វីខុសគ្នា
ពាក្យពិត ការគិត ការលះបង់ជា យោគៈនៅនានៃបនឹងបណ្ឌិត ។
នេះឯងហៅថាសុភមង្គល គឺការឃើញយល់ព្រះព្រហ្មពិតៗ
ឯឧបាទានមិនត្រូវប្រព្រឹត្ត បណ្ឌិតទុកជាព្រួញមុតបំផុត ។
ចៅដឹងឬទេថាមនុស្សបែបណា គួរឱ្យស្នេហានិងជាចំហុត
គឺអ្នកសាងខ្លួនឱ្យល្អបរិសុទ្ធ ដោយចេះលំអុតអង្គក្នុងសាសនា ។
មានការអប់រំផ្សំដោយកេរ្តិ៍ឈ្មោះ កបទាំងកិត្តិយសខ្ពស់ទាំងប្រាជ្ញា
មិនមែនឈាមរាវអួតអង្គអាត្មា គ្មានមហិច្ឆតាហួសសមត្ថភាព ។

បន្ទាប់ទៅនេះតាសូមប្រាប់ថា ជំងឺតណ្ហាជាធម៌ថោកទាប
ដែលនាំឱ្យឃើញបាបកម្មជាលាភ ពាលវែងប្រុងប្រៀបស្វះស្វែងចង់បាន ។
ជាវត្ថុបំណងនៃវិញ្ញាណ ដែលអាចឱ្យហ៊ានបំពានគ្មានស្រាន្ត
ដើម្បីឱ្យចិត្តកាយអាចកម្សាន្ត តាមការប្រមាណរបស់វិញ្ញាណ ។
នៅពេលគួរគាប់ជាប់ជាមួយគ្នា ឈឺមើលមិនជា គឺឧបាទាន
ស្អប់ខ្ពើមនិងលោភលន់ឥតខ្មាសអៀន ឱ្យហ៊ានបំពានលើធម៌សុចរិត ។
ពេលនោះអារម្មណ៍ត្រូវច្រឡំបល់ ក្តីតក់ក្រហល់ជាមោហ៍បាំងបិទ
មនុស្សលែងដើរតាមគន្លងក្រមក្រឹត្យ ព្រោះលែងមានចិត្តតម្កើងគុណធម៌ ។
រួចក៏ប្រមូលទ្រព្យតាមពុតត្បុត ក្បត់ក្តីបរិសុទ្ធសប្បុរសស្មោះសរ
មើលឃើញបាបកម្មជាមាគ៌ាល្អ ពាក្យពោលប្រៀនប្រដៅក៏លែងស្តាប់ ។
ជនបាបបែបនេះមិនអាចនឹងស្តារ រំដោះអាត្មាឱ្យផុតក្តីស្លាប់
ពីវដ្តសង្សារនៅក្នុងភទ្រកប្ប គឺត្រូវតែរ៉ាប់រងទុក្ខច្រើនជាតិ ។
មនុស្សល្អដែលស្នេហ៍យុត្តិធម៌ពិត រមែងរិះគិតឥតមានរវាត
ស្វែងរកក្តីល្អពីមនុស្សឯទៀត ទើបគេអាចឆ្លៀតយកកុសលបាន ។
ការឈ្នះខ្លួនឯងគឺជាគុណធម៌ មួយដ៏បវរនាំសុខក្សេមក្សាន្ត
និងឱ្យឈានដល់ការលះបង់បាន ទៅតាមលម្អានព្រោះមានវិជ្ជា ។
ភាពមានវិជ្ជាតែមួយប៉ុណ្ណោះ ដែលជម្រះអស់នូវអធម្មា
តាមការបំបាត់តណ្ហានានា ដែលលោកទុកជាកិលេសនុះឯង ។

វិជ្ជាអាចឱ្យមនុស្សមើលឃើញថា    លោកយើងនេះណាជាការសម្ដែង
ល្ខោនដ៏អឹកធឹកឥតមានពាក្យថ្លែង    លុះយូរអង្វែងក៏ត្រូវអន្តរាយ ។
ជនដែលបានឈានដល់ការលះបង់    នឹងមិនឱ្យអង្គរងក្ដីសោកស្ដាយ
កំហឹង លោភលន់ ក៏ត្រូវអន្តរាយ    សុខទុក្ខក្នុងកាយតម្លៃស្មើគ្នា ។
រាជវាំង ផ្ទះធំ ខ្ទមត្រែងឫស្សី    មាសប្រាក់ដែកដីភ្លើងខ្យល់គង្គា
ការដែលមើលឃើញតម្លៃខុសគ្នា    ព្រោះវាជាការបំភាន់វិញ្ញាណ ។
អ្នកឈានទៅដល់ការរំដោះខ្លួន    មិនអាចជួបជូននឹងឧបាទាន
រីករាយឈឺចាប់ឈ្នះចាញ់អត់ឃ្លាន    ខាតចំណេញគ្មានឃើញអ្វីខុសគ្នា ។
វត្ថុទាំងអស់សម្រាប់សត្វលោក    ដែលកើតគរគោកគ្រប់កាលវេលា
តែងនាំមកជាមួយនូវមាយា-    ការនិងប្រែជារឿងអន្តរកាល ។
ការចេះដឹងនិងស្គាល់លោកពិតៗ    នឹងនាំពិតមិនឱ្យរីកដុះដាល
ឱ្យឃើញគតិបណ្ដិតល្អគ្រកាល    បីដូចជាថ្នាលសច្ចធម៌ផង ។

-៚-

# ច្បាប់ព្រះភិក្ខុ (តនិងចប់)

## បទភុជង្គលីលា

នេះបទភុជង្គលីលា ថ្លែងពីរាជា យុធិស្ថិរហោង ។
ទ្រង់ត្រាស់សួរអយ្យកោផង តាមព្រះបំណង ព្រោះទ្រង់ចង់យល់ ។
ថាបើគេជាប់រវល់ នៅក្នុងមណ្ឌល ផ្ទះឬគ្រួសារ ។
ដោយមិនទៅព្រៃបព្វតា តើធ្វើម្ដេចម្ដា ឱ្យបានរំដោះ ។
ខ្លួនរួចដោយល្អឥតខ្ចោះ សូមទ្រង់ប្រោសប្រោះ ប្រាប់នត្តាផង ។
ព្រះអយ្យកោច្បាស់ច្បង ទ្រង់ចាប់សាសង ដោយព្រះឱង្ការ ។
ថាមិនបាច់នៅបព្វតា ឬបោះបង់ប្រា- សាទចៅនោះទេ ។
ចៅត្រូវចេះគិតគ្នាន់គ្នេរ យកទុកជាមេ- រៀនសែនចម្បង ។
ចូរចៅចាកចោលតែម្ដង ពីរាល់ចំណង ជាឧបាទាន ។
ដោយចៅតម្រង់វិញ្ញាណ ឱ្យដូចជាស្ពាន ឆ្លងទៅព្រះព្រហ្ម ។
ជាអមតភាពដ៏ធំ ទើបចៅជួបជុំ នឹងការរំដោះ ។
ការលះបង់ចោលឱ្យអស់ ជាកេរជាកោះ នៃមាតិកានេះ ។
ដោយប្រើប្រាជ្ញាត្រិះរិះ វិជ្ជាចំណេះ ជាអ្នកដឹកនាំ ។
និងជួយតម្រង់អារម្មណ៍ ឱ្យប្រឹងខិតខំ ប្រព្រឹត្តយោគ: ។
គឺមានតែតាមរយ: ការធ្វើយោគ: ទើបគេអាចឈាន ។

ឈោងឆ្ពោះដល់ព្រះនិព្វាន យោគៈជាយាន នៅគ្រប់កន្លែង ។
ទាំងនៅក្នុងផ្ទះសម្បែង ដោយសាងខ្លួនឯង ជាសញ្ញាសី ។
នេះឯងហើយណាជាន័យ មួយដ៏ប្រពៃ នៃការរំដោះ ។
ឱ្យតែចិត្តយើងត្រង់ស្មោះ យើងអាចរំដោះ ខ្លួនពីលោកិយ ។
តាសុំបន្តករណី ស្ដីពីសេចក្ដី រុងរឿងថ្កុំថ្កើង ។
ដែលទេព្តាកសាងឡើង តើលោកតម្កើង ទុកនៅទីណា ។
តាសូមជម្រាបនត្តា ថាបើមនុស្សណា ពូកែសម្ដី ។
ជាជាងសកម្មឥតបី ទាំងយកហឫទ័យ ទុកដាក់ប្រយ័ត្ន ។
ក្រោធក៏បានកម្ចាត់ តណ្ហាក៏បាត់ ទាំងមានអារម្មណ៍ ។
ហៅសែនឧត្តុង្គឧត្ដម នេះជាអាស្រម នៃភាពចម្រើន ។
ដូចព្រាហ្មណ៍ខិតខំបរៀន ឱ្យពូតពលាស់ច្រើន នូវសព្វវិជ្ជា ។
ក្នុងគម្ពីរវេទនានា ឬដូចរាជា ឧទ្ទិសព្រះអង្គ ។
ចំពោះយុត្តិធមិដ៏ត្រង់ ព្រះទ័យឥតហ្មង ឬដូចវេស្សៈ ។
ដែលឧទ្ទិសខ្លួនទាំងស្ម័គ្រ ចិត្តចងទុកដាក់ លើកសិកម្ម ។
កបចិត្តលើការដកដាំ កាប់គាស់ភ្ជាស់ផ្សាំ ឥតបីបណ្ដាក់ ។
នេះឯងជាទីសម្នាក់ ជ្រះអស់ឧបសគ្គ នៃភាពថ្កុំថ្កើង ។
ចូរចៅខិតខំប្រឹងឡើង កុំបីរើសអើង ជាមួយគុណធមិ ។
សកម្មភាពបីមិនល្អ ដែលឱ្យរីកវរ នោះត្រូវរិះគិត ។
មួយ គឺបំផ្លាញជីវិត សត្វលោកជាមិត្ត ឱ្យជួបអន្តរាយ ។

ពីរ លួចធ្វើស្នេហ៍សហាយ លួកលាន់ឡែបខាយ ជាមួយគូគេ ។
បី គឺចិត្តចោរជាមេ កេងលួចទ្រព្យគេ ឥតបីស្រណោះ ។
បីនេះបើលះបង់អស់ នោះទើបរំដោះ ខ្លួនផុតលោកា ។
ដោយរីករាយក្នុងចិន្តា ទាំងបច្ចុប្បន្នា និងបរលោកផង ។
សកម្មភាពបួនទៀតហោង ជាធម៌សៅហ្មង ចៅត្រូវវាងវៀរ ។
មួយ គឺការប្រើក្បាត្ហា អាក្រក់មហិមា ពេញដោយបាបកម្ម ។
ពីរ គឺពាក្យប្រឡេងខាម ឌឺដងដៀមដាម ដោតដៅដល់គេ ។
បី គឺកើតចិត្តវៀចវេរ ផ្សាយបោកប្រាស់គេ ឱ្យជឿលើខុស ។
បួន គឺផ្សព្វផ្សាយកំហុស បំផ្លាញកិត្តិយស របស់គេឯង ។
អកុសលបីត្រូវក្រែង កុំឱ្យចិញ្ចែង នៅក្នុងអារម្មណ៍ ។
មួយ គឺការកើតចិត្តធំ ចិត្តចោរជញ្ជ្រំ ចង់បានទ្រព្យគេ ។
ពីរ គឺចិត្តពាលជាមេ ញុះញង់ឱ្យគេ កើតចិត្តឈឺផ្សា ។
បី គឺអាប់ឱនអាត្មា ដោយបង់ខ្លឹមសារ នៃវេទវិជ្ជា ។
បើមនុស្សម្នាអាចនឹងវៀរ ចាកអធម្មា ទាំងដប់ប្រការ ។
ដូចបានរាប់ជាតម្រា នោះឯងអាត្មា គេនឹងអាចឆ្លង ។
ផុតពីលោកនេះតែម្តង ទាំងឥតមានហ្មង នៅបរលោកនាយ ។
ពេលនេះអយ្យកោនិយាយ ពីន័យទូលាយ នៃព្រហ្មចារ្យ ។
និងពីអ្វីជាខ្លឹមសារ ខ្ពង់ខ្ពស់ថ្លៃថ្លា នៃគុណធម៌ ។
ចៅអើយ! អ្វីទៅដែលល្អ ជាកុសលធម៌ ប្រសើរបំផុត ។

គឺកាន់យុត្តិធម៌បរិសុទ្ធ វៀរចាកឱ្យផុត ពីគ្រឿងស្រវឹង ។
តមកុំស៊ីសាច់ឈាមឆ្អឹង កុសលបីហ្នឹង ជាព្រហ្មចារ្យ ។
ធម្មៈ. អត្ថៈ ជាសារ កាមៈ ជាអាទិ៍ គេត្រូវប្រព្រឹត្ត ។
ក្នុងផ្នែកដើមនៃជីវិត គឺត្រូវគួរគិត ប្រមូលធនទ្រព្យ ។
យុត្តិធម៌ដ៏សែនគួរគាប់ ក៏ចាប់ផ្ដើមជាប់ ពីពេលនោះមក ។
រួចសឹមយើងទទួលយក ជាបន្ទាប់មក នូវក្ដីរីករាយ ។
ហើយតមកុំធ្វើពាយងាយ តែត្រូវរំលាយ អារម្មណ៍ឱ្យអស់ ។
ឱ្យបានល្អាតល្អំឥតខ្ចោះ កុំឱ្យជាប់សោះ នូវឧបាទាន ។
ទើបអាចថាចៅមានញាណ ដែលមិនបំពាន បំពារក្រឹត្យក្រម ។
ចូរចៅស្វែងយល់តាមដំ- ណើរដោយសក្តិសម ថាមនុស្សតែងគាប់ ។
នឹងបំណងប្រាថ្នាសព្វ និងទីបញ្ចប់ ហៅថាមោក្សៈ ។
សច្ចធម៌ក៏ដូចតិចិៈ ដែលឱ្យសត្វ- លោកមុជជម្រះ ។
មុជហើយនឹងបានស្រឡះ អារម្មណ៍ប្រែផ្លាស់ ប្រសើរក្រៃណា ។
គឺកិរិយាស្និទ្ធស្នេហា សុភាពរាបសា ក្ដីស្មោះដាមដិត ។
រួចចេះមេត្តាអាណិត អាចត្រួតត្រាចិត្ត និងឈ្នះខ្លួនឯង ។
នេះហៅឧត្តមក្ដាត់ក្ដែង បាត់ក្ដីចម្បែង អារម្មណ៍សុខសាន្ត ។
តើអ្នកណាជាត្រើយត្រាណ ជាមិត្តកល្យាណ ដ៏ស្មោះបរិសុទ្ធ ។
ជាឪពុកម្ដាយឬបុត្រ ញាតិជាចំបុត ឬគ្រូបាធ្យាយ ។
ឬអ្នកនិត្យនៅជាប់ជាយ ក្រោយពីរំលាយ វិញ្ញាណក្ខន្ធទៅ ។

ចូរគិតឱ្យឃើញរាក់ជ្រៅ ថាមនុស្សដែលនៅ និត្យក្នុងលោកិយ ។
កើតឡើងតែឯងគ្មានអ្វី ជាទ្រព្យគប្បី មកជាមួយទេ ។
ខ្លួនស្រាតនទលទំនេរ រស់ជាមួយគេ នៅក្នុងសកល ។
លុះពេលអវសានមកដល់ គ្មានអ្វីសេសសល់ នៅនិត្យនឹងខ្លួន ។
មិនអាចមានការពឹងពូន ពីមិត្តមាសស្ងួន ដូចកាលនៅរស់ ។
សូម្បីតែអ្នកខ្ពង់ខ្ពស់ ដូចម៉ែឪនុះ ឬបុត្រធីតា ។
ទាំងព្រៀងលៀនញាតកា ទាំងគ្រូអាចារ្យ នឹងបែរខ្នងដាក់ ។
ក្រោយពីចូលរួមមរណ- ទុក្ខមួយរយៈ គេក៏នាំគ្នា ។
លាទៅបន្តការងារ សពចៅនៅនា បីដូចដុំដី ។
ឬឈើមួយកំណាត់ខ្ចី ដែលលែងមានអ្វី ជាខ្លឹមសារឡើយ ។
គឺព្រះធម្មៈនេះហើយ ដែលជាត្រាណត្រើយ នឹងនៅនៃបនិត្យ ។
ព្រះធម្មៈនេះជាមិត្ត ប្រាកដពេកពិត របស់មនុស្សលោក ។
ម្នាក់ៗត្រូវតែស្វែងរក សម្បត្តិនេះមក ជារបស់ខ្លួន ។
សម្រាប់ជាទីពឹងពូន ពាក់ព័ន្ធនឹងខ្លួន នៅបរលោកនាយ ។
ដូច្នេះ សាធុ! សម្មាយ កុំបីពាយងាយ នឹងយុត្តិធម៌ ។
ត្រូវលើកស្ទួយឱ្យបវរ ស្លោកមួយដ៏ល្អ "ពាក្យសង្សពាក្យសត្យ" ។
យុត្តិធម៌ប្រសើរពេកក្កាត់ គួរឱ្យគេចាត់ ទុកជាជម្រក ។

នេះនឹងសូមសម្តែងបន្ត ក្នុងន័យយ៉ៗថ្វាយត្រាប់ត្រង
ពីព្រះកាតព្វកិច្ចចម្បង ដប់ប្រការផងនៃមហាក្សត្រិយ៍ ។
មួយ គឺ **អក្រោធ** មានន័យថា ការខឹងសម្បាត្រូវកម្ចាត់
ពីរ គឺ **អរោគ** ការឈឺថ្កាត់ ត្រូវឱ្យសះបាត់ពីព្រះកាយ ។
បី គឺ **បិតិន្ទ្រិយ** នោះមិញ ត្រូវឱ្យពេញលេញមិនបែកខ្ចាយ
បួន គឺ **ទយា** ឱ្យសប្បាយ កបកាយនឹងមេត្តាករុណា ។
ប្រាំ **សមតោ** ឱ្យរ៉ពៃ រម្យាប់រ៉ូៗជាពន្លា
ប្រាំមួយ **ប្រជាប្រិយ** គឺការ សម្បូណ៌ស្នេហាការរាប់អាន ។
ប្រាំពីរ បានដល់ **និលោភៈ** ការលោភលួចលាក់ពមឱ្យបាន
ប្រាំបី **ទាតា** ជាកល្យាណ គឺសទ្ធាទាន ក្តីសប្បុរស ។
ប្រាំបួន **អសោកមតា** គឺឥតទុក្ខាសោកសៅសោះ
ដប់ គឺ **អភយមតា** នោះ គឺចិត្តមិនលុះដោយភិតភ័យ ។
មហាក្សត្រិយ៍ត្រូវមានកិរិយាល្អ ទុកជាគុណធម៌ប្រពៃ
មានបួនប្រការជាវិន័យ ចងជាសេចក្តីដូចតទៅ ។
មួយ គឺ **ពុទ្ធិចរិតំ** មានប្រាជ្ញាខ្លាំងជ្រាបរាក់ជ្រៅ
ពីរ **សត្តុមទ្ទនេ** នៅ លើស្គាល់សត្រូវញាំញីក្បត់ ។
បី គឺ **ទិដ្ឋធម្មិក-** **សាធនំ**ជាក់ ភាពហ្មត់ចត់
សម្រេចប្រយោជន៍ឱ្យប្រាកដ ទៅតាមបែបបទទាន់បច្ចុប្បន្ន ។

បួន នៅលើ**ទិដ្ឋធម្មៈ** ត្រូវឱ្យឃើញជាក់ជាបន្ទាន់
លទ្ធផលនៃការងារពាក់ព័ន្ធ កុំឱ្យគេទ្រាន់ចាំមើលផ្លូវ ។
នេះនឹងសូមថ្លាថ្លែងបន្ត ពីព្រហ្មវិហារធម៌ដែលក្សត្រិយ៍ត្រូវ
ប្រឹងប្រែងប្រតិបត្តិទុកជាផ្លូវ ឆ្ពោះទៅនិព្វានបួនប្រការ ។
មួយ គឺ**មេត្តា** ការនាំមក មេត្រីរាប់រកដោយស្នេហា
ចង់ឱ្យគេសុខក្នុងចិន្តា ទាំងកបកាយានឹងភាពថ្កើង ។
ពីរ គឺ**ករុណា** ក្តីអាណិត អាសូរពេញចិត្តឥតរើសអើង
គ្រប់បក្សវណ្ណៈឥតបីរឆ្នើង គ្មានចិត្តឡឹតឡើងឡកឡឺយឡើយ ។
បី គឺ**មុទិតា** មានន័យ ថាក្តីរីករាយជាត្រាណត្រើយ
នៃក្តីសុខរបស់គេហើយ មិនឈ្នានីសឡើយក្នុងចិន្តា ។
បួន នៅក្រោយគេដែលត្រូវរាប់ ពាក្យគាប់គួរគឺ**ឧបេក្ខា**
ឬចិត្តស្មោះស្មើក្នុងចិន្តា ទៅលើមនុស្សានិងសព្វសត្វ ។
រាប់បាវចនាឱ្យងាយចាំ ចងជាបណ្តាំពាក្យបួនម៉ាត់
ឱ្យជាប់បញ្ចូលតាមការចាត់ ជាដើមចុងកាត់រៀង១គ្នា ។
**មេត្តា ករុណា មុទិតា** និង **ឧបេក្ខា** គាប់ទយា
ជាបាវចនាព្រហ្មវិហារ- ធម៌ព្រះរាជារបស់ខ្មែរ ។
បន្ទាប់ទៅទៀតឆ្លៀតប្រឹងប្រែង សារសព្ទសម្តែងថ្លែងប្រាប់ប្រែ
ពីការវៀរចាកកុំនៅក្បែរ និងកុំថ្ងូនថែទ្នូវអ្វីខ្លះ ។

ជារឿងអាស្រូវត្រូវលះបង់ ឱ្យផុតព្រះអង្គដោយស្រឡះ
ផុតពីពួកបរិស័ទដែលក្រាស់ ដោយភាពអាម៉ាស់ទាំងដប់ប្រាំ ។
មួយ បានដល់ភាពច្រអូសខ្ជិល ទាំងចិត្តរមិលមើលបំណាំ
ពីរ ចិត្តអាក្រក់នៅត្រែងត្រាំ រាល់ថ្ងៃខែឆ្នាំមិនរសាយ ។
បី គឺឆោត ខ្លៅ អវិជ្ជា ជាគ្រោះវេរានាំអន្តរាយ
បួន មានមារយាទអាក្រក់ក្រៃ នាំឱ្យតម្លៃសាបសូន្យសោះ ។
ប្រាំ គឺធ្វើការមិនបានគ្រាន់ ដៃភ្លើងជើងមាន់គ្រប់ចន្លោះ
ប្រាំមួយ គឺបិទបាំងជិតអស់ នូវទោសកំហុសរបស់ខ្លួន ។
ប្រាំពីរ គឺគ្មានក្តីសន្តោស ទោះទោសតិចតួចកូចគុំកួន
ប្រាំបី គឺចិត្តមិនមាំមួន មិនក្បៀវក្លាខ្លួនអាប់កិរិយា ។
ប្រាំបួន បណ្តោយឱ្យខ្លួនធ្លាក់ ចូលក្តីអប្បលក្ខណ៍ច្រើនប្រការ
ដប់ គឺការប្រើសព្វវាចា អសុរោះឡូឡាច្រឡោងខាម ។
ដប់មួយ និយាយមូលបង្កាច់ ខ្លាចគេសម្រេចប្រយោជន៍តាម
ដប់ពីរ គឺលោភៈ ជិតដាម ជាស្នាមអាស្រូវនៃកិត្តិយស ។
ដប់បី មិនស្ទាត់នឹងក្រឹត្យក្រម គម្ពីរជាធម្មសាស្ត្រខ្ពង់ខ្ពស់
ដប់បួន គឺសូន្យដោយកេរ្តិ៍ឈ្មោះ ពីព្រោះតែអាត្មានិយម ។
ដប់ប្រាំ គឺការរមិលគុណ ជាកំហុសធ្ងន់មិនសមរម្យ
ការរមិលគុណជាទោសធំ នាំឱ្យមនុស្សពុំមានជោគជ័យ ។

ខាងលើជាលក្ខណសម្បត្តិ ដែលក្សត្រិយ៍ត្រូវចាត់ថាអប្រិយ
ជនដូចខាងលើមិនគប្បី ឱ្យធ្វើមន្ត្រីរាជការឡើយ ។
មន្ត្រីធ្វើការបម្រើរាស្ត្រ ត្រូវវៀរចាកចៀសឱ្យផុតត្រើយ
កិរិយាអាក្រក់ឥតបីស្បើយ ដប់ប្រាំនេះហើយជាក្តីទុក្ខ ។
*ខ្ញុំចងក្រងច្បាប់ដោយសង្ខេប ទុកជាបទបែបតទៅមុខ
សូមសិក្សាដោយពេញបន្ទុក ចងជាទំនុកតាមកំណត់ ។
សូមបញ្ចប់ការអធិប្បាយ បំភ្លឺបរិយាយតាមបែបបទ
នៃន័យដូចមានមកប្រាកដ សន្មតថាចប់សព្វសេចក្តី ។

# យុគ

បទកាកគតិ

ខេមរភាសា តែងទម្លាប់ថា ជា "យុគសម័យ"
គឺសម័យកាល យូរអង្វែងក្រៃ ដែលគ្រប់គ្រងផ្ទៃ
នៃផែនពសុធា ។
ជាកាលច្រើនកប្ប មានល្អចំណាប់ សម្រាប់មនុស្សា
មានល្អគួរសម អាក្រក់មិនជា យុគមួយៗវា
ស្ថិតជាប្រចាំ ។
កាលនៃយុគៈ ឬមន្វន្តរៈ ងាយស្រួលចំណាំ
គឺបួនលានបី- សែនពីរម៉ឺនឆ្នាំ[1] មនុស្ស ត្រូវចងចាំ
និងយល់សេចក្តី ។
បុរាណចារទុក ថាន័យនៃយុគ សន្មតដោយខ្លី
គឺអាយុកាល នៃភពផែនដី កើតជាប្រក្រតី
ដោយផ្លាស់វេនគ្នា ។
អាយុសែនយូរ ខ្ទង់លេខគត់គូ ខ្ទង់សេសល្អជា
យុគតែងស្តែងឡើង ថ្កើងឬវេទនា អាស្រ័យឫកពា
នៃព្រះមហាក្សត្រិយ៍ ។

---

១. រយៈកាល ៤.៣២០.០០០ ឆ្នាំមនុស្ស ឬហៅថា មួយមន្វន្តរៈ ។

នេះបានន័យថា យុគទាំងនោះណា មិនមែនបង្កាត់
បង្កបង្កើត លក្ខណសម្បត្តិ នៃព្រះមហាក្សត្រិយ៍
ឬអ្នកដឹកនាំ ។

យុគសម័យនេះ អ្នកប្រាជ្ញត្រិះរិះ ចាត់ជាក្រឹត្យក្រម
ចែកជាបួនយ៉ាង រាប់រៀងបឋម យុគដើមឧត្តម
ហៅ **ក្រឹតយុគ** ។

ឬតាមពាក្យមួយ ទៀតនោះជាត្រួយ ត្រូវត្រងត្រាប់ទុក
លោកឱ្យឈ្មោះថា ជា **សត្យយុគ** ដូចអ្នកនាំមុខ
ជាយុគឱភាស ។

រីក្រឹតយុគ បុរាណចាត់ទុក ថាជាយុគមាស
យុគសម័យនេះ បានជាឱភាស ព្រោះពោរពេញពាស
ដោយនូវពាក្យសត្យ ។

លេខយុគសេសគូ កប្បកល្បសែនយូរ ហើយប្រសើរក្លាត់
មួយលានប្រាំពីរ- សែនពីរម៉ឺនកាត់ រួចត្រូវចែងចាត់
ថែមប្រាំបីពាន់[១] ។

ឆ្នាំនៃមនុស្សម្នា បើគន់គិតជា ឆ្នាំទិព្វគុំភ័ន្ត
នោះឃើញថាមាន ចំនួនបួនពាន់- ប្រាំបីរយគ្រាន់
គ្រប់ទៅតាមន័យ ។

---

១. គឺ ១.៧២៨.០០០ ឆ្នាំមនុស្ស ឬស្មើនឹង ៤.៨០០ ឆ្នាំទិព្វ ។

ជាយុគមានជោគ នាំមនុស្សក្នុងលោក ចៀសផុតទុក្ខភ័យ
ព្រោះយុត្តិធម៌ គ្រប់គ្រងសព្វផ្ទៃ នៃភពផែនដី
ឥតបីមានហ្មង ។

យុគនេះបវរ ព្រោះអយុត្តិធម៌ សូន្យសោះតែម្តង
អកុសលធម៌ មិនដែលមានឆ្លង លោកទាំងមូលផង
ពេញសន្តិភាព ។

ចិត្តមនុស្សស្មោះសរ សុចរិតសច្ចធម៌ ល្អះល្អឥតប្រៀប
មិនលួចលាក់លៀម ធ្វើតាមរបៀប យកតម្លាភាព
ទុកជាគោលការណ៍ ។

មនុស្សតែងប្រតិបត្តិ តាមដោយមធ្យ័ត នូវពាក្យសន្យា
មិនឱ្យឱនអាប់ សារសព្វវាចា សត្វគ្រប់អាត្មា
សែនសុខសប្បាយ ។

ដីមានជីជាតិ ឈើផ្លែទាំងឃ្លាត ចាកផុតអន្តរាយ
ដុះមិនបាច់ដាំ ដោយកម្លាំងកាយ ភោគផលទាំងឡាយ
កើតឡើងឯងៗ ។

លោកកំណត់ថា មកពីទេព្តា ទ្រង់ចង់សម្តែង
ថាទ្រង់រីករាយ ព្រះទ័យក្រៃលែង អាយុយូរវែង
ជាពរលោកជូន ។

ផលានុផល កើតកើនច្រើនដល់ ដូចគេគរពូន
ជំងឺតម្កាត់ បង់បាត់ស្វាត់សូន្យ ដូចគេសណ្ដូន
សណ្ដោងទៅអស់ ។
រីឯរដូវ ចូលឬចេញទៅ ត្រឹមត្រូវឥតខ្ចោះ
ផ្គរពពកភ្លៀង ទាត់ទៀងស្មើស្មោះ សន្និភាពប៉ុណ្ណោះ
គ្រប់គ្រងផែនដី ។
កាលបើមហាក្សត្រិយ៍ សោយរាជសម្បត្តិ មិនសូវប្រពៃ
ដោយឱ្យទណ្ឌនី- តិមួយភាគបី ចូលក្នុងហឫទ័យ
ផែនដីនឹងប្រែ ។
នាំឱ្យក្រឹតយុគ រងការវាយលុក ទៅមុខឥតបែរ
យុគប្រាក់ចូលមក មិនអាចឱ្យកែ ជាយុគល្អដែរ
ហៅ **ត្រេតយុគ** ។
នេះបានន័យថា នៅយុគនោះណា ក៏មិនមានទុក្ខ
អធម្មៈមួយ- ភាគបីចូលលុក កើតជាបន្ទុក
បន្តិចជាការណ៍ ។
ផែនដីនៅផ្ដល់ ផលានុផល ប្រសើរធម្មតា
តែត្រូវកាប់គាស់ ភ្ជួររាស់ស្រែចម្បារ រានដីចម្ការ
សព្វសិនសីមដាំ ។

ត្រូវថែរក្សា ធញ្ញជាតិរុក្ខា ទាំងត្រូវផ្សំផ្សា
ដាក់ជីស្រោចទឹក រួចត្រូវរង់ចាំ ព្រោះផលដំណាំ
លែងផ្ដល់ភ្លាមៗ ។

អាយុជីវិត ក៏យូរយារពិត ចិត្តឥតក្រំក្រៀម
ជំងឺតម្កាត់ ក៏ស្ងាត់ឈ្មោះនាម ទុក្ខមិនទាក់ទាម
សុខជាប្រចាំ ។

វីរអាយុយុគ តាមការចារទុក ងាយស្រួលចំណាំ
មួយលានពីរសែន- ប្រាំបួនម៉ឺនប្រាំ- មួយពាន់[១] នៃឆ្នាំ
មនុស្សលោកយើងហោង ។

គឺបីពាន់ប្រាំ- មួយរយជាឆ្នាំ ទិព្វដោយច្បាស់ច្បង
ខ្ទង់លេខសេសគូ កាលយូរយារផង នេះយុគទាំងសង
ល្អដាច់លើសគេ ។

កាលបើមហាក្សត្រិយ៍ មិនបានប្រតិបត្តិ ឱ្យប្រសើរទេ
ដោយបណ្ដោយឱ្យ អយុត្តិធម៌ជាមេ- រោគចូលមកទ្វេ
ដល់ពាក់កណ្ដាល ។

នោះ **ទ្វាបរយុគ** នឹងមកនាំមុខ ចូលលុករាលដាល
ក្ដីសុខថយចុះ ទុក្ខទោសមកក្រាល ជូនធ្ងន់ជូនស្រាល
គ្រប់កាលជំនាន់ ។

---

១. គឺ១.២៩៦.០០០ ឆ្នាំមនុស្ស ឬស្មើនឹង ៣.៦០០ ឆ្នាំទិព្វ. ហៅថាយុគប្រាក់ ។

លេខយុគពេញជូ សូមជនវិញ្ញូ កុំច្រឡំភ័ន្ត
ប្រាំបីសែនប្រាំ- មួយម៉ឺនបួនពាន់[1] ចូរស្ដាប់ឱ្យទាន់
ខ្ទង់ពាន់ចុងក្រោយ ។

បើនឹងគណនា ឆ្នាំទិព្វត្រូវជា ពីរពាន់បួនរយ
ឱ្យអាយុខ្លី ក្ដីសុខថ្លោះធ្លោយ ដោយបណ្ដោយឱ្យ
ទុក្ខជ្រែកលោកា ។

ដីទោះភ្លូវរាស់ ឬរានកាប់គាស់ ល្អអស់ក្ដីណា
ដាក់ជីស្រោចទឹក ល្វាចព្រឹករក្សា ឯផលផ្លែផ្កា
បានត្រឹមមធ្យម ។

ក្នុងទ្វាបរយុគ ក្ដីសុខនិងទុក្ខ មូលមកជិតជុំ
ឱ្យមនុស្សសត្វផង ឆ្លងជ្រោះតូចធំ គឺគ្រោះសង្គម
ខ្វះភាពទាត់ទៀង ។

ជំងឺតម្កាត់ មកទំមនុស្សសត្វ ពិចតូចរៀងៗ
រូចរីករោលរាល ដាលរាលមែកធាង ពេទ្យហ្មត្រូវព្រាង
ស្មើរគ្មានទំនេរ ។

---

១. គឺ ៨៦៤.០០០ ឆ្នាំមនុស្ស ឬស្មើនឹង ២.៤០០ ឆ្នាំទិព្វ ហៅថាយុគសរិទ្ធ ។

# កលិយុគ[១]

បទពាក្យ៧

យុគទីបួនហៅថាកលិយុគ ជាយុគនាំទុក្ខអាក្រក់ទ្វេ
តែអាយុកាលខ្លីជាងគេ សូមរួមរិះរេស្ដាប់បន្ត ។
ពេលណាដែលព្រះមហាក្សត្រិយ៍ មិនព្រមប្រតិបត្តិឱ្យបានល្អ
ដោយបណ្ដោយអកុសលធម៌ ឱ្យចូលនគរជ្រែកពេញដី ។
និត្យនៅជាប់លាប់ក្នុងអារម្មណ៍ កើតចិត្តអធម្មលើលោកិយ
ស្ដេច រាស្ត្រ សព្វសេនាបតី ក្នុងកម្រិតបីភាគបួនផង ។
កលិយុគនឹងចរចូលមកដល់ ឱ្យកើតកង្វល់ជាចម្បង
បង្កទុក្ខទោសច្រើនកន្លង ពេញដោយសៅហ្មងគ្រប់ជំនាន់ ។
រយៈកាលនៃកលិយុគ បុរាណចារទុកតាមថ្នាក់ជាន់
គឺបួនសែនបីម៉ឺនពីរពាន់ ឆ្នាំមនុស្សគ្រប់គ្រាន់តាមកម្រិត ។
ស្មើនឹងមួយពាន់ពីររយឆ្នាំ ទិព្វតាមបណ្ដាំជាកំហិត
ហេតុល្អក់អាក្រក់មកផ្ដេកផ្ដិត និត្យនៅក្នុងចិត្តច្រើនជាងល្អ ។
កលិយុគមានដើមកំណើតមក ពីទីជម្រក **អយុត្តិធម៌**
ស្វែងតាមការបោកប្រាស់ភូតភរ គ្មានសច្ចធម៌ជាជំនួយ ។
កើតចិត្តជាចោរប្រឹងលាក់លួច ច្រើនឬតិចតួច ទាំងមានសួយ-
សារជាសំណូកពុករលួយ មានអំណាចជួយជាតួយ៉ាង ។

---

១. ឬបុរាណហៅម្យ៉ាងទៀតថា "យុគដែក" ។

តុលាការអយុត្តិធម៌ តែងឈរលើលុយជាសំអាង
ស៊ីរះសំណូកទាំងសងខាង អ្នកណាខ្សោយជាងជាក់ជាចាញ់ ។
សព្វមុខមន្ត្រីអវិជ្ជា យកល្បិចពាលាមកចម្រាញ់
មើលឃើញតែខ្លួន "អាត្មាអញ" កិបកេងប្រវញ្ចព្រោះលោភលន់ ។
ដណ្ដើមកម្មសិទ្ធិមិនចេះចប់ ចិត្តមិនដែលស្កប់ទាំងគេចពន្ធ
ពុំពិចារណាពីទោសគុណ រាស្ត្ររងទម្ងន់ការសង្កត់ ។
ពាក្យតែមួយម៉ាត់បាត់ន័យល្អ គឺ **អយុត្តិធម៌** តាមសន្ទត
កំណើតមានមកយកធម៌ក្បត់ គុំគាបសង្កត់ឱ្យរាស្ត្រខ្លាច ។
កាមមុច្ឆានិងអភិជ្ឈា ដើរទៅព្រមគ្នានឹងអំណាច
ផ្សំនឹងការពោលពាក្យកោងកាច សម្លុតបន្ទាចលាយបន្លំ ។
បន្លាយបញ្ហាណាអភ័ព្វ ល្បែងភ្នាល់ដិតជាប់ជាបឋម
ស្រីស្រាអាភៀនញៀនថ្នាំផ្សំ ខ្វះខាតខិតខំរកបន្ទាន់ ។
ទេព្តាមិនសប្បាយព្រះទ័យ មិនផ្តល់ពរជ័យជូនគ្រប់គ្រាន់
ឱ្យមេឃអាកាសផ្លាស់ប្រែភ័ន្ត រដូវហោមន្តលែងទាត់ទៀង ។
កើតគ្រោះធម្មជាតិគ្រប់តំបន់ ភ្លើងឱ្យអាសន្ន ទាំងរាំងភ្លៀង
ភ្លៀងខុសចំណាំទម្លាប់រៀង ទីខ្លះមានភ្លៀងខ្លះក្រៀមក្រោះ ។
ជន់លិចស្រែក្រុងលង់ដំណាំ សន្ទូងដោតដាំរលួយអស់
ភោគផលកើតឡើងពីអម្រស់ មិនគ្រប់គ្រាន់សោះរៀងរាល់ឆ្នាំ ។
រាស្ត្រខ្លះខ្វះស្រែខ្វះបាយទឹក រងគ្រោះទុរ្ភិក្សជាប្រចាំ
បញ្ហាវេទនានៅត្រែងត្រាំ នេះជាផលកម្មអយុត្តិធម៌ ។

ជំងឺមនុស្សសត្វសែនប្លែកៗ | បែងចែកពាសពេញដែននគរ
ហួសសមត្ថភាពពួកពេទ្យហ្ម | បញ្ហារីករាលសព្វទីឋាន ។
លួចប្លន់ចាក់កាប់ជាពួយ៉ាង | ពួកផ្ដើងឡើងចាងសែនហាវហាន
គ្នាខុសតិចតួចអត់មិនបាន | ហិង្សាជាត្រាណត្រើយពួកពាល ។
កើតចិត្តប្រចណ្ឌប្រពន្ធប្ដី | ជម្លោះអប្រិយ គ្ដី ជេរ ជៀល
បាញ់លែងចាក់កាប់ស្លាប់រង្គាល | ទូលពិតឆ្កឹះឆ្កៀលផ្ដាប់យកចិត្ត ។
ខ្លៅនិងអវិជ្ជាជាគ្រូធំ | ប្រជុំទៅរកកាយទុច្ចរិត
ដែលជាបាបធម៌ដ៏ឧក្រិដ្ឋ | ជីវិតសែនសង្រេងសង្រៃ ។
លោកយើងក្លាយជាទីពំនាក់ | នៃជម្រកអនាធិបតេយ្យ
មិនអាចទប់ទល់ឬកែខៃ | ស្ទើរមិនស្គាល់ថ្ងៃណាសប្បាយ ។
ឃើញតែក្ដីទុក្ខក្ដីកង្វល់ | រំបល់អកុសលគ្រោះអន្តរាយ
ដូចលោកិយកាច់ឥតបីណាយ | ឱ្យខ្វល់ដល់កាយចិត្តស្មារតី ។
ប្រជែងអាវុធយុទ្ធភណ្ឌ | សម្លាប់លួចប្លន់គ្មានប្រណី
អសន្តិសុខកើតពេញផែនដី | ស្ទើរគ្មានន័យអ្វីដល់ជីវិត ។
ចូរចៅ[១] ចាំទុកជាពាក្យស្លោក | នូវឃ្លាប្រយោគន័យល្អពិត
ដែលប្រាជ្ញចងទុកពីព្រេងព្រឹទ្ធ | ឱ្យជាប់នៅនិត្យជាសម្បត្តិ ។
ថា "កូនឆ្កួងដ្បិតម្ដាយឪពុក | ស្រុកកើតកលិយុគដ្បិតមហាក្សត្រ"
ន័យត្រង់មួយនេះចៅ[១] អាចកាត់ | យល់ជាបញ្ញត្តិបានដោយងាយ ។

---

១.ព្រះភីស្មៈត្រាស់ទៅយុធិស្ឋិរ ជាព្រះនត្តា (រឿងមហាភារតៈ) ។

ចៅអើយ! យុត្តិធម៌ត្រូវប្រតិបត្តិ ទាំងប្រុងប្រយ័ត្នពេលនិយាយ
និយមពាក្យសត្យកុំពាយងាយ កិច្ចការសម្ងាយរាយឱ្យពិត ។
អធិប្បាយកលិយុគត្រឹមប៉ុណ្ណេះ ប្រាជ្ញណាដែលចេះគួរគួរគិត
ជួយចងជាមេរៀនជីវិត យោងតាមគំនិតធម៌សច្ចៈ ។
ខ្ញុំតែងផ្សែផ្សំដោយលម្អិត ផ្អែកតាមក្រមក្រឹត្យព្រះភិក្ខុ
ដូចមានចារចែងតែងទុកដាក់ ក្នុងមហាភារតៈជំពូកមួយ ។
ស្តីពីក្រមសីលធម៌មហាក្សត្រិយ៍ ដែលត្រូវប្រតិបត្តិជាប់ជាត្រួយ
ជាទ្រឹស្តីទ្រព្យសម្រាប់ជួយ ឱ្យអស់ទុក្ខព្រួយពីពសុធា ។
សព្វថ្ងៃកលិយុគគ្រប់គ្រងលោក ទើបក្តីទុក្ខសោកមកនាំពៀរ
ព្រោះមានការក្បត់ប្រយោជន៍គ្នា រាស្ត្ររងវេទនារៀងរាល់ថ្ងៃ ។
មាននគរខ្លះសែនថ្កុំថ្កើង លូតលាស់លេចឡើងប្រសើរក្រៃ
គេលើកសច្ចធម៌ឱ្យថ្លាថ្លៃ យុត្តិធម៌មានន័យចម្រើនសុខ ។
សូមឧទ្ទិសកាព្យជូនកូនចៅ បងប្អូនញាតិផៅគ្រប់ភូមិស្រុក
ទុកជាសម្បត្តិដ៏ស្តុកស្តុក សូមជួបក្តីសុខគ្រប់ប្រការ ។
ក្នុងពុទ្ធសករាជរាប់មិនភ័ន្ត នៅឆ្នាំពីរពាន់ប្រាំរយហា-
សិប ថ្ងៃដប់ប្រាំពីរកញ្ញា គ្រិស្តសាសនាពីរពាន់ប្រាំមួយ ។
ខ្ញុំចងក្រងទុកគ្រាន់នឹងអាន ជាការកម្សាន្តនិងលើកស្ទួយ
ឡើងជាចំណេះទូទៅមួយ ជូនជាជំនួយប៉ុណ្ណេះហោង ។
សូមស្រង់គ្រងគ្រាប់យកគំនិត សែនល្អពេកពិតជាចំណង-
ដៃ ព្រោះជាវិជ្ជាចម្បង ដែលមនុស្សម្នាផងគួរផ្តេកផ្តិត ។

# អម្រឹត

បទពាក្យ៧

យោងតាមទម្លាប់នៃភាសា ខ្មែរយើងតែងថា "ទឹកអម្រឹត"
អម្រឹតជាភេសជ្ជៈពិសិដ្ឋ ព្រោះត្បិតជាសុរាទេព្តា ។
ជាទឹកដមទ្រទ្រង់ជីវិត ឱ្យនៅនឹងនិត្យជាអមតា
តាមន័យនៃពាក្យផ្សេងគេថា ជាបិយោសាឬនិជ្ជរា ។
ទឹកអម្រឹតចេញមកពីណា នេះនឹងសូមចារចែងពណ៌នា
ចូរយើងនឹកទៅពាក្យមួយឃ្លា ថា "ការកូរសមុទ្រទឹកដោះ" ។
ដែលប្រារព្ធដោយពួកទេព្តា និងអសុរាយក្សហៀវហោះ
បុរាណនិទានគ្មានចន្លោះ សូមជ្រាបឱ្យអស់សព្វករណី ។
ថាក្នុងកល្បមួយកំបាំងបាត់ យ៉ាងយូរយាំងក្តាត់ហួសនឹងស្តី
មានចម្បាំងមួយខ្លាំងឥតបី លើសួគ៌ាល័យលោកនេះណា ។
នោះឯងជាចម្បាំងរាំងជល រវាងអសុរនិងទេព្តា
អសុរមានឫទ្ធិសែនអស្ចារ្យ វាយពួកទេព្តាឱ្យទន់ដៃ ។
ទេព្តាឃើញថាអស់រំពឹង ក៏ត្រឡប់រឹងទៅទាំងថ្ងៃ
គាល់ព្រះវិស្ណុឧត្តមក្រៃ ប្រាស្រ័យសុំពរល្អប្រសើរ ។
គឺឱ្យបានជីវិតអមតៈ ចាកផុតគ្រោះថ្នាក់តាមដំណើរ
ឱ្យមានកម្លាំងឥតប្រៀបស្មើ ដើម្បីបម្រើយកជោគជ័យ ។

ទេពាធិបតីទ្រង់ត្រាស់ថា ឱ្យពួកទេព្តាប្រឹងលកលៃ
ស្រុះស្រួលបបួលគ្នារំពៃ រវៀសរវៃនឹងសត្រូវ ។
កូរឱ្យលេចឡើងទឹកអម្រឹត ជាទឹកពិសិដ្ឋប្រសើរនួវ
វត្ថុថ្លៃថ្លាដែលបាត់ទៅ នោះត្រូវយកមកវិញឱ្យបាន ។
ដូច្នេះ ឱ! អស់ពួកទេវៈ យើងសុំបញ្ជាក់ជាដើមដាន
សូមអ្នករាល់គ្នាកុំខកខាន ធ្វើតាមលម្អានយើងបញ្ជា ។
សូមចូលរួមក្នុងសន្តិភាព រាក់ទាក់រាបទាបកុំរួញរា
ជាមួយសត្រូវនៃទេវា រួចត្រូវនាំគ្នាទៅស្វះស្វែង ។
បោចគាស់អស់ធញ្ញជាតិឱសថ នៅតាមជនបទសព្វកន្លែង
ព្រៃភ្នំជិតឆ្ងាយដាច់សង្វែង រួចរើកលីសែងត្រកងយក ។
ទៅបោះចូលសមុទ្រទឹកដោះ ហើយគាស់ខ្នែងភ្នំមន្ទរមក
ធ្វើចង្កឹះកូរទឹករលក វិលវង់ទៅមកកុំរឹករវ ។
យកវាសុកីជាស្តេចនាគ មករុំព័ទ្ធក្រៀកភ្នំមន្ទរ
ដូចពួរព័ទ្ធសសរបញ្ឈរ រួចកូរសាគរដោយរវាំង ។
ឱ្យកើតចេញជាភេសជ្ជៈ គឺទឹកអមតៈផ្តល់ពលំ
ជាប្រភពទ្រទ្រង់ជីវំ អាចលើកកម្លាំងឱ្យអស្ចារ្យ ។
យើងនឹងប្រឹងប្រែងជួយប្រាស្រ័យ ដុតជើងដុតដៃយកអាសា
យើងក្លែងខ្លួនជាជាតិមច្ឆា ដោយយករូបាជាអណ្តើក ។

រួចយើងក្រាបទប់ជាទម្រ នៅបាតសាគរមិនកម្រើក
ឱ្យមន្ទរវិលវង់កក្រើក រំពើកទៅបាននឹងហើយស្រាល ។
ទេព្តាតោងខាងកន្ទុយនាគ អសុរតោងភាគទៅខាងក្បាល
ត្រូវនាំគ្នាកូរត្រង់កណ្តាល សាគរនោះកាលណាត្រៀមហើយ ។
យើងរ៉ាប់រងឱ្យបច្ចាមិត្ត ប្រឹងជួយរួមរឹតមិនកន្តើយ
តែមិនឱ្យបានចំណែកឡើយ លើផលជាត្រើយនៃកិច្ចការ ។
មិនឱ្យសេពសោយភេសជ្ជៈ សុរាអមតៈនោះទេណា
ឥឡូវទៅចុះអស់ទេព្តា ធ្វើតាមវាចាយើងជម្រាប ។
ពួកពញ្ញាម្ចាស់ខ្លួនដូច្នោះ ទេវាក្រាបចុះ អង្គបន្ទាប
រួចទើបចាកចេញចរទៅត្រៀប សុំចងមិត្តភាពនឹងសត្រូវ ។
ប្រឹងប្រតិបត្តិតាមការណែនាំ ដ៏ល្អទន្ទាំមួយនោះទៅ
ព្រោះជាគំនិតអាចនាំផ្លូវ ត្រឹមត្រូវទៅរកឫទ្ធិបារមី ។
យក្សនិងទេព្តាចាប់ទាញនាគ រង្កៀកទៅមកដោយគប្បី
មិនគិតថាយូរឆាប់ឡើយនៃ ដ្បិតអីជាសេចក្តីត្រូវការ ។
មេគោទិព្វលេចឡើងមុនគេ ជាមេគោដែលពួកទេព្តា
ទុកជាទីគោរពសក្ការ និងទេពធីតាមួយអង្គដែរ ។
ទ្រង់ព្រះនាមថាសុរភី[១] ល្អឥតមានពីរជាព្រះម៉ែ
តែងផ្តល់ទឹកដោះជាប់ឥតល្ហែ ឱ្យថែថ្ងូនមនុស្សលើផែនដី ។

១. មានឈ្មោះផ្សេងទៀតថា កាមាធេនុ និង សពាល ។

លេចឡើងបន្ទាប់គឺអស្សតរ រាងសមរោមសដូចសំឡី
ស្រែកកញ្ជ្រៀវខ្ទរខ្ទ័រទឹកដី ចែងចាំងរស្មីនឹងសុរិយា ។
សេះសនោះឈ្មោះឧច្ចៃស្រព សឹងសមប្រកបគ្រប់លក្ខណា
ពាហនៈមួយទៀតល្អអស្ចារ្យ គឺមហាគជសារសូត្រិតលោក ។
ឈ្មោះប្រាកដថាឰរាវ័ណ ដូចដួងព្រះចន្ទដ៏មានជោគ
នៃថ្ងៃពេញបូណ៌មីរះមក ហោះកាត់ពពកទន្ទឹមគ្នា ។
ពាហនៈទិព្វទាំងពីរប្រាណ ត្រូវបានជាយានព្រះឥន្ទ្រា
ទ្រង់ប្រើប្រាស់ផ្ទាល់រាល់វេលា ទាំងជាកេតនភណ្ឌព្រះអង្គ ។
រួមទាំងវត្ថុទិព្វបីទៀត កៅទណ្ឌសរសៀតក្នុងបំពង់
ខ្សែងស័ង្ខលាន់ឮក្នុងរឿណរង្គ លន្លោចលន្លង់ខ្ទ័រទៅក្រៅ ។
បន្ទាប់មកគឺព្រះសិទ្ធស ល្អសមឥតមោះមៃហ្មងសៅ
ទាក់ទាញភ្នែកមនុស្សឱ្យចៅរ៉ៅ គន់មើលសំដៅស្មើរនឹងភ្លឹក ។
ជាទេព្តាមានបុណ្យបារមី អាចចរលើដីលើផ្ទៃទឹក
ហោះលើអាកាសសូរសន្ធឹក គគ្រេងគគ្រឹកលឿនមហិមា ។
មានចំនួនប្រាំបីម៉ឺនប្រាំ- បីពាន់អង្គតាមការគណនា
ទ្រង់ហោះលើអាកាសវេហាស៍ ពាសពេញមេឃាគួរផ្អើលភ្ញាក់ ។
បន្ទាប់មកព្រះវារុណី សុរាទេវីស្រស់វង់ភក្ត្រ
ជាទេពធីតាស្រាភេសជ្ជៈ លេចឡើងប្រត្យក្សបង្ហាញតួ ។

# សព្ទានុក្រម (Lexicon)

**កប្ប,កល្ប**.- កាលដែលតាំងនៅយ៉ាងយូរ age, epoch, era ។

**កម្ម**.- អំពើដែលជនម្នាក់ធ្វើនិងផលនៃអំពើនោះដែលត្រូវធ្លាក់មកលើអ្នកធ្វើនោះវិញ ដោយមិនអាចចៀសផុតបាន deed, action, karma ។

**កម្មវត្ថុនៃវិញ្ញាណ**.- វត្ថុទាំងឡាយដែលទាក់ទាញ ឬ ដែលជាទីប៉ងប្រាថ្នារបស់វិញ្ញាណ objects of the senses ។

**ករុណា**.- សេចក្ដីអាណិតអាសូរ pity, mercy, compassion ។

**កាម**.- សេចក្ដីប្រាថ្នា, ចំណង់ passion, desire ។

**កាមមុច្ឆា**.- ការត្រាំអារម្មណ៍នៅក្នុងកាមគុណ lust ។

**កំណាញ់**.- ការកាញ់គ្នេរ, ការហួងហែង avarice, greed ។

**កំហឹង**.- ការខឹងសម្បា anger ។

**ក្រអឺតក្រទម**.- ដែលសម្ញែងឫកពា, ដែលមានអាកប្បកិរិយាមិនសមគួរ, ដែលបង្ហាញកិរិយាឃឹតយ៉ារ, ព្រហើន arrogant, rude ។

**ក្សត្រិយ៍**(ខត្តិយ).- ម្ចាស់ទឹកដី, ស្ដេច khshatriya, monarch, king ។

**ខន្តី**.- សេចក្ដីអត់ធន់, ការកាន់ចិត្តអត់ឱន patience, tolerance ។

**ខឹង**.- ដែលមានអារម្មណ៍មិនគាប់ចិត្ត, កម្រើកចិត្តដោយទោមនស្ស angry ។

**ខ្លៅ**.- ល្ងង់ព្រោះប្រាជ្ញាតិចពេក, ល្ងីល្ងើ ignorant, imbecile ។

**គតិបណ្ឌិត**.- ដំណើរគំនិតឬកិរិយារបស់អ្នកប្រាជ្ញ, ការចេះដឹង wisdom ។

**គុរុ**.- គ្រូ, ឧបជ្ឈា, រាជបណ្ឌិត (ក្លាយជា គរុ, គ្រូ) guru, teacher, scholar ។

**ចក្ខុន្ទ្រិយ**.- អារម្មណ៍របស់ភ្នែកដែលអាចប្រមើលឃើញ mind-eye ។

**ចងគំនុំ**.- ចិញ្ចឹមចិត្តចាំសងសឹក to wreak one's vengeance on ។

**ចំណង**.- ការជាប់ចិត្តជាប់អារម្មណ៍តាមមនោសញ្ចេតនា (ដូចជាគ្រួសារ, បងប្អូន, ញាតិសន្ដាន, ការងារ, ទ្រព្យសម្បត្តិ ជាដើម) bondage ។

**ច្រណែន, ឈ្នានីស**.- ដែលមិនចង់ឱ្យគេបានស្មើឬលើសខ្លួន jealous ។
**ច្រឡោត**.- ដែលខឹងយ៉ាងខ្លាំង, ក្តៅចិត្ត furious, irritated ។.
**ច្រឡោងខាង**.- ដែលព្រហើនតាមឥរិយាបថនិងសម្តី, ដែលវាយឬកពា សម្ដែងបែបព្រៃផ្សៃ arrogant, aggressive, harsh ។
**ជិវ្ហិន្ទ្រិយ**.- អារម្មណ៍ដែលឱ្យទឹកចង់ផ្ដាប់ជិវ្ហាវិញ្ញាណ sense of taste ។
**ជ្រាប**.- រីកសុសសាយសព្វទីកន្លែង to permeate, omnipresent ។
**ញាណ**.- សេចក្ដីដឹង, ប្រាជ្ញា knowledge, intelligence, self, ego ។
**តណ្ហា**.- ចំណង់, សេចក្ដីប្រាថ្នា, ការត្រេកត្រអាល passion, desire ។
**តុស្នី**[១] .- ដែលសម្ងំស្ងៀម, មិនបង្ហាញប្រតិកម្មលម្បៀង silent, quiet ។
**តូចចិត្ត**.- ទើសទាស់ចិត្ត, ដែលមិនឱ្យពេញចិត្ត shocked, depressed ។
**ត្រួតត្រាអាត្មន**.- ត្រួតត្រាខ្លួនឯងពោលគឺជម្នះឥន្ទ្រិយឬវិញ្ញាណទាំងប្រាំ ឱ្យបាន self-control, self-restraint ។
**ទណ្ឌៈ**.- ការធ្វើទោសទណ្ឌតាមច្បាប់ punishment, chastisement ។.
**ទណ្ឌនីតិ**.- ច្បាប់ដែលចែងពីបទធ្វើទោសទណ្ឌិត penal code ។
**ទឡ្ហីករណ៍**.- អ្វីៗជាសំអាង ឬជាភស្តុតាង argument ។
**ទុក្ខសោក**.- ការកើតអារម្មណ៍សង្រេងសង្រែ grief, sorrow ។
**ទេវភាព**.- ភាព ឬ ភាវៈ ជាទេវតា deity ។
**ទ្រឹស្តិស្នូរ**.- ដែលកំណាញ់ស្វិត, កំណាញ់ក្រៅតម្រា avarice ។
**ធម្មៈ**.- សភាវៈទ្រទ្រង់សត្វលោក ដូចជា បុណ្យ, បាប, សុចរិត, ទុច្ចរិត, ច្បាប់, គុណ, ធម្មជាតិ ។ល។ dharma, law ។.
**ធុតង្គ**.- អង្គរបស់ធមិដែលកម្ចាត់អស់នូវគ្រឿងកិលេស, អ្នកដែលបានកម្ចាត់ អស់នូវគ្រឿងកិលេស ascetic, sage ។
**នីតិកម្ម**.- ការតែងច្បាប់, សិទ្ធិខាងតែងច្បាប់ legislation, legislature ។

---

១- ពាក្យនេះមិនឃើញមានក្នុងវចនានុក្រមទេ ខ្ញុំឃើញនៅក្នុងសៀវភៅ ក្បួនរាជសព្ទ របស់ លោកឧកញ៉ាមហាមន្ត្រី ញ៉ុក ទូ . មានន័យព្រលាំគ្នានឹង ខន្តី (កុំច្រឡំនឹង តុស្តិ៍) ។

**ពិរោធ**( ភាជសព្ទ ).- កំហឹងខ្លាំង, ការខឹងច្រឡោត fury ។

**ព្យាបាទ**.- ដំណើរចងចិត្តធ្វើឱ្យអ្នកដទៃវិនាស malice, malevolence ។

**ព្រលឹង**.- ដំណើរជីវិត, ស្រីសួស្តី, ធាតុអមតៈរបស់ជីវិត soul ។

**ភន្តវិញ្ញាណ**.- ការយល់ច្រឡំដោយសារការផ្តាច់វិញ្ញាណ delusion ។

**មច្ឆរិយៈ**.- សេចក្តីកំណាញ់ស្វិត avarice ។

**មហិច្ឆតា**.- សេចក្តីប្រាថ្នាធំ, ការចង់បានច្រើន, អំនួត ambition ។

**មាយាការ**.- ការសម្តែងបួកប្ញកាយវិការធ្វើជាកិច្ចកល illusion, maya ។

**មុទិតា**.- ដំណើររីករាយជាមួយនឹងសេចក្តីសុខរបស់គេ sympathy ។

**មេត្តា**.- អារម្មណ៍រាប់រក, អារម្មណ៍នៃមេត្រីភាព mercy, compassion ។

**មោក្សៈ**.- ការរំដោះខ្លួនចេញពីអ្វីជាលោកិយ, ការរួចរដោះ emancipation ។

**មោទនភាព**.- ការមានអារម្មណ៍ចង់លើកតម្កើងខ្លួនឯង, ការពេញចិត្ត pride ។

**យុត្តិធម៌**.- ភាពត្រឹមត្រូវ righteouness, justice, fairness ។

**យោគ**.- ការគួបប្រសព្វគ្នា, ដំណើរព្យាយាម, សមាធិ yoga, austerity ។

**យោគី ឬ យោគិន**.- អ្នកប្រតិបត្តិយោគ yogi or yogin, ascetic ។

**ឫសី ឬ ឥសី**.- សញ្ញាសី គឺអ្នកជម្រះអស់កិលេសស ascetic, rishi ។.

**លោភលន់**.- ដំណើរចង់បានឱ្យលើសគេ ឬចង់បានតែឯង envy, cupidity ។

**លះបង់**( ការ- ).- ការអស់មានអារម្មណ៍ទៅលើអ្វីជាលោកិយ renunciation ។

**ល្ងង់**.-- ការមិនចេះ ឬមិនដឹង ព្រោះមិនបានរៀនសូត្រ ignorance ។.

**វដ្តសង្សារ ឬ វាលវដ្តសង្សារ**.- ដំណើរវិលកើតវិលស្លាប់នៅក្នុងលោក-សន្និវាសនេះ transmigration, evolution of the life cycle ។.

**វិជ្ជា**.- ការចេះ, ការដឹង, ញាណ ( អ្វីជាកុសល ) knowledge, science ។

**វិញ្ញាណ**.- ធម្មជាតិដែលឱ្យដឹងច្បាស់នូវអារម្មណ៍ sense ។

**វិប្បដិសារៈ**.- ការស្តាយក្រោយ remorse, repentance, regret ។.

**វីរកថា.**- រឿងនិទានពីវីរភាព គឺភាពអង់អាច របស់តួអង្គ epic ។.

**វេទនារម្មណ៍.**- ការប៉ះពាល់ត្រូវព្រមនៃអាយតនៈ ជាហេតុបណ្ដាលឱ្យកើតអារម្មណ៍ឡើង sensation, feeling, emotion, impression ។

**សន្ដោស.**- ការអត់ឱនឱ្យនូវទោសកំហុស forgiveness ។.

**សប្បុរស.**- ដែលប្រព្រឹត្តល្អត្រឹមត្រូវ, មានសន្ដានចិត្តទូលាយ generous ។

**សុភាពរាបសា.**- កិរិយារម្យទមដែលតែងមាននៅជាមួយបណ្ឌិត modest kind, gentle ។

**ស្មោះត្រង់.**- ទៀងត្រង់, កាន់ពាក្យសច្ចៈ, មិនភូតភរ honest ។.

**សោកនាដកម្ម.**- រឿងកម្សត់ tragedy ។

**សោះអង្គើយ.**- មិនអើពើ, ព្រងើយកន្តើយ indolence ។

**ស្រុតិ.**- ការស្ដាប់និងចាំតាមឡើងវិញ, ឈ្មោះគម្ពីរមួយ sruti ។

**ហិង្សា.**- ភាពកំណាច, ការបៀតបៀនដោយប្រើកម្លាំងកាយ violence ។

**អចន្តិកនិយម.**- ការយល់ឃើញនិងអនុវត្តជ្រុលហួសហេតុ extremism ។

**អត្ថៈ.**- ផលប្រយោជន៍ advantage, interest ។

**អនត្តា.**- ដែលមិនមែនជារបស់ខ្លួន, មិនមែនខ្លួន non-self ។.

**អនន្តភាព.**- ភាពឋិតនៅជារហូត គឺមិនប្រែប្រួល eternity ។.

**អភិជន.**- ជនក្នុងត្រកូលខ្ពស់, ជនខ្ពង់ខ្ពស់ aristocrat, noble ។.

**អភិជ្ឈា.**- ការសម្លឹងចង់បានអ្វីៗដែលមិនមែនជារបស់ខ្លួន covetousness ។

**អភិញ្ញាណ.**- សេចក្ដីដឹងពិសេសខាងផ្លូវធម៌ឬខាងសីលធម៌ គឺអារម្មណ៍ពិសេសដែលត្រួតពិនិត្យញាណ subconscience, super ego ។

**អតិសមាចារ.**- សីលធម៌ដ៏ឧត្តុង្គឧត្តម ethics, ideal conduct ។

**អមតភាព.**- ភាពមិនចេះស្លាប់ឬមិនចេះវិនាសបាត់បង់; immortality ។.

**អម្រឹត.**- ភេសជ្ជៈទ្រទ្រង់ជីវិតឱ្យនៅជាអមតៈ elixir of immortality ។.

**អយុត្តិធម៌**.- ភាពមិនត្រឹមត្រូវ unrighteousness ។
**អវតារ**.- ច្យុតិនៃទេវតា, ការចុះចាកឋានសួគ៌មកចាប់កំណើតជាមនុស្ស, ការបែងភាគនៃព្រះវិស្ណុ incarnation, avatar ។
**អវិជ្ជា**.- ការបាត់បង់ការពិចារណាលើអ្វីដែលខុសនិងអ្វីដែលត្រឹមត្រូវ, ការមិនយល់ឬមិនស្គាល់ពីករណីយកិច្ចរបស់ខ្លួន ignorance ។
**អហិង្សា**.- ដែលមិនប្រើហិង្សា ឬអាការៈសាហាវ non-violence ។
**អាត្មា**.- ខ្លួនប្រាណ, ញាណ, អង្គ self, ego, conscience ។
**អាត្មានិយម**.- ការគិតតែប្រយោជន៍ផ្ទាល់ខ្លួន egoism, selfishness ។
**អាថ៌កំបាំងនៃអាថ៌កំបាំង**.- secret of the secrets, kingly secret ។
**អារម្មណ៍**.- ការដឹង, គ្រឿងទាក់ទាញចិត្ត feeling, impression ។
**ឥន្ទ្រិយ**.- សេចក្ដីដឹង, ប្រាជ្ញា, អារម្មណ៍ senses, knowledge, thought ។
**ឧបាទាន**.- ការភ្ជាប់អារម្មណ៍ទៅនឹងផលនៃការងារ attachment ។
**ឧបេក្ខា**.- ការតាំងចិត្តជាកណ្ដាល មិនមានលម្អៀង equanimity ។

**សម្គាល់ :**

ខ្ញុំដកស្រង់តែពាក្យមួយចំនួនតូចប៉ុណ្ណោះ គ្រាន់ជាជំនួយឱ្យយល់ន័យរបស់ពាក្យ ។ ដោយហេតុថាពាក្យស្ទើរតែទាំងអស់ជាពាក្យទស្សនវិជ្ជា សេចក្ដីពន្យល់និងការបកប្រែជាភាសាអង់គ្លេសក៏នៅក្នុងន័យនៃទស្សនវិជ្ជាដែរ ។ សូមកុំចាត់ទុកពាក្យអង់គ្លេសទាំងអស់ថាមានន័យត្រឹមត្រូវចំគ្នានឹងន័យរបស់ពាក្យខ្មែរនោះឡើយ វាគ្រាន់តែមានន័យប្រហាក់ប្រហែលគ្នាប៉ុណ្ណោះ ។ សូម្បីតែពាក្យខ្មែរ(ពាក្យវប្បធម៌)ក៏ជួនកាលមានការព្រលាំន័យ (nuance) ស្ទើរនឹងរកពន្យល់ឱ្យចំមិនបានដែរ ដូចជាពាក្យ "អារម្មណ៍, វេទនារម្មណ៍, វិញ្ញាណ, ឥន្ទ្រិយ, អាត្មន, ព្រលឹង", ពាក្យ "ចំណង, ចំណង់, តណ្ហា, ឧបាទាន, អភិជ្ឈា", ពាក្យ "ខ្លៅ, ល្ងង់, អវិជ្ជា" ជាដើម ។

សូមស្វែងយល់បន្ថែមដោយមើលក្នុងវចនានុក្រម ឬសួរវិញ្ញូជនដែលចេះប្រាកដ ។

ផ្សេងៗ

ទំព័រកាព្យ

ពេញដោយការចាប់ចុងចួនរណ្ដំ

បរិយាយអំពីច្បាប់ផ្សេងៗស្ដីពី

សីលធម៌ឧត្ដុង្គឧត្ដម

មានខ្លឹមសារនិងតម្លៃដ៏ខ្ពស់

មានន័យរស់រវើកជាប់ជានិច្ច

សម្រាប់ការអប់រំ ដើម្បី

កសាងខ្លួនឱ្យទៅជាមនុស្សពិតៗ

ជាកំណាប់ទ្រព្យមិនចេះរីងស្ងួត

នៃចំណេះទូទៅ ។